# បេឡាជាតិរបបសន្តិសុខសង្គម
# (ប.ស.ស)

# របាយការណ៍

## ស្តីពី
## លទ្ធផលការងារសម្រេចបានឆ្នាំ២០១៥
## និងទិសដៅអនុវត្តបន្ត

ជំហានទី១
ការអនុវត្តផ្នែកហានិភ័យការងារ

ធានាសន្តិសុខប្រាក់ចំណូល រួមចំណែកកាត់បន្ថយភាពក្រីក្រ លើកកម្ពស់ស្ថិរភាពសង្គម

# បេឡាជាតិរបបសន្តិសុខសង្គម

# (ប.ស.ស)

# របាយការណ៍
# ស្តីពី
# លទ្ធផលការងារសម្រេចបានឆ្នាំ២០១៥
# និងទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០១៦

## ជំពូកទី១
## ការអនុវត្តផ្នែកហានិភ័យការងារ

# មាតិកា

**ចក្ខុវិស័យ បេសកកម្ម និងគោលដៅ** .......... i

**រចនាសម្ព័ន្ធគ្រប់គ្រងរបស់ ប.ស.ស** .......... ii

**សេចក្តីផ្តើម** .......... ១

**I. ការងាររៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត** .......... ២

**II. ពង្រឹង និងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ** .......... ៣

១. ការងារបញ្ជិកា និងភាគទាន .......... ៣

២. ការងារអធិការកិច្ច និងកិច្ចការនីតិកម្ម .......... ៧

៣. ការងារតាវកាលិក .......... ១០

៤. ការងារគ្រប់គ្រង និងបណ្តុះបណ្តាលធនធានមនុស្ស .......... ១៤

៤.១. ការងាររដ្ឋបាល និងហិរញ្ញវត្ថុ .......... ១៤

៤.២. កិច្ចសហប្រតិបត្តិការ និងការងារបណ្តុះបណ្តាលធនធានមនុស្ស .......... ១៥

៤.៣. ការងារព័ត៌មានវិទ្យា .......... ១៩

៤.៤. ការងារសវនកម្មផ្ទៃក្នុង .......... ២០

៥. ការងាររៀបចំបុននីតិសម្បទា .......... ២០

៦. ការងារប្រជុំផ្សព្វផ្សាយ និងបង្ការហានិភ័យការងារ .......... ២១

៦.១. ការងារប្រជុំផ្សព្វផ្សាយ .......... ២១

៦.១.១. ការពង្រឹងការផ្សព្វផ្សាយគោលនយោបាយថ្មីៗ .......... ២៣

៦.២. ការងារប្រជុំផ្សព្វផ្សាយបង្ការហានិភ័យការងារ .......... ២៣

៦.២.១. ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ .......... ២៣

៦.២.២. ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត .......... ២៦

៦.២.៣. គណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹង នៃបេឡាជាតិរបបសន្តិសុខសង្គម .......... ២៨

**III. ការរៀបចំដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព** .......... ២៨

**IV. បញ្ហាប្រឈម** .......... ៣០

**V. វិធានការដោះស្រាយ** .......... ៣១

**VI. ទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០១៦** .......... ៣២

**សេចក្តីសន្និដ្ឋាន** .......... ៣៣

**លទ្ធផលសម្រេចបានធៀបនឹងផែនការសកម្មភាពអនុវត្តយុទ្ធសាស្ត្រគាំពារសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារឆ្នាំ២០១៤-២០១៨** .......... ៣៥

***ការិយាល័យសាខាបេឡាជាតិរបបសន្តិសុខសង្គមតាមបណ្តារាជធានី-ខេត្ត*** .......... ៤៨

***មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិរបបសន្តិសុខសង្គម*** .......... ៥១

***ឧបសម្ព័ន្ធ*** .......... ៦៧

***តារាងចំណាត់ថ្នាក់ហានិភ័យការងារ*** .......... ៧៤

# ចក្ខុវិស័យ និងបេសកកម្ម

## ចក្ខុវិស័យ

ជានាផ្នែកសន្តិសុខសង្គម ប្រកបដោយប្រសិទ្ធភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

## បេសកកម្ម

ផ្តល់សេវាផ្នែកសន្តិសុខសង្គម ប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងទាន់ពេលវេលា សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ក្នុងគោលដៅជួយសម្រាលការលំបាកនានានៅពេលជរាភាព ទុព្វលភាព មរណភាព ហានិភ័យការងារ ឬពេលជួបប្រទះយថាភាពផ្សេងៗទៀត ដូចជាជំងឺ និងមាតុភាពជាដើម។

## គោលដៅ

១. ពង្រីក និងពង្រឹងការអនុវត្តផ្នែកហានិភ័យការងារ (គ្រោះថ្នាក់នៅកន្លែងធ្វើការ, គ្រោះថ្នាក់ពេលធ្វើដំណើរ,ជំងឺវិជ្ជាជីវៈ)
២. ដាក់ឱ្យដំណើរការផ្នែកថែទាំសុខភាព (សេវាបង្ការសុខភាព, ការព្យាបាល និងថែទាំ, ផ្តល់ប្រាក់បំណាច់ជំងឺ,មាតុភាព)
៣. ដាក់ឱ្យដំណើរការផ្នែកប្រាក់សោធន (ជរាភាព, ទុព្វលភាព, មរណភាព)

# រចនាសម្ព័ន្ធគ្រប់គ្រងរបស់បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)



# របាយការណ៍

## ស្តីពី

## លទ្ធផលការងារសម្រេចបានឆ្នាំ២០១៥ និង ទិសដៅអនុវត្តបន្តឆ្នាំ២០១៦ របស់បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)

ការអនុវត្តរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ, ផ្នែកថែទាំសុខភាព និងរបបប្រាក់សោធន ត្រូវបានអនុវត្តអនុលោមតាមច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោម បទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងអនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម ដោយស្រប តាមយុទ្ធសាស្ត្រចតុកោណ, យុទ្ធសាស្ត្រអភិវឌ្ឍជាតិ, យុទ្ធសាស្ត្រគាំពារសង្គមសម្រាប់ជនក្រីក្រ និង ជនងាយរងគ្រោះ, យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ, យុទ្ធសាស្ត្រអភិវឌ្ឍវិស័យការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈ និងយុទ្ធសាស្ត្រគាំពារសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពី ការងារ។

អនុលោមតាមច្បាប់ និង ផែនការយុទ្ធសាស្ត្រ បេឡាជាតិរបបសន្តិសុខសង្គម បានអនុវត្តជំហាន ទី១ របបសន្តិសុខសង្គមផ្នែកហានិភ័យការងារទទួលបានលទ្ធផលយ៉ាងល្អប្រសើរ ព្រមទាំងទទួលបានការ គាំទ្រទាំងនៅកំរិតថ្នាក់ជាតិ និងអន្តរជាតិ។ មួយវិញទៀត ដោយយោងទៅលើស្ថានភាពរីកចំរើននៃសេដ្ឋកិច្ច ជាតិ និងការធ្វើសមាហរណកម្មក្នុងតំបន់ បេឡាជាតិរបបសន្តិសុខសង្គម ក៏បាននិងកំពុងត្រៀមខ្លួនរៀបចំ ពង្រីក ពង្រឹង និងអភិវឌ្ឍសមត្ថភាពបន្ថែមទៀត ដើម្បីផ្តល់សេវារដ្ឋបាលសន្តិសុខសង្គមប្រកបដោយប្រសិទ្ធ ភាព តម្លាភាព គណនេយ្យភាព និងទាន់ពេលវេលា និងដើម្បីចូលរួមអនុវត្តឱ្យបានសម្រេចនូវបទដ្ឋានអន្តរ ជាតិនានា ព្រមទាំងការបង្កិតសេវាសន្តិសុខសង្គមឱ្យបានជិត និងប្រហាក់ប្រហែលប្រទេសក្នុងតំបន់នៅក្នុង ការត្រៀមសមាហរណកម្មអាស៊ានឆ្នាំ២០១៥ ដូចមានចែងនៅក្នុងសរសរស្តម្ភទី៣ សហគមន៍សង្គម-វប្បធម៌ អាស៊ាន។

ក្នុងរយៈពេលជាង ៧ឆ្នាំ គិតចាប់ពី ឆ្នាំ២០០៨-២០១៥ នៃការដាក់ឱ្យដំណើរការជំហានទី១ ផ្នែក ហានិភ័យការងារ ដែលទទួលបានជោគជ័យនេះ វាជាចលករដ៏សំខាន់មួយទៀតក្នុងការជួយជម្រុញឱ្យ ប.ស.ស មានបទពិសោធន៍ប្រកបដោយសក្តានុពល ដើម្បីបង្កើតផ្នែកថ្មីៗបន្ថែមទៀត សំដៅចូលរួមសម្រាលទុក្ខ លំបាកនានារបស់សមាជិកសង្គម ក៏ដូចជាចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រជូនប្រជាពលរដ្ឋ និង លើកកម្ពស់ស្ថិរភាពសង្គម។ ទន្ទឹមនឹងភាពជោគជ័យនេះ ប.ស.ស ក៏បានរកឃើញនូវបញ្ហាមួយចំនួនផង ដែរទាំងចំណុចខ្លាំង និងចំណុចខ្សោយ ដែលជាបទពិសោធន៍ដ៏មានសារៈសំខាន់មួយទៀត សម្រាប់ធ្វើឱ្យ ប្រសើរឡើងនូវការអនុវត្តជំហានទី១ និងជាមូលដ្ឋានឈានទៅអនុវត្តជំហានទី២ ផ្នែកថែទាំសុខភាព និង ជំហានទី៣ ផ្នែកប្រាក់សោធនដើម្បីឱ្យកម្មករនិយោជិតទទួលបាននូវការថែទាំ និងព្យាបាលសុខភាព ព្រម ទាំងរបបប្រាក់សោធនឱ្យបានដូចមន្ត្រីរាជការផងដែរ។

បេឡាជាតិរបបសន្តិសុខសង្គម សង្ឃឹមយ៉ាងមុតមាំថា របាយការណ៍បូកសរុបលទ្ធផលការងារសម្រេចបាននៅឆ្នាំ២០១៥ នេះ វានឹងក្លាយជាឧបករណ៍ដ៏មានប្រសិទ្ធភាពមួយសម្រាប់វាស់វែង តាមដាន និងវាយតម្លៃលើការអនុវត្តវិស័យសន្តិសុខសង្គម ជាពិសេសផ្នែកហានិភ័យការងារ ហើយវាជាកញ្ចក់ឆ្លុះបញ្ចាំងឱ្យឃើញពីចំណុចវិជ្ជមាន និងអវិជ្ជមាន ព្រមទាំងបញ្ហាប្រឈមនានា ដើម្បីធ្វើការកែតម្រូវ និងធ្វើការដោះស្រាយ សម្រាប់រៀបចំទិសដៅអនុវត្តបន្តឆ្នាំ២០១៦ ឱ្យបានកាន់តែល្អប្រសើរថែមទៀត។

## I. ការងាររៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត

ការកើនឡើងនូវទំហំការងារ ចំនួនសមាជិក ស្ថានភាពនៃការរីកចំរើនសេដ្ឋកិច្ចសង្គម និងតម្រូវការនៃការផ្តល់សេវាសាធារណៈ ជូនប្រជាពលរដ្ឋ និយាយជារួម និងនិយាយដោយឡែកសម្រាប់កម្មករនិយោជិតដែលបម្រើការងារនៅតាមបណ្តាសហគ្រាស គ្រឹះស្ថាន ប.ស.ស នៅឆ្នាំ ២០១៥នេះ បានខិតខំប្រឹងប្រែងបំពេញការងារទ្វេរឡើង ដោយបានរៀបចំពង្រឹង ពង្រីក និង អភិវឌ្ឍន៍គោលនយោបាយ ផ្នែកហានិភ័យការងារបន្ថែមទៀត និង ការរៀបចំផែនការរយៈពេលវែង ដែលមានលក្ខណៈស៊ីជម្រៅ និង ការកសាងលិខិតបទដ្ឋានគតិយុត្ត សម្រាប់ជាមូលដ្ឋានក្នុងការអនុវត្ត ដើម្បីជានាក្នុងការផ្តល់សេវាសន្តិសុខសង្គម

*រូបភាពទី១. កិច្ចប្រជុំក្រុមប្រឹក្សាភិបាល នៃ ប.ស.ស លើកទី២៥ ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៥*



ប្រកបដោយប្រសិទ្ធភាព ទាន់ពេលវេលា និងឆ្លើយតបតាមតម្រូវការ។ ទន្ទឹមនឹងការអនុវត្តផ្នែកហានិភ័យការងារចំពោះផ្នែកថែទាំសុខភាពគឺជាគោលដៅទីពីរ ដែលកន្លងមក ប.ស.ស បានបង្កើតក្រុមការងាររៀបចំដាក់ឱ្យដំណើរការ ហើយតាមរយៈក្រុមការងារនេះ ការត្រៀមរៀបចំអនុវត្តការងារសម្រេចបានលទ្ធផលជាច្រើន លើការរៀបចំបែបបទ នីតិវិធីការងារ និង ការរៀបចំលិខិតបទដ្ឋានគតិយុត្ត។ តាមរយៈកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ចំនួន០៩ លើក (លើកទី១៧,១៨,១៩,២០,២១,២២ ,២៣,២៤ និងលើកទី២៥) នៃអាណត្តិទី៣ នេះ ការងារមួយចំនួនត្រូវបានពិនិត្យសម្រេច និងអនុម័ត ព្រមទាំងទទួលបានការឯកភាពយល់ព្រមពីក្រសួងអាណាព្យាបាលទាំងពីរ រួមមាន៖

- ពិនិត្យ និងកែសម្រួលរបាយការណ៍បូកសរុបលទ្ធផលការងារសម្រេចបានឆ្នាំ២០១៤ និងទិសដៅអនុវត្តបន្តរបស់ក្រុមការងារ ទ.ស.ប.ក។
- ពិនិត្យ និងកែសម្រួលរបាយការណ៍បូកសរុបលទ្ធផលការងារសម្រេចបានឆ្នាំ២០១៤ និងទិសដៅអនុវត្តបន្តរបស់ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក)។
- ធ្វើបទបង្ហាញស្តីពីការរៀបចំដំណើរការរបបធានារ៉ាប់រងសុខភាព និងសិក្សាពីសមិទ្ធិលទ្ធភាព។

- ពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០១៤របស់បេឡាជាតិរបបសន្តិសុខសង្គម។
- ពិនិត្យសម្រេចលើខ្លឹមសារមាត្រា៨ថ្មី នៃអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីការបង្កើតក្រុមប្រឹក្សាបច្ចេកទេសរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារ។
- ពិនិត្យលើសេចក្តីព្រាងផែនការចំណូល-ចំណាយថវិការបស់ ប.ស.ស ឆ្នាំ២០១៦។
- ពិភាក្សាឡើងវិញលើការស្នើសុំដីសម្រាប់សង់អគាររដ្ឋបាលរបស់ ប.ស.ស។
- ការពិភាក្សាលើការរៀបចំកំណត់អត្តសញ្ញាណសមាជិក ប.ស.ស ឡើងវិញ។

## II. ពង្រីង និងពង្រីកការអនុវត្តរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ

### ១. ការងារបញ្ជិកា និងភាគទាន

និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវមានកាតព្វកិច្ចចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងបង់ភាគទានហានិភ័យការងារមកក្នុង ប.ស.ស។ ក្នុងដំណាក់កាលចាប់ដំណើរការដំបូង នៃ ប.ស.ស ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន ត្រូវអនុវត្តចំពោះតែសហគ្រាស គ្រឹះស្ថានណាដែលមានកម្មករនិយោជិតចំនួន ០៨ នាក់ឡើង។ អត្រាភាគទាន ផ្នែកហានិភ័យការងារជាអត្រាឯកភាព ដែលត្រូវបានកំណត់ស្មើនឹង ០,៨ ភាគរយ នៃប្រាក់ឈ្នួលមធ្យម ក្នុងលំដាប់ថ្នាក់នៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិត។

*រូបភាពទី២. សកម្មភាពនៃការចុះបញ្ជិកា និង បង់ភាគទាននៅ ប.ស.ស*



#### ១.១. ការងារចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន

រហូតមកដល់ដំណាច់ឆ្នាំ២០១៥ នេះ ប.ស.ស បានពង្រីកវិសាលភាពផ្នែកហានិភ័យការងារគ្របដណ្តប់នៅទូទាំងប្រទេស និងបានចុះបញ្ជិកាសហគ្រាស គ្រឹះស្ថានសរុបជាបឋមចំនួន ***៧.៧៩៦*** សហគ្រាស មានកម្មករនិយោជិតសរុបចំនួន ***១.០៧៧.០៧៩*** នាក់ ស្រីចំនួន *៧៦២.០១៣* នាក់ ត្រូវជា ៧០,៧៤ ភាគរយ។

ដោយឡែកសម្រាប់ឆ្នាំ២០១៥ នេះ ប.ស.ស បានទទួលចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត តាមបណ្តារាជធានី-ខេត្ត បានចំនួន ***៧៥៥*** សហគ្រាស និងមានកម្មករនិយោជិតចំនួន ***៥៥.៤៩១*** នាក់ (ស្រី ***៣៦.៦៨៦*** នាក់) ក្នុងនោះរាជធានីភ្នំពេញមានចំនួន ***៣៨៨*** សហគ្រាស ខេត្តកណ្តាល ***២៦*** សហគ្រាស ខេត្តកំពង់ស្ពឺ ***២៤*** សហគ្រាស ខេត្តសៀមរាប ***៧៣*** សហគ្រាស ខេត្តកំពង់ចាម ***០៨*** សហគ្រាស ខេត្តស្វាយរៀង ***១៩*** សហគ្រាស ខេត្តបាត់ដំបង ***៤២*** សហគ្រាស ខេត្តកំពង់ធំ ***១៤*** សហគ្រាស ខេត្តព្រះសីហនុ ***៣៣*** សហគ្រាស ខេត្តតាកែវ ***១៧*** សហគ្រាស ខេត្តរតនគិរី ***២២*** សហគ្រាស និងខេត្តផ្សេងៗទៀតមានចំនួន ***៨៩*** សហគ្រាស។ *(ព័ត៌មានលំអិតសូមអានក្នុងតារាងឧបសម្ព័ន្ធទី១)*

*ក្រាហ្វិកទី១. ស្ថានភាពសហគ្រាស គ្រឹះស្ថាន ចុះបញ្ជិកាតាមរាជធានី-ខេត្ត ឆ្នាំ២០១៥*




****កំណត់សំគាល់ស្តីពីបច្ចុប្បន្នភាពសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត*

- សហគ្រាសគ្រឹះស្ថាន ៦.៤៧០ ស.ហ **(ដកចំនួនសហគ្រាសបិទ និងផ្អាកដំណើរការ)**
- កម្មករនិយោជិតចំនួន ១.១០៩.៨៩០ នាក់ (ស្រី ៧៧៩.៩៩៨ នាក់) **(បូកចំនួនកម្មករនិយោជិតបានបង់ និងមិនបានបង់ភាគទាន)**

***តារាងទី ១.សហគ្រាសចុះបញ្ជិកា និងសមាជិកថ្នាក់កណ្តាល /ថ្នាក់ខេត្ត***

| សហគ្រាសចុះបញ្ជិកា និងសមាជិកថ្នាក់កណ្តាល និងថ្នាក់ខេត្ត | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| បរិយាយ | សរុប | | | ថ្នាក់កណ្តាល | | | ថ្នាក់ខេត្ត | | |
| | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី |
| ឆ្នាំ២០១៥ | 755 | 55,491 | 36,686 | 388 | 31,426 | 2,064 | 367 | 24,065 | 16,046 |
| ឆ្នាំ២០១៤ | 934 | 174,313 | 125,605 | 576 | 87,622 | 57,804 | 358 | 86,691 | 67,801 |
| ឆ្នាំ២០០៨-២០១៥ | 7,796 | 1,077,079 | 762,013 | 4,687 | 621,537 | 42,033 | 3,109 | 455,542 | 341,683 |

**ប្រភព៖ បេឡាជាតិរបបសន្តិសុខសង្គម ឆ្នាំ ២០១៥ (ទិន្នន័យលំអិតសូមមើលក្នុងតារាង ឧបសម្ព័ន្ធទី ២)**

***តារាងទី ២. បច្ចុប្បន្នភាព សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត***

| បច្ចុប្បន្នភាពសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| បរិយាយ | សរុប | | | ថ្នាក់កណ្តាល | | | ថ្នាក់ខេត្ត | | |
| | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី |
| ឆ្នាំ២០០៨-២០១៥ | 6,470 | 1,109,890 | 779,998 | 3,766 | 638,583 | 424,726 | 2,704 | 471,307 | 355,272 |

**ប្រភព៖ បេឡាជាតិរបបសន្តិសុខសង្គម ឆ្នាំ ២០១៥ (ទិន្នន័យលំអិតសូមមើលក្នុងតារាង ឧបសម្ព័ន្ធទី ៣)**

*តារាងទី៣. សហគ្រាសវិស័យកាត់ដេរ និងផលិតស្បែកជើង ថ្នាក់កណ្តាល-ថ្នាក់ខេត្ត*

| សហគ្រាសវិស័យកាត់ដេរ និងផលិតស្បែកជើង ថ្នាក់កណ្តាល-ថ្នាក់ខេត្ត | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| បរិយាយ | សរុប | | | ថ្នាក់កណ្តាល | | | ថ្នាក់ខេត្ត | | |
| | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី |
| ឆ្នាំ២០០៨-២០១៥ | 1,088 | 715,640 | 599,158 | 733 | 405,158 | 333,768 | 355 | 310,482 | 265,390 |

**ប្រភព៖ បេឡាជាតិរបបសន្តិសុខសង្គម ឆ្នាំ ២០១៥ (ទិន្នន័យលំអិតសូមមើលក្នុងតារាង ឧបសម្ព័ន្ធទី ៤)**

## ១.២. ប្រភេទសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកា

នៅឆ្នាំ២០១៥ នេះ ប.ស.ស បានទទួលចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន បានចំនួន *៧៥៥* ក្នុងនោះរោងចក្រកាត់ដេរមានចំនួនច្រើនជាងគេ *៩៩* បន្ទាប់មកភ្នាក់ងារដឹកជញ្ជូនចំនួន *៧២* សណ្ឋាគារ ៦៣ អង្គការក្រៅរដ្ឋាភិបាលចំនួន *៤៩* ភោជនីយដ្ឋាន ៤៨ បម្រើសេវាកម្មផ្សេងៗ ៤៦ និងសហគ្រាសផ្សេងៗទៀតចំនួន ៣៧៨ ។ *(ទិន្នន័យលំអិតសូមអានក្នុងតារាងឧបសម្ព័ន្ធទី៥ )*

*ក្រាហ្វិកទី២. ប្រភេទសហគ្រាសបានចុះបញ្ជិកា ឆ្នាំ២០១៥*




## ១.៣. ស្ថានភាពសហគ្រាសបិទទ្វារ និងផ្អាកដំណើរការ

នៅឆ្នាំ២០១៥ នេះ សហគ្រាស គ្រឹះស្ថាន បិទទ្វារឈប់ដំណើរការ និងផ្អាកដំណើរការ មានចំនួន ៤៧០ មានកម្មករនិយោជិតសរុបចំនួន ៣៥.៣៨៧ នាក់ ក្នុងនោះសហគ្រាសបិទទ្វារឈប់ដំណើរការជាស្ថាពរមានចំនួន ៣៦៧ មានកម្មករនិយោជិតចំនួន ៣០.០១៩ នាក់ (រាជធានីភ្នំពេញមានចំនួន ២៤២ ខេត្តកណ្តាល ០៩ ខេត្តកំពង់ស្ពឺ ០១ ខេត្តកំពង់ធំ ០៥ ខេត្តស្ទឹងត្រែង ០៣ ខេត្តបន្ទាយមានជ័យ ០៤ ខេត្តសៀមរាប ៣៥ ខេត្តស្វាយរៀង ០៦ ខេត្តព្រះសីហនុ ១០ ខេត្តកំពង់ឆ្នាំង ០១ ខេត្តប៉ៃលិន ០៤ ខេត្តកែប ០២ ខេត្តកំពត ០៤ ខេត្តពោធិ៍សាត់ ០១ ខេត្តតាកែវ ០៩ ខេត្តក្រចេះ ០៣ ខេត្តកំពង់ចាម ០៨ ខេត្តរតនគិរី ០៤ ខេត្តបាត់ដំបង ០៩ ខេត្តមណ្ឌលគិរី ០២ ខេត្តព្រះវិហារ ០៣ និងខេត្តត្បូងឃ្មុំ០២សហគ្រាស)។ ចំណែកឯសហគ្រាសផ្អាកដំណើរការបណ្តោះអាសន្ន មានចំនួន ១០៣ មានកម្មករនិយោជិតសរុបចំនួន ៥.៣៦៨ នាក់ (រាជធានីភ្នំពេញមានចំនួន ៥១ ខេត្តកណ្តាល ០៥ ខេត្តឧត្តរមានជ័យ ០២ ខេត្តបន្ទាយមានជ័យ ០៣ ខេត្តស្ទឹងត្រែង ០១ ខេត្តកំពង់ស្ពឺ ០២ ខេត្តប៉ៃលិន ០២ ខេត្តស្វាយរៀង ០១ ខេត្តតាកែវ ០៩ ខេត្តក្រចេះ ០៤ ខេត្តព្រះសីហនុ ០២ ខេត្តសៀមរាប ០៣ ខេត្តបាត់ដំបង ០៣ ខេត្តកំពង់ឆ្នាំងចំនួន ០៦ ខេត្តកំពង់ចាម ០៣ ខេត្តព្រះវិហារ ០១ ខេត្តពោធិ៍សាត់ ០១ ខេត្តកែប ០១ និងខេត្តត្បូងឃ្មុំ០៣ សហគ្រាស )។

ជាការគួរឱ្យកត់សំគាល់ ក្នុងចំណោមសហគ្រាស គ្រឹះស្ថាន ដែលបានឈប់ដំណើរការខាងលើ រហូតមកដល់ពេលនេះ មានសហគ្រាស គ្រឹះស្ថាន មួយចំនួនបានបើកដំណើរការឡើងវិញហើយ ដែលក្នុងនោះមួយចំនួនបានប្តូរឈ្មោះ មួយចំនួនទៀតបានប្តូរម្ចាស់ ដែលភាគច្រើនជាសិប្បកម្ម, ឡតដ្ឋ, ភោជនីយដ្ឋាន ,.....ដែលមានទីតាំងនៅឆ្ងាយ។

### ១.៤. ប្រៀបធៀបការងារចុះបញ្ជិកា

*ក្រាហ្វិកទី៣. ការងារចុះបញ្ជិកាគិតត្រឹមឆ្នាំ២០១៤ និងឆ្នាំ២០១៥*




ផ្អែកតាមក្រាហ្វិចនេះក្នុងរយៈពេល ០១ឆ្នាំ ចំនួនសហគ្រាស មានការកើនឡើង ៧៥៥ សគ្រាស ស្មើនឹង ១០,៧២ ភាគរយ និងកម្មករនិយោជិតចំនួន ៥៥.៤៩១ នាក់ ស្មើនឹង៥,៤៣ ភាគរយ។




ផ្អែកតាមក្រាហ្វិចនេះក្នុងរយៈពេល ០១ឆ្នាំ ចំនួនសហគ្រាសមានការថយចុះ -១៧៩ សហគ្រាស ស្មើនឹង -១៩,១៦ ភាគរយ និងកម្មករនិយោជិតចំនួន -១១៨.៩២២ នាក់ ស្មើនឹង -៦៨,១៨ ភាគរយ ។

### ១.៥. ការងារភាគទាន

ក្នុងចំនួនសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកានៅ ប.ស.ស ទាំងអស់ ៧.៧៩៦ មានកម្មករនិយោជិតចំនួន ***១.០៧៧.០៧៩*** នាក់ (ស្រី ***៧៦២.០១៣*** នាក់)។ ដោយផ្អែកតាមបច្ចុប្បន្នភាពសហគ្រាស ៦.៤៧០ មានកម្មករនិយោជិត ១.១០៩.៨៩០ នាក់ (ស្រី ៧៧៩.៩៩៨ នាក់) ប.ស.ស បានដាក់ឱ្យជាប់ភាគទានសរុបជាមធ្យម មានចំនួន ៦.១៤៤ សហគ្រាស ក្នុងនោះសហគ្រាសបានបង់ភាគទានមានចំនួន ៥.៦២២ មានចំនួនកម្មករនិយោជិតសរុប ១.០៣៨.១៩១ នាក់ និងសហគ្រាសមិនបានបង់ភាគទានចំនួន ៥១៨ មានចំនួនកម្មករនិយោជិត ២៨.២២៦ នាក់។

***តារាងទី៤. ចំនួនសហគ្រាស គ្រឹះស្ថាន និងចំនួនកម្មករនិយោជិត បានបង់ភាគទាន***

| ខែ | ឆ្នាំ | ចំនួនស.ហ ជាប់ភាគទាន | ចំនួនស.ហ បានបង់ភាគទាន | ចំនួនកម្មករ បានបង់ភាគទាន (នាក់) | ចំនួនភាគទានសរុប (រៀល) | ចំនួនស.ហ មិនបានបង់ភាគទាន | ចំនួនកម្មករ មិនបានបង់ភាគទាន (នាក់) | ចំនួនភាគទានសហមិនទាន់បង់ (រៀល) |
|---|---|---|---|---|---|---|---|---|
| វិច្ឆិកា | ២០១៤ | 5,937 | 5,686 | 1,008,273 | 5,247,493,199 | 251 | 11,308 | 36,920,600 |
| ធ្នូ | | 6,020 | 5,702 | 1,009,515 | 5,379,547,180 | 318 | 26,836 | 106,852,200 |
| មករា | ២០១៥ | 5,995 | 5,696 | 1,015,511 | 5,986,061,593 | 299 | 13,587 | 44,906,400 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| កុម្ភៈ | | 6,021 | 5,696 | 1,018,252 | 5,859,008,380 | 325 | 14,642 | 49,473,600 |
| មីនា | | 6,081 | 5,726 | 1,024,004 | 6,021,689,000 | 355 | 18,376 | 60,502,600 |
| មេសា | | 6,111 | 5,749 | 1,028,198 | 5,723,537,300 | 362 | 18,402 | 62,133,600 |
| ឧសភា | | 6,130 | 5,737 | 1,051,187 | 6,342,858,627 | 393 | 20,661 | 71,826,400 |
| មិថុនា | | 6,159 | 5,706 | 1,065,103 | 6,545,141,900 | 453 | 22,408 | 79,175,200 |
| កក្កដា | | 6,231 | 5,636 | 1,073,829 | 6,617,076,500 | 569 | 28,615 | 107,477,100 |
| សីហា | | 6,295 | 5,580 | 1,072,647 | 6,438,201,193 | 689 | 35,115 | 137,866,700 |
| កញ្ញា | | 6,342 | 5,419 | 1,060,868 | 6,432,582,793 | 923 | 49,289 | 202,152,800 |
| តុលា | | 6,406 | 5,125 | 1,030,422 | 6,024,539,100 | 1,281 | 79,468 | 352,796,000 |
| សរុប | | មធ្យមភាគ | មធ្យមភាគ | មធ្យមភាគ | សរុប | មធ្យមភាគ | មធ្យមភាគ | សរុប |
| | | 6,144 | 5,622 | 1,038,151 | 72,617,736,765 | 518 | 28,226 | 1,312,083,200 |

ប្រភព៖ បេឡាជាតិរបបសន្តិសុខសង្គម ឆ្នាំ២០១៥

### ១.៦. ប្រៀបធៀបការងារបង់ភាគទានឆ្នាំ២០១៤ និង ឆ្នាំ២០១៥

*ក្រាហ្វិកទី៥. ចំនួនសហគ្រាស កម្មករនិយោជិតបានបង់ភាគទាន និងភាគទានឆ្នាំ២០១៤ និង ឆ្នាំ២០១៥*




បើធ្វើការគណនាតាមក្រាហ្វិកខាងលើ នេះចំនួនសហគ្រាស គ្រឹះស្ថាន ដែលបានបង់ភាគទានមានការថយចុះចំនួន -១៣៦ សហគ្រាស ស្មើនឹង -២,៣៦ ភាគរយ, និងកម្មករនិយោជិតកើនឡើងចំនួន ១២៩.៦១៦ នាក់ ស្មើនឹង ១៤,២៧ ភាគរយ និងភាគទានសរុបមានការកើនឡើង២៤.៧៩៤.៣៩៩.០១៥ រៀល ស្មើនឹង ៥១,៨៤ ភាគរយ។

## ២. ការងារអធិការកិច្ច និងកិច្ចការនីតិកម្ម

ការងារអធិការកិច្ច និងកិច្ចការនីតិកម្ម មានមុខងារក្នុងការធានាឱ្យមានការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងបទបញ្ញាផ្សេងៗជាធរមាន។ ផ្នែកនេះផ្តោតជាសំខាន់លើការងារមួយចំនួនមានជាអាទិ៍ ការចុះពន្យល់ណែនាំម្ចាស់សហគ្រាស គ្រឹះស្ថាន ស្តីពីការអនុវត្តគោលនយោបាយរបបធានារ៉ាប់រងហានិភ័យការងារ ដើម្បីឱ្យមានការចុះបញ្ជិកា និងបង់ភាគទាននៅ ប.ស.ស, ការចុះអង្កេតគ្រោះថ្នាក់ការងារ, ការស៊ើបអង្កេតអំពីស្ថានភាព របស់អ្នករស់នៅក្នុងបន្ទុករបស់ជនរងគ្រោះ, ការពង្រឹងការអនុវត្តច្បាប់តាមរយៈការធ្វើអធិការកិច្ច, ការដាក់កំហិត, ការពិន័យ និងដាក់បណ្តឹងទៅតុលាការក្នុងករណីសហគ្រាស គ្រឹះស្ថានមិនព្រមអនុវត្តតាមច្បាប់។

### ២.១. ការងារអធិការកិច្ច

ជាលទ្ធផលនៅក្នុងឆ្នាំ២០១៥ នេះ មន្ត្រីអធិការរបបសន្តិសុខសង្គម បានចុះអធិការកិច្ចចំនួន ៦.៥៥២ សហគ្រាស ស្មើនឹង ៦.១០៩ លើក ក្នុងនោះមន្ត្រីអធិការរបបសន្តិសុខសង្គម បានចុះអធិការកិច្ចពិសេសជាមួយក្រុមអធិការកិច្ចតែមួយ ចំនួន ១៤៣ សហគ្រាស ស្មើនឹង ១៤៣ លើក។

### ២.១.១. ការចុះអធិការកិច្ចចុះបញ្ជិកា

មន្ត្រីអធិការរបបសន្តិសុខសង្គម បានចុះស្រាវជ្រាវសហគ្រាស គ្រឹះស្ថានថ្មីបានចំនួន ១.០៥៥, ចុះចែកលិខិតជូនដំណឹងអធិការកិច្ចចំនួន ១.០៤៥ សហគ្រាស, ចុះអធិការកិច្ចចុះបញ្ជិកាបានចំនួន ៦៨៨ សហគ្រាស, ដាក់លិខិតដាក់កំហិតចំនួន ២៦២, ធ្វើកំណត់ហេតុផាកពិន័យបានចំនួន ២៦ សហគ្រាស និងសម្របសម្រួលចុះបញ្ជិកាបានចំនួន ៣០៨ សហគ្រាស សរុបការចុះអធិការកិច្ចចុះបញ្ជិកាបានចំនួន ៣.៣៨៤ សហគ្រាស ស្មើនឹងចំនួន ៣.១៨៩ លើក ។

*តារាងទី៥.ការចុះអធិការកិច្ចចុះបញ្ជិកា*

| ល.រ | សកម្មភាព | ចំនួនលើក(ដង) | | ចំនួនសហគ្រាស | | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | ស្នាក់ការកណ្តាល | សាខាខណ្ឌ-ខេត្ត | ស្នាក់ការកណ្តាល | សាខាខណ្ឌ-ខេត្ត | |
| ១ | ចុះស្រាវជ្រាវសហគ្រាស គ្រឹះស្ថានថ្មី | 312 | 635 | 368 | 687 | |
| ២ | ចុះចែកលិខិតជូនដំណឹងអធិការកិច្ច | 482 | 520 | 525 | 520 | |
| ៣ | ចុះអធិការកិច្ចចុះបញ្ជិកា | 124 | 520 | 168 | 520 | |
| ៤ | បានដាក់លិខិតដាក់កំហិត | 150 | 112 | 150 | 112 | |
| ៥ | ចុះអធិការកិច្ចផាកពិន័យ | 26 | - | 26 | - | |
| ៦ | សម្របសម្រួលចុះបញ្ជិកា | 122 | 186 | 122 | 186 | |
| សរុប | | 1,216 | 1,973 | 1,359 | 2,025 | |
| សរុបរួមលទ្ធផលនៃការចុះអធិការកិច្ច | | 3,189 | | 3,384 | | |

### ២.១.២. ការចុះអធិការកិច្ចការងារតែមួយ

មន្ត្រីអធិការរបបសន្តិសុខសង្គម បានចុះអធិការកិច្ចសាមញ្ញលើកទី១ ជាមួយក្រុមអធិការកិច្ចការងារតែមួយបានចំនួន ១.៤២២ សហគ្រាស ស្មើនឹង ១.២៣១ លើក ក្នុងនោះបានរកឃើញសហគ្រាសចំនួន ២០២ រាយការណ៍ពីចំនួនកម្មករនិយោជិតមក ប.ស.ស មិនបានត្រឹមត្រូវ, សហគ្រាសចំនួន ១៣២ មិនបានបញ្ចូលថ្លៃបាយរបស់កម្មករនិយោជិត, សហគ្រាសចំនួន ៨៣ ប្រកាសប្រាក់ឈ្នួលកម្មករនិយោជិតមិនត្រឹមត្រូវ និងសហគ្រាសចំនួន ១៥ មិនបញ្ចូលប្រាក់បន្ថែមម៉ោងរបស់កម្មករនិយោជិត។

បន្ទាប់ពីការចុះលើកទី១ មន្ត្រីអធិការរបបសន្តិសុខសង្គម ក៏បានចុះអធិការកិច្ចសាមញ្ញលើកទី២ ទៅលើសហគ្រាស ដែលបានចុះអធិការកិច្ចសាមញ្ញលើកទី១រួចជាមួយក្រុមអធិការកិច្ចតែមួយបានចំនួន ១៣២ សហគ្រាស ស្មើនឹង ១៣២ លើក ក្នុងនោះមន្ត្រីអធិការរបបសន្តិសុខសង្គម បានរកឃើញសហគ្រាស ចំនួន ០៦ ដែលមិនអនុវត្តតាមច្បាប់។

លើសពីនេះទៀត មន្ត្រីអធិការរបបសន្តិសុខសង្គម បានចុះអធិការកិច្ចពិសេសជាមួយក្រុមអធិការកិច្ចតែមួយចំនួន ១៤៣ សហគ្រាស ស្មើនឹង ១៤៣ លើក ក្នុងនោះមន្ត្រីអធិការរបបសន្តិសុខសង្គម បានកត់សម្គាល់ឃើញមានសហគ្រាសចំនួន ១២៦ អនុវត្តបានត្រឹមត្រូវតាមការណែនាំ, សហគ្រាសចំនួន ១៧ នៅមិនទាន់អនុវត្តបានត្រឹមត្រូវនៅឡើយព្រមទាំងបានរកឃើញនូវកំហុសថ្មីចំនួន ១១ សហគ្រាស។ សរុបចំនួនលើកនៃការចុះអធិការកិច្ចបានចំនួន ១.៦៩៧ សហគ្រាស ស្មើនឹង ១.៥០៦ លើក។

### ២.១.៣. ការចុះអធិការកិច្ចទារភាគទាន

តាមរយៈលទ្ធផលចុះអធិការកិច្ចទារភាគទាន សរុបបានចំនួន ៣១១ សហគ្រាស ស្មើនឹង ២៥៤ លើក។

*តារាងទី ៦.ការចុះអធិការកិច្ចទារភាគទាន*

| ល.រ | សកម្មភាព | ចំនួនលើក(ដង) | | ចំនួនសហគ្រាស | | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | ស្នាក់ការកណ្ដាល | សាខាខណ្ឌ-ខេត្ត | ស្នាក់ការកណ្ដាល | សាខាខណ្ឌ-ខេត្ត | |
| ១ | ចុះអធិការកិច្ចពិន័យរាប់កម្មករ | 12 | - | 18 | - | |
| ២ | ពិន័យចេញដោយនាយក ប.ស.ស | 6 | 9 | 6 | 9 | |
| ៣ | អធិការកិច្ចទារប្រាក់ពិន័យ | 5 | - | 5 | - | |
| ៤ | ចុះអធិការកិច្ចបង់ភាគទាន | 112 | 23 | 122 | 33 | |
| ៥ | បានដាក់លិខិតដាក់កំហិត | 46 | 18 | 52 | 30 | |
| ៦ | សម្របសម្រួលបង់ភាគទាន(ក្រើនរំលឹករួចបង់) | 14 | 9 | 22 | 14 | |
| សរុប | | 195 | 59 | 225 | 86 | |
| សរុបរួមលទ្ធផលនៃការចុះអធិការកិច្ច | | | 254 | | 311 | |

### ២.១.៤. ការងារផ្សេងៗផ្នែកអធិការកិច្ច

ទន្ទឹមនឹងលទ្ធផលដែលសម្រេចបានខាងលើ មន្ត្រីអធិការរបបសន្តិសុខសង្គម ក៏បានបំពេញភារកិច្ចមួយចំនួនទៀតផងដែររួមមាន ការចុះពិនិត្យសហគ្រាស គ្រឹះស្ថាន ដែលសង្ស័យថាបានបិទ ឬ បើក ចំនួន ២៣០ សហគ្រាស ស្មើនឹង ២៣០ លើក, ចុះចែកវិញ្ញាបនបត្រចំនួន ២២ សហគ្រាស, ចុះពន្យល់ពីអត្ថប្រយោជន៍របស់ ប.ស.ស ចំនួន ៣២ សហគ្រាស, ចុះសម្របសម្រួលបង់ភាគទាន និងប្រព័ន្ធព័ត៌មានវិទ្យាចំនួន ១៦ សហគ្រាស, ចុះពិនិត្យមើលសហគ្រាសសុំផ្អាកបង់ភាគទានចំនួន ២៤, ចុះចែកលិខិតទារភាគទាន និងប្រាក់ពិន័យ ព្រមទាំងការប្រាក់ចំនួន ៨២៤ សហគ្រាស និងបានចុះសម្របសម្រួលការងារ និងពន្យល់ នីតិវិធីការងារដល់មន្ត្រី បុគ្គលិក ប.ស.ស សាខាខេត្តចំនួន ១២ លើក សរុបការងារអធិការកិច្ចផ្សេងៗមានចំនួន ១.១៦០ សហគ្រាស ស្មើនឹង ១.១៦០ លើក។

## ២.២. ការងារអង្កេតហានិភ័យការងារ

ប.ស.ស បានទទួលរបាយការណ៍ហានិភ័យការងារចំនួន ៣០.៩១៩ នាក់ ក្នុងនោះអង្កេតបានចំនួន ៣១.០៧២ នាក់ មានគ្រោះថ្នាក់ការងារសរុបចំនួន ៣០.២៨១ នាក់ រួមមាននោះគ្រោះថ្នាក់នៅកន្លែងធ្វើការមានចំនួន ២២.៤៩០ នាក់ និងគ្រោះថ្នាក់នៅពេលធ្វើដំណើរមានចំនួន ៧.៧៩១ នាក់ និងជំងឺវិជ្ជាជីវៈ ចំនួន ០៣ នាក់ (ជំងឺវិជ្ជាជីវៈ ០៣ នាក់ ត្រូវបានរាប់បញ្ចូលក្នុងគ្រោះថ្នាក់កន្លែងការងារ) និងមិនមែនគ្រោះថ្នាក់ការងារមានចំនួន ៧៩១ នាក់។ មួយវិញទៀតក៏បានអង្កេតឧត្តរជីវីចំនួន ១៨៦ ករណី ក្នុងនោះបានផ្ដល់ឧត្តរជីវីចំនួន ១០៦ ករណី និងមិនបានផ្ដល់ចំនួន ៨០ ករណី ដោយពុំគ្រប់តាមលក្ខខណ្ឌដែលបានកំណត់។

### ២.៣. ការងារនីតិកម្ម

ប.ស.ស បានចុះធ្វើការផាកពិន័យការចុះបញ្ជិកា សហគ្រាស គ្រឹះស្ថានចំនួន ០៧, ចុះអធិការកិច្ចទារភាគទានចំនួន ១៥៥ សហគ្រាស, សហគ្រាស ចំនួន ០៤ កំពុងដោះស្រាយនៅសាលាដំបូងរាជធានីភ្នំពេញ។

ចំពោះការងារជាមួយក្រុមអធិការកិច្ចការងារតែមួយ អធិការរបបសន្តិសុខសង្គម បានចុះអធិការកិច្ចចំនួន ១.៦៩៧ សហគ្រាស ក្នុងនោះមន្ត្រីអធិការរបបសន្តិសុខសង្គមបានរកឃើញសហគ្រាស គ្រឹះស្ថានមួយចំនួនរាយការណ៍ពីចំនួនកម្មករនិយោជិតមក ប.ស.ស មិនបានត្រឹមត្រូវ, មិនបានបញ្ចូលថ្លៃបាយរបស់កម្មករនិយោជិត, ប្រកាសប្រាក់ឈ្នួលមិនគ្រប់តាមចំនួនជាក់ស្តែង និងមិនបញ្ចូលប្រាក់បន្ថែមម៉ោងរបស់កម្មករនិយោជិត។ សហគ្រាស គ្រឹះស្ថាន ដែលក្រុមអធិការរបបសន្តិសុខសង្គមបានរកឃើញខាងលើមានចំនួន២វគ្គសរុបចំនួន ១៦៤ សហគ្រាស ត្រូវបានធ្វើលិខិតផាកពិន័យចំនួន ៩៧ សហគ្រាស។

## ៣. ការងារតាវកាលិក

ការកើនឡើងនូវចំនួនសមាជិក ដែលនាំឱ្យចំនួនគ្រោះថ្នាក់ការងារមានការកើនឡើងផងដែរនោះ ប.ស.ស បានរៀបចំអភិវឌ្ឍបែបបទការងារ និងបានពង្រឹកយន្តការនៃការផ្តល់តាវកាលិកឱ្យកាន់តែមានភាពងាយស្រួល ទូលំទូលាយបន្ថែមទៀត ដើម្បីឱ្យកម្មករនិយោជិតដែលទទួលរងនូវគ្រោះថ្នាក់ការងារ ទទួលបានសេវាប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា។ តាមរយៈនេះ ប.ស.ស បានបង្កើត និងដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធគ្រប់គ្រងទិន្នន័យទាមទារតាវកាលិកហានិភ័យការងារ ដែលប្រព័ន្ធនេះអាចគ្រប់គ្រងបាននូវរបាយការណ៍ហានិភ័យការងារ ការអង្កេត និងការគណនាតាវកាលិកដែលវាបានពន្លឿនក្នុងការផ្តល់តាវកាលិក និងមានភាពត្រឹមត្រូវ។ ប.ស.ស ក៏បានពង្រីកការចុះកិច្ចព្រមព្រៀងជាមួយមន្ទីរពេទ្យសាធារណៈ និងឯកជនបានចំនួន ៩៣ និងបានដាក់ភ្នាក់ងារឱ្យប្រចាំការនៅតាមមន្ទីរពេទ្យបានមួយចំនួន សម្រាប់ជួយសម្របសម្រួលដល់ជនរងគ្រោះ ដែលជាសមាជិករបស់ ប.ស.ស ឱ្យទទួលបានការសម្រាកព្យាបាល និងងាយស្រួលទទួលបានសេវានៅកន្លែងដែលជិត។ មួយវិញទៀតក្នុងករណីមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ប.ស.ស បាន បញ្ជូនមន្ត្រីទៅដល់កន្លែងគ្រោះថ្នាក់ផ្ទាល់ ដើម្បីជួយសម្របសម្រួល និងធ្វើអន្តរាគមន៍បានទាន់ពេលវេលា។

### ៣.១. របាយការណ៍ហានិភ័យការងារ

សម្រាប់ឆ្នាំ២០១៥ នេះ ប.ស.ស បានទទួលរបាយការណ៍ហានិភ័យការងារពីបណ្តាសហគ្រាស គ្រឹះស្ថាន តាមបណ្តារាជធានី-ខេត្ត នៅទូទាំងប្រទេសមានចំនួន ២៧.៩១៦ ករណី មានកម្មករ និយោជិតចំនួន ៣០.៩១៩ នាក់ (ស្រីចំនួន ២២.៧៦៤ នាក់) ហើយតាមរយៈលទ្ធផលនៃការអង្កេតមានគ្រោះថ្នាក់ការងារ ចំនួន ៣០.២៨១ នាក់ (ស្រីចំនួន ២២.២៧៣ នាក់) ក្នុងនោះគ្រោះថ្នាក់កន្លែងធ្វើការមានចំនួន ២២.៤៨៧ នាក់ (ស្រី ១៧.២៨០ នាក់) គ្រោះថ្នាក់ពេលធ្វើដំណើរមានចំនួន ៧.៧៩១ នាក់ (ស្រី ៤.៩៩១ នាក់) និងជម្ងឺវិជ្ជាជីវៈ មានចំនួន ០៣ នាក់ (ស្រី ០២ នាក់) ចំពោះកម្រិតនៃរបួសវិញមានរបួសស្រាលចំនួន ២៧.៨០៤ នាក់ (ស្រី ២០.៨០២ នាក់) របួសធ្ងន់ចំនួន ២.២៩៦ នាក់ (ស្រី ១.៤០៤ នាក់) ស្លាប់ ចំនួន ១៨១ នាក់ (ស្រី ៦៧ នាក់) និងមិនមែនជាគ្រោះថ្នាក់ការងារចំនួន ៧៩១ នាក់ (ស្រី ៦២៤ នាក់)។ *(ទិន្នន័យអំពីរបាយការណ៍ហានិភ័យការងារ សូមមើលក្នុងតារាងឧបសម្ព័ន្ធទី៦)*

## ៣.២. ប្រៀបធៀបស្ថានភាពគ្រោះថ្នាក់ការងារឆ្នាំ២០១៤ និងឆ្នាំ២០១៥

*ក្រាហ្វិកទី៦. ចំនួនកម្មករនិយោជិតបានចុះបញ្ជិកា និងចំនួនគ្រោះថ្នាក់ការងារ (នាក់)*




តាមក្រាហ្វិកខាងលើបានបង្ហាញឱ្យឃើញថា ចំនួនកម្មករនិយោជិតគ្រោះថ្នាក់ការងារឆ្នាំ២០១៥ មានចំនួន ៣០.២៨១ នាក់ រីឯនៅឆ្នាំ២០១៤ ចំនួន ១៨.៦៩៩ នាក់ ដូច្នេះចំនួននេះមានការកើនឡើង ១១.៥៨២ នាក់ ស្មើនឹង ៦១,៩៣ ភាគរយ។ ចំពោះកម្មករនិយោជិតបានចុះបញ្ជិកាវិញមានការកើនឡើងចំនួន ៥៥.៤៩១ នាក់ ស្មើនឹង ៥,៤៣ ភាគរយ។ យើងឃើញថាចំនួនគ្រោះថ្នាក់ការងារមានការកើនឡើងចំនួន ៦១,៩៣ ភាគរយ រីឯចំនួនកម្មករនិយោជិតដែលបានចុះបញ្ជិកាមានការកើនឡើងចំនួន ៥,៤៣ ភាគរយ ដូច្នេះបើប្រៀបធៀបជាមួយនឹងកំណើនទាំងពីរ ចំនួនគ្រោះថ្នាក់ការងារមានការកើនឡើងស្របនឹង ចំនួនកម្មករនិយោជិតដែលបានចុះបញ្ជិកា។ ចំពោះអត្រាគ្រោះថ្នាក់ការងារកម្មករនិយោជិត ធៀបជាមួយកម្មករបានចុះបញ្ជិកានៅឆ្នាំ២០១៥ មានចំនួន ២,៨១% និងនៅឆ្នាំ២០១៤ មានចំនួន ១,៨៣%។

*ក្រាហ្វិកទី៧. ស្ថានភាពគ្រោះថ្នាក់ការងារតាមប្រភេទគ្រោះថ្នាក់ និងកម្រិតរបួស(នាក់)*




ស្ថានភាពគ្រោះថ្នាក់ការងារនៅឆ្នាំ២០១៥ មានការកើនឡើងចំពោះគ្រោះថ្នាក់នៅកន្លែងធ្វើការ ចំនួន ៨.៤៦៥ នាក់ ស្មើនឹង ៦០,៣៦ ភាគរយ, កម្រិតរបួសស្រាលកើនឡើងចំនួន ១០.៥៩០ នាក់ ស្មើនឹង ៦១,៥១ ភាគរយ, របួសធ្ងន់កើនឡើងចំនួន ៩០៩ នាក់ ស្មើនឹង ៦៥,៥៣ ភាគរយ និងស្លាប់កើនឡើងចំនួន ៨៦ នាក់។ ចំពោះស្ថានភាពគ្រោះថ្នាក់នៅពេលធ្វើដំណើរមានការថយចុះចំនួន ៣.១១៧ នាក់ ស្មើនឹង ៦៦,៦៨ ភាគរយ និងជម្ងឺវិជ្ជាជីវៈមានចំនួនស្មើគ្នា។ ការកើនឡើងនូវករណីគ្រោះថ្នាក់ការមួយចំនួននេះវាស្របនឹងការកើនឡើងនៃចំនួនកម្មករនិយោជិតដែលបានចុះបញ្ជិកា។

## ៣.៣. ការទាមទារតាវកាលិកហានិភ័យការងារ

នៅឆ្នាំ២០១៥ ប.ស.ស បានទទួលការទាមទារតាវកាលិកហានិភ័យការងារសរុបចំនួន ១៥.៥៩១ នាក់(ស្រី១០.៨៥៤នាក់)ស្មើនឹង២៥.៨៤៩ឯកសារ។ បើប្រៀបធៀបនឹងឆ្នាំ២០១៤ ការទាមទារតាវកាលិក

មានតែចំនួន ១៦.៦២១ ឯកសារ ដូច្នេះចំនួននេះមានការកើនឡើង ៩.២២៨ ឯកសារ ស្មើនឹង ៥៥,៥២ ភាគរយ។

*តារាងទី៧. ការទាមទារតាវកាលិកហានិភ័យការងារ*

| ល.រ | ប្រភេទតាវកាលិក | ចំនួនការទាមទារ ឆ្នាំ២០១៥ (ឯកសារ) | ចំនួនការទាមទារ ឆ្នាំ២០១៤ (ឯកសារ) |
|---|---|---|---|
| ១ | តាវកាលិកថែទាំ និង ព្យាបាល | 12,804 | 864 |
| ២ | តាវកាលិកបាត់បង់សមត្ថភាពបណ្តោះអាសន្ន | 12,589 | 7,772 |
| ៣ | តាវកាលិកបាត់បង់. អចិន្ត្រៃយ៍ក្រោម ២០% (វិភាជន៍) | 68 | 22 |
| ៤ | តាវកាលិកបាត់បង់. អចិន្ត្រៃយ៍ចាប់ពី ២០% (ធនលាភ) | 118 | 42 |
| ៥ | តាវកាលិកឧត្តរជីវី | 85 | 45 |
| ៦ | វិភាជន៍បូជាសព | 179 | 100 |
| ៧ | តាវកាលិកអ្នកចាំថែរក្សា | 6 | - |
| សរុប | | **25,849** | **16,621** |

### ៣.៤. ការចំណាយតាមប្រភេទតាវកាលិក

តាមរយៈការទាមទារតាវកាលិកពីជនរងគ្រោះ ប.ស.ស បានចេញសេចក្តីសម្រេចផ្តល់តាវកាលិកហានិភ័យការងារ ដល់កម្មករនិយោជិតដែលរងគ្រោះថ្នាក់ការងារចំនួន *១៥.៣៣៨* នាក់ ស្មើនឹង *២៨.៤៦២* ឯកសារ សម្រាប់ការព្យាបាលនៅតាមមន្ទីរពេទ្យ និងការថែទាំ, ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន, ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍, ឧត្តរជីវី, វិភាជន៍បូជាសព និងតាវកាលិកអ្នកចាំថែរក្សាសរុបចំនួន *៥.៩១៣.៥៨៦.០០០* រៀល និងចេញសេចក្តីសម្រេចទូទាត់ថ្លៃព្យាបាលវេជ្ជសាស្ត្រជូនមន្ទីរពេទ្យផ្លូវការចំនួន *៥៤* សហគ្រាស មានកម្មករនិយោជិតព្យាបាលចំនួន *២០.៦០៥* នាក់ ចំណាយទឹកប្រាក់ ចំនួន *៥.០១៤.៩៨១.២០០* រៀល និងមន្ទីរពេទ្យក្រៅផ្លូវការ ចំនួន *៣៦* សហគ្រាស មានកម្មករនិយោជិត ព្យាបាលចំនួន *៨.៦៧៨* នាក់ ចំណាយទឹកប្រាក់ចំនួន *១.០៨៨.៦៤១.៦០០* រៀល និងសេវាបុននីតិសម្បទា ចំនួន *១០* នាក់ ចំណាយទឹកប្រាក់ចំនួន *៤១,១៧៥.៥០០* រៀល។ ដូច្នេះ សរុបការចេញសេចក្តីសម្រេចផ្តល់តាវកាលិកហានិភ័យការងារ និងទូទាត់ថ្លៃព្យាបាលវេជ្ជសាស្ត្រជូនមន្ទីរពេទ្យផ្លូវការក្រៅផ្លូវការ និងសេវាបុននីតិសម្បទាសម្រាប់ឆ្នាំ២០១៥ មានទឹកប្រាក់សរុបចំនួន ***១២.០៥៨.៣៨៤.៣០០*** រៀល។

*តារាងទី៨. ការចំណាយតាមប្រភេទតាវកាលិកហានិភ័យការងារ*

| *ល.រ* | *ចំណាយតាមប្រភេទតាវកាលិក* | *ចំណាយតាវកាលិក ឆ្នាំ២០១៥* | *ចំណាយតាវកាលិក ឆ្នាំ២០១៤* |
|---|---|---|---|
| | | *ចំណាយ (៛)* | *ចំណាយ (៛)* |
| ១ | តាវកាលិកព្យាបាល | 2,213,447,800 | 1,339,757,800 |
| ២ | តាវកាលិកថែទាំ | 111,104,300 | 59,465,000 |
| ៣ | តាវកាលិកបាត់បង់សមត្ថភាពបណ្តោះអាសន្ន | 1,806,873,600 | 967,263,100 |
| ៤ | តាវកាលិក.អចិន្ត្រៃយ៍ក្រោម ២០% *(វិភាជន៍)* | 177,958,200 | 52,810,600 |
| ៥ | តាវកាលិក.អចិន្ត្រៃយ៍ចាប់ពី ២០% *(ធនលាភ)* | 267,744,000 | 110,264,500 |

| | | | |
|---|---|---|---|
| ៦ | តាវកាលិកឧត្តរជីវី *(ធនលាភ)* | 594,253,900 | 283,238,800 |
| ៧ | វិភាជន៍បូជាសព | 720,000,000 | 392,000,000 |
| ៨ | តាវកាលិកអ្នកថាំថៃរក្សា | 22,204,200 | 4,875,000 |
| ៩ | សេវាបុនទីតិសម្បទា | 41,175,500 | 5,810,800 |
| **សរុប** | | **5,954,761,500** | **3,215,485,600** |
| | ***ការចំណាយតាមមន្ទីរពេទ្យ*** | | |
| **ល.រ** | **មន្ទីរពេទ្យ** | **ឆ្នាំ២០១៥** | **ឆ្នាំ២០១៤** |
| ១ | មន្ទីរពេទ្យផ្លូវការ | 5,014,981,200 | 4,013,036,400 |
| ២ | មន្ទីរពេទ្យក្រៅផ្លូវការ | 1,088,641,600 | 758,547,600 |
| **សរុប** | | **6,103,622,800** | **4,771,584,000** |
| **សរុបរួម** | | **12,058,384,300** | **7,987,069,600** |

ចំនួនអ្នកស្នើសុំ និងចំនួនអ្នកដែលត្រូវបានផ្តល់តាវកាលិកមិនដូចគ្នាទេ ដោយសារឯកសារមួយចំនួនបានបន្សល់ទុកមកពីឆ្នាំចាស់ ហើយបន្តផ្តល់រហូតមកដល់ឆ្នាំបន្ទាប់។ ការផ្តល់តាវកាលិកសម្រាប់ឆ្នាំ២០១៥ នេះ ចំណាយថវិកាកើនចំនួន ៤.០៧១.៣១៤.៧០០ រៀល ត្រូវជា ៥០,៩៧ ភាគរយ។ ការកើនឡើងនៃការស្នើសុំ និងការផ្តល់តាវកាលិកនេះ ដោយសារការកើនឡើងនូវចំនួនគ្រោះថ្នាក់ការងារ ស្របគ្នានឹងការកើនឡើងកម្មករនិយោជិតដែលបានចុះបញ្ជិកា។

### ៣.៥. ការទាមទារសំណងតាវកាលិកមិនមែនគ្រោះថ្នាក់ការងារ

ជនរងគ្រោះដែលជាសមាជិកនៃប.ស.សទទួលរងគ្រោះថ្នាក់ការងារត្រូវទទួលបានការសម្រាកព្យាបាលដោយឥតគិតថ្លៃនៅតាមបណ្តាមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ប៉ុន្តែកន្លងមក មានកម្មករនិយោជិតមួយចំនួនទទួលរងនូវគ្រោះថ្នាក់ដែលមិនមែនជាគ្រោះថ្នាក់ការងារ ហើយទៅទទួលការសម្រាកព្យាបាលនៅតាមបណ្តាមូលដ្ឋានសុខាភិបាលខាងលើ ដោយឥតបង់ប្រាក់ ហើយទុកឱ្យមូលដ្ឋានសុខាភិបាលទាំងនោះទូទាត់ជាមួយ ប.ស.ស ដែលករណីនេះ ជនរងគ្រោះត្រូវទូទាត់សងមក ប.ស.ស វិញតាមចំនួនជាក់ស្តែង។

សម្រាប់ឆ្នាំ២០១៥ នេះ ប.ស.ស បានទទួលប្រាក់សំណងមិនមែនគ្រោះថ្នាក់ការងារចំនួន ០៧ នាក់ មានទឹកប្រាក់ចំនួន *២.៨២០.៥០០* រៀល ។

### ៣.៦. ការខារវាយតម្លៃកម្រិតបាត់បង់សមត្ថភាពអចិន្ត្រៃយ៍

គណៈកម្មការវេជ្ជសាស្ត្រ បានអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនប្រកបដោយតម្លាភាព, យុត្តិធម៌មនសិការវិជ្ជាជីវៈ និងកសាងបានជំនឿទុកចិត្តពីសំណាក់មជ្ឈដ្ឋានទូទៅ និងសមាជិករបស់ ប.ស.ស ជាពិសេសពីនិយោជកជាម្ចាស់សហគ្រាស គ្រឹះស្ថាន មកលើការអនុវត្តរបស់ ប.ស.ស តាមរយៈការចូលរួមបង់ភាគទានធានារ៉ាប់រងហានិភ័យការងារជូនកម្មករនិយោជិត ហើយវាក៏បានជំរុញឱ្យពួកគេផ្តល់ព័ត៌មានពិតពីចំនួនកម្មករនិយោជិត និងពីចំនួនប្រាក់ខែរបស់ពួកគេ ដើម្បីជៀសវាងការបាត់បង់អត្ថប្រយោជន៍ដែលមានចែងនៅក្នុងច្បាប់។

នៅក្នុងឆ្នាំ២០១៥ គណៈកម្មការវេជ្ជសាស្ត្រ បានបើកកិច្ចប្រជុំ ចំនួន ១៣ លើក វាយតម្លៃកម្រិតបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ជូនជនរងគ្រោះ ចំនួន ៧៨ នាក់ ក្នុងនោះរួមមាន៖

- កម្រិតបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍តិចជាង ២០ភាគរយ ចំនួន ៣១ នាក់ (ស្រី ១៦ នាក់)។
- កម្រិតបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ចាប់ពី ២០ ភាគរយ ឡើងទៅមានចំនួន ៤៦ នាក់ (ស្រី១៥ នាក់) ក្នុងនោះផ្តល់តាវកាលិកអ្នកចាំថែរក្សា ដល់ជនរងគ្រោះចំនួន ០២ នាក់ (ភេទប្រុស) និងផ្តល់សេវាបុនីតិសម្បទាឡើងវិញដល់ជនរងគ្រោះចំនួន ០១ នាក់ (ភេទប្រុស)។
- បដិសេធមូលហេតុបណ្តាលឱ្យកើតជំងឺមហារីកមិនមែនមកពីគ្រោះថ្នាក់ប៉ះទង្គិចជើងជាមួយនិងតុនោះទេ ចំនួន ០១ នាក់ ភេទប្រុស។

## ៤. ការងារគ្រប់គ្រង និងបណ្តុះបណ្តាលធនធានមនុស្ស

### ៤.១. ការងាររដ្ឋបាល និងហិរញ្ញវត្ថុ

#### ៤.១.១. ការងាររដ្ឋបាល

ការងាររដ្ឋបាល មានតួនាទីយ៉ាងសំខាន់នៅក្នុងការគ្រប់គ្រងឯកសារ ការផ្គត់ផ្គង់ និងការគ្រប់គ្រងមន្ត្រី បុគ្គលិក ដើម្បីធានាបាននូវការអនុវត្តបទបញ្ជាផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព និងស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា និងធានាបាននូវប្រសិទ្ធភាពការងារខ្ពស់។

នៅឆ្នាំ២០១៥ កន្លងមកនេះ រដ្ឋបាលរបស់បេឡាជាតិរបបសន្តិសុខសង្គមសម្រេចបាន៖

- បង់ប្រាក់ភាគទានហានិភ័យការងារសម្រាប់បុគ្គលិកជាប់កិច្ចសន្យា។
- រៀបចំបន្តកិច្ចសន្យាសម្រាប់បុគ្គលិកជាប់កិច្ចសន្យា។
- រៀបចំប្រាក់បំណាច់លើកទឹកចិត្ត និង បៀវត្សសម្រាប់មន្ត្រី និងបុគ្គលិកជាប់កិច្ចសន្យា ។
- រៀបចំប្រជុំវាយតម្លៃមន្ត្រីរាជការស្នើសុំគ្រឿងឥស្សរិយស សម្រាប់ឆ្នាំ២០១៥។
- ដំឡើងប្រាក់កម្រៃលើកទឹកចិត្តជូនមន្ត្រីរាជការ ចំនួន០៨ រូប, កែតម្រូវប្រាក់កម្រៃលើកទឹកចិត្តក្នុងខែតុលា សម្រាប់មន្ត្រី ចំនួន១២ រូប ដែលបានផ្ទេរកន្លែងធ្វើការងារមក ប.ស.ស។
- ដំឡើងកម្រិតមុខងារ ជូនមន្ត្រីថ្នាក់ការិយាល័យ ចំនួន១០រូប និងបញ្ចូលឈ្មោះមន្ត្រីរាជការចំនួន០៨ រូប ទៅក្នុងតារាងប្រាក់កម្រៃលើកទឹកចិត្តរបស់ ប.ស.ស។
- រៀបចំវាយតម្លៃបុគ្គលិកជាប់កិច្ចសន្យាចំនួន ១៣១រូប។
- ដំឡើងថ្នាក់ ជូនបុគ្គលិកជាប់កិច្ចសន្យាការងារ ចំនួន៦៨រូប ដែលបានបម្រើការងារអស់រយៈពេល០២ ឆ្នាំ ប្រចាំ ប.ស.ស និងចំនួន២៧រូប ដាក់បន្តកិច្ចសន្យាថ្មីរយៈពេល០១ ឆ្នាំ។
- បង្កើតគណៈកម្មការវិន័យ ដើម្បីចាត់វិធានការលើមន្ត្រី និងបុគ្គលិកដែលបានឈប់សម្រាកលើសចំនួនថ្ងៃឈប់សម្រាកសម្រាប់ឆ្នាំ២០១៤។
- ប្រឡងជ្រើសរើសបុគ្គលិកថ្នាក់កណ្តាលចំនួន ១០១ រូប និងតាមបណ្តាខេត្តចំនួន ២៧ រូប។
- បញ្ចូលបុគ្គលិកសាកល្បងការងារឱ្យពេញសិទ្ធិ ចំនួន ៤៤ រូប នៅស្នាក់ការកណ្តាល និងចំនួន០៩រូប នៅតាមសាខាខេត្ត ដាក់ឱ្យពេញសិទ្ធិជាបុគ្គលិកជាប់កិច្ចសន្យា។

- គ្រប់គ្រងទិន្នន័យតាមរយៈការស្កេនម្រាមដៃ ត្រួតពិនិត្យ និងធ្វើរបាយការណ៍រៀងរាល់សប្តាហ៍ពីចំនួនមន្ត្រីអវត្តមាន និងមិនគោរពពេលវេលាចេញ-ចូល។
- កត់ត្រា និងរក្សាទុកលិខិតសុំអនុញ្ញាតច្បាប់ ដើម្បីផ្ទៀងផ្ទាត់ជាមួយទិន្នន័យ បញ្ជីវត្តមាននៃមន្ត្រី បុគ្គលិកទាំងអស់។
- ត្រួតពិនិត្យ ធ្វើរបាយការណ៍អវត្តមាន និងការមិនគោរពពេលវេលាចេញ-ចូល របស់មន្ត្រីបុគ្គលិករៀងរាល់សប្តាហ៍ និងប្រចាំខែ។
- រៀបចំឯកសារលំហែមាតុភាពជូនមន្ត្រី និងបុគ្គលិកចំនួន២២នាក់។
- បង់ពន្ធលើមធ្យោបាយដឹកជញ្ជូនសម្រាប់ឆ្នាំ២០១៥
- ទូទាត់ថ្លៃជួលអគារ និងថ្លៃប្រើប្រាស់ទឹកភ្លើងនៅសាខាខណ្ឌ/ខេត្ត

### ៤.១.២. ការងារហិរញ្ញវត្ថុ

ការងារគណនេយ្យ និង ហិរញ្ញវត្ថុរបស់ ប.ស.ស ប្រតិបត្តិការតាមរយៈប្រព័ន្ធធនាគារទាំងស្រុងពោលគឺរាល់កិច្ចដំណើរការនៃការគ្រប់គ្រងចំណូល និង ចំណាយ មានជាអាទិ៍ ការប្រមូលភាគទានពីសហគ្រាស គ្រឹះស្ថាន, ការបង់ប្រាក់ពិន័យ, ការចំណាយតាវកាលិកដល់កម្មករនិយោជិតដែលរងហានិភ័យការងារ និងការចំណាយរដ្ឋបាល ត្រូវបានប្រព្រឹត្តទៅដោយឆ្លងកាត់តាមប្រព័ន្ធធនាគារ។ ក្នុងគោលដៅធានាពីប្រសិទ្ធភាព និងគណនេយ្យភាព ក្នុងដំណើរការនៃកិច្ចប្រតិបត្តិការ ប.ស.ស បានអនុវត្តនូវការងារសំខាន់ៗ មួយចំនួនដូចខាងក្រោម ៖

- ធ្វើផែនការចំណូលចំណាយសម្រាប់អនុវត្តនៅឆ្នាំ២០១៦ ។
- កត់ត្រាចំណូលភាគទានប្រចាំខែ ដែលបានមកពីការបង់ភាគទានរបស់សហគ្រាស គ្រឹះស្ថាន។
- កត់ត្រាចំណាយប្រចាំខែ សម្រាប់ថ្លៃព្យាបាលនៅតាមមន្ទីរពេទ្យនីមួយៗ និងតាវកាលិកធនលាភរបស់សមាជិក ប.ស.ស ។
- រៀបចំរបាយការណ៍ចំណូល-ចំណាយសាច់ប្រាក់លម្អិតប្រចាំខែក្នុងឆ្នាំ២០១៥។
- ត្រួតពិនិត្យចំណាយផ្សេងៗដូចជា ចំណាយបេសកកម្ម ចំណាយរដ្ឋបាល ចំណាយបង្ការហានិភ័យការងារ និងចំណាយតាវកាលិក។
- ធ្វើសេចក្តីជូនដំណឹងពីអត្រាប្តូរប្រាក់សម្រាប់ការបង់ភាគទានប្រចាំខែនីមួយៗ។
- បង់ពន្ធលើប្រាក់បៀវត្ស និង ប្រាក់កំរ៉ៃលើកទឹកចិត្តប្រចាំខែនីមួយៗ។
- រៀបចំបញ្ជីបើកប្រាក់បៀវត្សប្រចាំខែនីមួយៗ ។
- ផ្ទៀងផ្ទាត់របាយការណ៍ធនាគារជាមួយសៀវភៅបេឡា ។
- សហការជាមួយប្រតិភូមកពីនាយកដ្ឋានទ្រព្យរដ្ឋ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រួតពិនិត្យការបិទបញ្ជីចំណូល-ចំណាយ និងបញ្ជីសារពើភ័ណ្ឌឆ្នាំ២០១៤ ។

## ៤.២. កិច្ចសហប្រតិបត្តិការ និងការងារបណ្តុះបណ្តាលធនធានមនុស្ស

កិច្ចសហប្រតិបត្តិការ និងការបណ្តុះបណ្តាលធនធានមនុស្ស ជាការងារមួយសំខាន់នៅក្នុងការអភិវឌ្ឍន៍អង្គភាព និងពង្រឹងនូវកិច្ចសហប្រតិបត្តិការរវាងផ្នែកដែលពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានាទាំងនៅ

ក្នុងប្រទេស និងក្រៅប្រទេស ដើម្បីធានានូវនិរន្តរភាពនៃកិច្ចដំណើរការរបស់អង្គភាព លើការរៀបចំផែនការ បែបបទ និងនីតិវិធីការងារ ក៏ដូចជាការអភិវឌ្ឍន៍នូវចំណេះដឹង ការដកស្រង់ និងផ្លាស់ប្តូរបទពិសោធន៍ការងារថ្មីៗ។ កិច្ចសហប្រតិបត្តិការ និងការងារបណ្តុះបណ្តាលធនធានមនុស្ស ក៏ជាការចូលរួមចំណែកនៅក្នុងសកម្មភាពការងារសង្គមទាំងមូលឱ្យមានការរីកចម្រើនផងដែរ ដែលថ្នាក់ដឹកនាំ ក៏ដូចជាមន្ត្រី ប.ស.ស បានចូលរួមកិច្ចប្រជុំពិភាក្សាផ្តល់យោបល់ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាទាំងនៅក្នុងប្រទេស និងក្រៅប្រទេស ដូចខាងក្រោម៖

### ៤.២.១. ការងារក្នុងប្រទេស

កិច្ចសហប្រតិបត្តិការ និងការបណ្តុះបណ្តាលធនធានមនុស្សនៅក្នុងប្រទេស ប.ស.ស បានរៀបចំឱ្យមានវគ្គបណ្តុះបណ្តាល និងធ្វើបច្ចុប្បន្នភាពការងារផ្ទៃក្នុងដល់មន្ត្រី និងបុគ្គលិកជាប្រចាំរៀងរាល់ឆ្នាំ។

ក្រៅពីនេះថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក នៃ ប.ស.ស ក៏បានចូលរួមនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ ពិភាក្សាការងារ ការរៀបចំផែនការអភិវឌ្ឍន៍ និងសិក្ខាសាលាបណ្តុះបណ្តាលលើកកម្ពស់ការយល់ដឹងតាមបណ្តាក្រសួង អង្គការ និងស្ថាប័នពាក់ព័ន្ធនានានៅទូទាំងប្រទេសបានជាច្រើនលើករួមមាន៖

- ចូលរួមកិច្ចប្រជុំអបអរសាទរក្រោមអធិបតីភាព ឯកឧត្តមរដ្ឋមន្ត្រី ដែល ប.ស.ស ទទួលបានជាអង្គភាពឆ្នើមផ្នែកនវានុវត្តន៍ ពីសមាគមន៍សន្តិសុខសង្គមអាស៊ាន។

*រូបភាពទី៣. អបអរសាទរ ការទទួលបានវិញ្ញាបនបត្រអង្គភាពឆ្នើមផ្នែកនវានុវត្តន៍ ពីសមាគមនសន្តិសុខសង្គមអាស៊ាន (ASSA) ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥*




- ចូលរួមប្រជុំស្តីពី ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦។
- រៀបចំ និងចូលរួមប្រជុំបូកសរុបលទ្ធផលការងាររបស់ ប.ស.ស ឆ្នាំ២០១៤ និងទិសដៅអនុវត្តបន្តឆ្នាំ២០១៥ នៅសណ្ឋាគារភ្នំពេញ។
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី Intermediate English Language and Communication Skills(I)។
- ចូលរួមប្រជុំពិភាក្សាលើផែនការយុទ្ធសាស្ត្រថវិកាដែលបានស្នើ និងពិនិត្យលើការរៀបចំគម្រោងចំណូល-ចំណាយថវិកាឆ្នាំ២០១៦ កម្រិតបច្ចេកទេស។

- ចូលរួមសិក្ខាសាលាកសាងសមត្ថភាព និងអភិវឌ្ឍន៍ផែនការសកម្មភាពស្តីពីកម្មវិធីការងារសមរម្យ សម្រាប់កម្ពុជា ២០១៦-២០១៨។
- ចូលរួមប្រជុំស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការងារ សម្រាប់ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម។
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ការធ្វើបច្ចុប្បន្នភាពកម្មវិធីការងារសមរម្យសម្រាប់កម្ពុជា ២០១១-២០១៥។
- ចូលរួមសិក្ខាសាលាស្តីពីកិច្ចការរដ្ឋបាល ហិរញ្ញវត្ថុ និងផែនការ។
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី។
- ចូលរួមសិក្ខាសាលាត្រីភាគីថ្នាក់ជាតិស្តីពីប្រាក់ឈ្នួលអប្បរមានៅកម្ពុជា។
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ការធ្វើបច្ចុប្បន្នភាពកម្មវិធីការងារសមរម្យសម្រាប់កម្ពុជា ២០១១-២០១៥។
- ចូលរួមសិក្ខាសាលាស្តីពីការផ្សព្វផ្សាយខ្លឹមសារ នៃព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល។
- ចូលរួមសិក្ខាសាលាស្តីពី ការសម្របសម្រួលការផ្លាស់ប្តូរពីសេដ្ឋកិច្ចក្រៅប្រព័ន្ធទៅសេដ្ឋកិច្ចក្នុងប្រព័ន្ធ ដោយផ្តោតលើតួនាទីរបស់សហជីព។
- ចូលរួមប្រជុំសាមញ្ញ ពិនិត្យខ្លឹមសារឯកសារដែលជាអនុសាសន៍របស់ឯកឧត្តមរដ្ឋមន្ត្រី។
- ចូលរួមសិក្ខាសាលាស្តីពី ហិរញ្ញប្បទានសុខាភិបាល និងការគាំពារសុខភាពសង្គមសម្រាប់មនុស្សចាស់ជរា ជនពិការ និងអ្នកមានជំងឺមិនឆ្លង។
- ចូលរួមសិក្ខាសាលាថ្នាក់ជាតិស្តីអំពី ការចែករំលែកបទពិសោធន៍អំពីការអភិវឌ្ឍន៍ធនធានមនុស្ស ដើម្បីការងារសមរម្យ និងការងារសង្គមនៃប្រទេសតណ្ហូនេស៊ី។
- ចូលរួមប្រជុំពាក់ព័ន្ធ និងការត្រៀមរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៤ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០១៥។
- ចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីអបអរសាទរខួបលើកទី ១២៩ ទិវាពលកម្មអន្តរជាតិ ០១ ឧសភា ឆ្នាំ២០១៥។
- ចូលរួមសិក្ខាសាលាត្រីភាគីស្តីពីការត្រួតពិនិត្យប្រចាំឆ្នាំ លើកម្មវិធីការងារសមរម្យសម្រាប់ប្រទេសកម្ពុជា (DWCP) (២០១១-២០១៥)។

ក្រៅពីការងារខាងលើ ប.ស.ស ក៏បានចាត់បញ្ជូនមន្ត្រី និងបុគ្គលិកឱ្យចូលរួមនៅក្នុងសកម្មភាពការងារសង្គមមួយចំនួនទៀតផងដែរ ដើម្បីចូលរួមចំណែកនៅក្នុងការអភិវឌ្ឍន៍សង្គមជាតិទាំងមូល។

### ៤.២.២ ការងារក្រៅប្រទេស

ក្រៅពីការងារលើកកម្ពស់ធនធានមនុស្ស និងកិច្ចសហប្រតិបត្តិការក្នុងប្រទេស ការទំនាក់ទំនងក្រៅប្រទេសជាការងារមួយដ៏សំខាន់ នៅក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍បរទេសនានា និងការធ្វើសមាហរណកម្មវិស័យសន្តិសុខសង្គមរបស់កម្ពុជាទៅក្នុងតំបន់ ដើម្បីឱ្យមានការផ្លាស់ប្តូរនូវបទពិសោធន៍ បច្ចេកទេសការងារថ្មីៗ យកមកធ្វើការអភិវឌ្ឍន៍នៅក្នុងប្រទេស។ នៅឆ្នាំ២០១៥

នេះ ប.ស.ស បានបំពេញនូវការងារក្រៅប្រទេសសំខាន់ៗមួយចំនួន សម្រាប់វិស័យសន្តិសុខសង្គម ដូចខាងក្រោម៖

- ចូលរួមកិច្ចប្រជុំសមាគមន៍សន្តិសុខសង្គមអាស៊ាន(ASSA) លើកទី៣២ក្រោមប្រធានបទបញ្ហានៃភាពកាន់តែមានវ័យចាស់នៃប្រជាពលរដ្ឋ ដែលរបបសន្តិសុខសង្គមទាំងឡាយត្រូវប្រឈម ហើយត្រូវបានអង្គភាពនេះ ទទួលស្គាល់ជាអង្គភាពឆ្នើមផ្នែកនវានុវត្តន៍ (សឹង្ហបុរី)។

*រូបភាពទី៤. ការទទួលបានវិញ្ញាបនបត្រអង្គភាពឆ្នើមផ្នែកនវានុវត្តន៍ ពីប្រធានសមាគមនសន្តិសុខសង្គមអាស៊ាន (ASSA) នៅប្រទេសសិង្ហបុរី*




- ចូលរួមសិក្ខាសាលាស្តីពី កំណែទម្រង់សន្តិសុខសង្គម ការផ្តល់តាវកាលិកសមស្របសម្រាប់ជនគ្រប់រូប និងការសម្របទៅតាមនិន្នាការចំបងនៃការងារ(ឥណ្ឌូនេស៊ី)។
- ចូលរួមក្នុងកិច្ចសន្ទនាសង្គមនៃកិច្ចប្រជុំអាស៊ី-អឺរ៉ុប(ឥណ្ឌូនេស៊ី)។
- ចូលរួមសិក្ខាសាលាស្តីពីសន្តិសុខសង្គម(ឥណ្ឌូនេស៊ី)។
- ចូលរួមសន្និសិទស្តីពី ការវាស់ស្ទង់ និងសម្រេចឱ្យបានការគ្របដណ្តប់សេវាសុខាភិបាលជាសកលក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក និងកិច្ចប្រជុំប្រព័ន្ធព័ត៌មានសុខភាពអេឡិចត្រូនិចអាស៊ីលើកទីបួន(ឥណ្ឌូនេស៊ី)។
- ចូលរួមសិក្ខាសាលាស្តីពីការធានារ៉ាប់រងការងារ សម្រាប់សមាគមន៍អាស៊ាន ការសិក្សាស្វែងយល់បទពិសោធន៍ពីសាធារណរដ្ឋកូរ៉េ លើប្រតិបត្តិការរបបធានារ៉ាប់រងនិកម្មវេលាសារភ្ជាប់ជាមួយសេវាកម្មការងារ(សាធារណរដ្ឋកូរ៉េ)។
- ចូលរួមសិក្ខាសាលាត្រីភាគីក្នុងការធ្វើឱ្យប្រសើរឡើងនៃកិច្ចគាំពារសង្គមក្នុងការធ្វើសមាហរណ-កម្មបញ្ចូលទៅក្នុងសហគមន៍អាស៊ាន(ឥណ្ឌូនេស៊ី)។
- ចូលរួមសិក្ខាសាលាស្តីពីកិច្ចគាំពារសង្គមអន្តរជាតិឆ្នាំ២០១៦(វៀតណាម)។
- ចូលរួមសិក្ខាសាលាស្តីពី ការវិនិយោគនៃបេឡាជាតិរបបសន្តិសុខសង្គម(ម៉ាឡេស៊ី)។
- ចូលរួមសិក្ខាសាលាស្តីពី ការវាស់ស្ទង់ និងសម្រេចឱ្យបាននូវការគ្របដណ្តប់ជាសកលសេវាសុខាភិបាលតាមរយៈបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនង (ICT) ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក (ហ្វីលីពីន)។
- ចូលរួមសិក្ខាសាលាស្តីពី ទំនួលខុសត្រូវផ្នែកសង្គមជុំវិញពិភពលោក (បង់ក្លាដេស)។

- ចូលរួមសិក្ខាសាលាស្តីពី ការរៀបចំ និងការពង្រីកបន្ថែមលើវិស័យសោធននិវត្តជាសកល (ថៃ)។
- ចូលរួមសិក្ខាសាលាស្តីពី គោលនយោបាយសោធននិវត្តន៍ ច្បាប់ និងប្រព័ន្ធព័ត៌មានវិទ្យារបស់ប្រទេសជប៉ុន (ជប៉ុន)។
- ចូលរួមសិក្ខាសាលាស្តីពី កិច្ចគាំពារសង្គម និងការផ្សព្វផ្សាយសិទ្ធិរបស់កម្មករទេសន្តប្រវេសន៍ (ហ្វីលីពីន)។
- ចូលរួមសិក្ខាសាលាស្តីពី ការផ្តល់សេវាបុននីតិសម្បទា (ថៃ)។
- ចូលរួមសិក្ខាសាលាស្តីពី សន្តិសុខសង្គមអន្តរជាតិ ឆ្នាំ២០១៥ (ម៉ាឡេស៊ី)។
- ចូលរួមសិក្ខាសាលាស្តីពី ការពង្រឹងសមត្ថភាពលើវិជ្ជាជីវៈនៃការសហការគ្នា(ថៃ)។
- ចូលរួមសិក្ខាសាលាស្តីពី កិច្ចគាំពារសង្គម និងវិភាគទៅលើកញ្ចប់ថវិការយ៉េនឪរសម្រាប់រដ្ឋជាសមាជិកអាស៊ាន(ហ្វីលីពីន)។

## ៤.៣. ការងារព័ត៌មានវិទ្យា

ប.ស.ស បានរៀបចំកិច្ចប្រតិបត្តិការងារ និងការគ្រប់គ្រងទិន្នន័យតាមរយៈបច្ចេកវិទ្យាព័ត៌មានវិទ្យាលើការងារចុះបញ្ជិកា, បង់ភាគទាន, ការផ្តល់តាវកាលិក, ការគ្រប់គ្រងវត្តមានមន្ត្រី និងការងារសំខាន់ៗមួយចំនួនទៀត ជាក់ស្តែងនៅឆ្នាំ២០១៥ ប.ស.ស សម្រេចបានលើការងារព័ត៌មានវិទ្យា ដូចខាងក្រោម៖

- ធ្វើបច្ចុប្បន្នភាព និងអភិវឌ្ឍកម្មវិធីសម្រាប់បញ្ជិកា និងភាគទាន។
- ដំឡើងកម្មវិធីស្វែងរកព័ត៌មានកម្មករនិយោជិតតាមរយៈទូស័ព្ទចល័ត(Smart Phone)
- សិក្សាបន្ថែមលើការប្រើប្រាស់ iOS Mobile Application តាមរយៈ Internet ដើម្បីបង្កើតកម្មវិធីសម្រាប់ ប.ស.ស ដែលអាចដំណើរការលើទូរស័ព្ទចល័ត iPhone និង iPad។
- ធ្វើបច្ចុប្បន្នភាពកម្មវិធីវត្តមាន (NSSF Attendant) ដោយកែសម្រួលទម្រង់បញ្ចូលទិន្នន័យព័ត៌មានគណនីធនាគាររបស់មន្ត្រី បុគ្គលិក និងកែសម្រួលទម្រង់បោះពុម្ពលិខិតផ្ទេរប្រាក់សម្រាប់ទូទាត់ចំណាយបេសកកម្ម។
- កម្មវិធីបញ្ជូនទិន្នន័យ និងទាញទិន្នន័យអេស៊ីលីដាយូនីធី ដោយបន្ថែមនូវដំណើរការធ្វើបច្ចុប្បន្នភាពប្រវត្តិការងាររបស់កម្មករនិយោជិត ដំណើរការបញ្ចូលសហគ្រាសដែលត្រូវជាប់ភាគទានប្រចាំខែ និងដំណើការធ្វើបច្ចុប្បន្នភាពប្រវត្តិសហគ្រាសបិទ ផ្អាក ឬដំណើរការដើម្បីសម្រួលដល់ការធ្វើរបាយការណ៍ក្នុងប្រព័ន្ធ។
- កម្មវិធីរដ្ឋបាល (NSSF Administration) ដោយបង្កើតទម្រង់បញ្ចូលទិន្នន័យព័ត៌មានថែមម៉ោង, បង្កើតទម្រង់បញ្ចូលទិន្នន័យគណនាប្រាក់ថែមម៉ោង, បង្កើតទម្រង់បង្ហាញរបាយការណ៍និងគំរូបោះពុម្ពរបាយការណ៍ថែមម៉ោង, កែសម្រួលទម្រង់បញ្ចូលទិន្នន័យបញ្ជាបេសកកម្ម, ធ្វើបច្ចុប្បន្នភាពទម្រង់គណនាប្រាក់បៀវត្សជូនមន្ត្រី និងបុគ្គលិក។
- កម្មវិធីកំណត់អត្តសញ្ញាណសមាជិក ប.ស.ស (NSSF DBMS Local)

- ធ្វើបច្ចុប្បន្នភាព និងអភិវឌ្ឍកម្មវិធីសម្រាប់ការផ្ដល់តាវកាលិក និងកម្មវិធីទាមទារសំណង វេជ្ជសាស្ត្រពីជនរងគ្រោះ។
- ទាញទិន្នន័យពីប្រព័ន្ធចុះបញ្ជិកា និងភាគទានចាស់ ទៅកាន់ប្រព័ន្ធចុះបញ្ជិកា និងភាគទានថ្មី ដើម្បីដាក់ឱ្យដំណើរការកម្មវិធីចុះបញ្ជិកា និងភាគទានថ្មី។
- ដំឡើង Database Failover Clustering។
- បញ្ចូលឈ្មោះអ្នកដោះស្រាយ និងបង្កើតឈ្មោះអ្នកប្រើកម្មវិធី Complaint System។
- កម្មវិធី NSSF Program ដោយធ្វើបច្ចុប្បន្នភាពទម្រង់បំលែងពី E-Form ចាស់ ទៅ E-Form ថ្មីដោយបង្ហាញឈ្មោះនិយោជិតមិនមានដកឃ្លា និងបន្ថែមការបំលែងទៅលើជួរឈរនៃតួនាទី និងក្រុមរបស់និយោជិត។
- ដំឡើងប្រព័ន្ធកាម៉េរាសុវត្ថិភាពនៅសាខា ប.ស.ស ខេត្ត-ខណ្ឌទាំងអស់។
- ដំឡើងឧបករណ៍ Finger Print នៅសាខា ប.ស.ស ខេត្ត-ខណ្ឌទាំងអស់។
- ដំឡើងប្រព័ន្ធតាមដានត្រួតពិនិត្យ (Link) នៅស្នាក់ការកណ្ដាលដែលបាន តភ្ជាប់មកពីគ្រប់សាខា ប.ស.ស ខេត្ត-ខណ្ឌ។
- រចនាគេហទំព័រថ្មី និង បញ្ចូលអត្រាប្តូរប្រាក់ប្រចាំខែ ព្រឹត្តិបត្រព័ត៌មាន សេចក្ដីជូនដំណឹង និងព័ត៌មានមួយចំនួនទៀតលើគេហទំព័រ។

### ៤.៤. ការងារសវនកម្មផ្ទៃក្នុង

ការពង្រឹងលើការអនុវត្តភារកិច្ចរបស់សវនករ ដោយធ្វើសវនកម្មទៅតាមប្រភេទសវនកម្មមានជាអាទិ៍ សវនកម្មលើ អនុលោមភាព សវនកម្មលើហិរញ្ញវត្ថុ សវនកម្មលើប្រតិបត្តិការ ដើម្បីជួយស្វែងរកនូវចំណុចអវិជ្ជមាន ហើយផ្ដល់អនុសាសន៍ និងរាយការណ៍ជូននាយកគ្រឹះស្ថាន និងអាជ្ញាធរសវនកម្មជាតិ ដែលមានការចង្អុលដោយអនុក្រឹត្យ។ ក្នុងនោះការិយាល័យសវនកម្ម បានដាក់ចេញនូវសកម្មភាពចំនួន ៤គឺៈ

១. សវនកម្មអង្គភាពចំណុះផ្ទាល់ ប.ស.ស នៅថ្នាក់កណ្ដាល

២. សវនកម្មអង្គភាពប្រើប្រាស់ថវិកា ប.ស.ស

៣. សវនកម្មអង្គភាពចំណុះផ្ទាល់ ប.ស.ស ការិយាល័យ ប.ស.ស សាខាខេត្ត

៤. សវនកម្មតាមសំណើ(ឥតគ្រោងទុក)។

## ៥. ការងារៀបចំបុនរនីតិសម្បទា

អនុលោមតាមច្បាប់ស្ដីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ, អនុក្រឹត្យស្ដីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម និងប្រកាសស្ដីពីតាវកាលិកហានិភ័យការងារ កម្មករនិយោជិតដែលទទួលរងហានិភ័យការងារ បណ្ដាលឱ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍មានសិទ្ធិទទួលបានសេវាបុនរនីតិសម្បទា (ស្តារលទ្ធភាពពលកម្ម) រួមមានការផ្ដល់នូវឧបករណ៍ ឬ អវៈយវៈសិប្បនិម្មិតតាមការកំណត់របស់គ្រូពេទ្យផ្លូវការ ឬគ្រូពេទ្យដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម ព្រមទាំងសេវាសម្របសម្រួលមុខងារ និងការបណ្ដុះបណ្ដាលវិជ្ជាជីវៈឡើងវិញ។

ចំពោះការផ្តល់សេវាខាងលើ កន្លងមក ប.ស.ស ពុំទាន់បានផ្តល់ឱ្យបានពេញលេញនៅឡើយទេ ការផ្តល់សេវាមួយចំនួនភាគច្រើនជាសេវាស្តារលទ្ធភាពពលកម្មផ្នែកវេជ្ជសាស្ត្រ ដែលរួមមានការផ្តល់ឧបករណ៍ ឬអវៈយវៈសិប្បនិម្មិត និងការព្យាបាលដោយចលនាតែប៉ុណ្ណោះ។ ដោយឡែកការផ្តល់សេវាស្តារលទ្ធភាពពលកម្មផ្នែកវេជ្ជសាស្ត្រមួយចំនួនទៀត, ការបណ្តុះបណ្តាលវិជ្ជាជីវៈនិងការងារ និងសេវាសង្គមផ្សេងទៀតមិនទាន់បានផ្តល់នៅឡើយទេ។

ទន្ទឹមនឹងការផ្តល់សេវាខាងលើ ដើម្បីរៀបចំការផ្តល់សេវានេះឱ្យបានពេញលេញ ប.ស.ស ក៏បានសិក្សាស្រាវជ្រាវ និងបង្កើតក្រុមការងារ ដើម្បីរៀបចំយន្តការផ្តល់សេវាបុននីតិសម្បទា ។ តាមរយៈការយកចិត្តទុកដាក់នេះ នៅឆ្នាំ២០១២ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិអាល្លឺម៉ង់ (GIZ) បានផ្តល់ជំនាញការផ្នែកស្តារលទ្ធភាពពលកម្ម មកជួយរៀបចំបែបបទ និងនីតិវិធីការងាររយៈពេលពីរសប្តាហ៍ចាប់ពីថ្ងៃទី ២០-៣១ ខែសីហា។ ក្នុងរយៈពេលនោះក្រុមការងារបានចុះធ្វើទស្សនៈកិច្ចសិក្សានៅមជ្ឈមណ្ឌល និងអង្គភាពមួយចំនួនដែលមានការងារទាក់ទងនឹងការផ្តល់សេវាស្តារលទ្ធភាពពលកម្ម រួមមាននាយកដ្ឋានសុខមាលភាពជនពិការ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, មូលនិធិជនពិការ, វិទ្យាស្ថានជាតិសង្គមកិច្ច, មជ្ឈមណ្ឌលជាតិស្តានីតិសម្បទាជនពិការគៀនឃ្លាំង និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការភ្នំពេញថ្មី (ដែលបច្ចុប្បន្នជាមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមពោធិ៍សែនជ័យ)។ បន្ថែមពីលើនេះទៀត ប.ស.ស ក៏បានបញ្ជូនមន្ត្រីទៅចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាអន្តរជាតិបានមួយចំនួនផងដែរទាក់ទងនឹងប្រធានបទ នៃការស្តារលទ្ធភាពពលកម្មនេះ។ ជាបន្តបន្ទាប់រហូតមកដល់ឆ្នាំ២០១៥ មន្ត្រីជំនាញចំនួន ០៤ រូប ដឹកនាំដោយ **លោក អ៊ុក សមវិទ្យា** នាយកបេឡាជាតិរបបសន្តិសុខសង្គម បានទៅធ្វើទស្សនៈកិច្ចសិក្សានៅអង្គភាពសន្តិសុខសង្គម នៃព្រះរាជាណាចក្រថៃ (SSO) និងមជ្ឈមណ្ឌលផ្តល់សេវាស្តារលទ្ធភាពពលកម្ម (IRC) ដើម្បីសិក្សា និងដកស្រង់បទពិសោធន៍ពីការគ្រប់គ្រងការផ្តល់សេវាបុននីតិសម្បទា សម្រាប់កម្មករនិយោជិតនៅក្នុងផ្នែកសន្តិសុខសង្គម។ តាមរយៈការធ្វើទស្សនៈកិច្ចសិក្សានេះផងដែរ និងគម្រោងរបស់សមាគមសន្តិសុខសង្គមអាស៊ាន (ASSA) នៅឆ្នាំ២០១៥ ដដែលមជ្ឈមណ្ឌលផ្តល់សេវាស្តារលទ្ធភាពពលកម្ម (IRC) របស់ថៃក៏បានផ្តល់នូវការបណ្តុះបណ្តាលផ្នែកស្តារលទ្ធភាពពលកម្មចំនួន ០២ សប្តាហ៍ដល់មន្ត្រីជំនាញ ប.ស.ស ចំនួន០១ រូប ព្រមទាំងសិក្ខាកាមមកពីបណ្តាប្រទេសអាស៊ានមួយចំនួនទៀត។

ជាលទ្ធផលនៃការរៀបចំ និងការសិក្សាស្រាវជ្រាវនេះ ប.ស.ស សម្រេចបានលើការបង្កើតនូវសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តិ បែបបទ និងនីតិវិធីការងារ ដើម្បីត្រៀមដាក់ឱ្យដំណើរការការផ្តល់សេវានេះឱ្យបានពេញលេញ នៅពេលវេលាសមស្របណាមួយបាន។

## ៦. ការងារប្រជុំផ្សព្វផ្សាយ និងបង្ការហានិភ័យការងារ

### ៦.១. ការងារប្រជុំផ្សព្វផ្សាយ

ការងារផ្សព្វផ្សាយជាការងារមួយដ៏សំខាន់ ដែល ប.ស.ស បានយកចិត្តទុកដាក់ខ្ពស់ ដោយក្នុងនោះបានរៀបចំនូវផែនការផ្សព្វផ្សាយសាធារណៈជាច្រើន ដើម្បីផ្សព្វផ្សាយពីលទ្ធផលសម្រេចបាន, ការងារបង្ការគ្រោះថ្នាក់ការងារ, ការអនុវត្តគោលនយោបាយថ្មីៗ ក៏ដូចជាការពង្រឹងការអនុវត្តបន្ថែមជាមួយផ្នែកពាក់ព័ន្ធរួមមាននិយោជក, តំណាងកម្មករនិយោជិត, អង្គការសហជីព, អង្គភាពផ្តល់សេវាសុខាភិបាល, អង្គការ

ក្រៅរដ្ឋាភិបាល និងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួនទៀត ដើម្បីឱ្យទទួលបានព័ត៌មានថ្មីៗពីការអនុវត្តគោលនយោបាយសន្តិសុខសង្គម និងឱ្យមានការចូលរួមទាំងអស់គ្នា។ ជាការគួរឱ្យកត់សំគាល់នៅក្នុងឆ្នាំ២០១៥ ការងារផ្សព្វផ្សាយមួយចំនួនត្រូវបានអនុវត្តដូចខាងក្រោម៖

- ប្រជុំបូកសរុបលទ្ធផលការងារសម្រេចបានឆ្នាំ២០១៤ និងលើកទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០១៥ របស់ ប.ស.ស នៅសណ្ឋាគារភ្នំពេញ។

*រូបភាពទី៥. កិច្ចប្រជុំបូកសរុបលទ្ធផលការងារសម្រេចបានឆ្នាំ២០១៤ និងទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០១៥ របស់ ប.ស.ស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (សណ្ឋាគារភ្នំពេញ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៥)*




- ប្រជុំផ្សព្វផ្សាយលទ្ធផលការងារសម្រេចបានឆ្នាំ២០១៤ និងទិសដៅអនុវត្តបន្តឆ្នាំ២០១៥ របស់ក្រុមការងារ ទ.ស.ប.ក និងក្រុមការងារ ស.ផ.ត។
- ប្រជុំផ្សព្វផ្សាយស្តីពីការអនុវត្តគោលនយោបាយថ្មីៗ និងសេវានៃការផ្តល់តាវកាលិកហានិភ័យការងារ។
- ប្រជុំផ្សព្វផ្សាយស្តីពីលក្ខខណ្ឌអនាម័យ, សុវត្ថិភាពការងារ, លក្ខខណ្ឌការងារ, អត្ថប្រយោជន៍របបសន្តិសុខសង្គម,វិធានការទប់ស្កាត់ករណីសន្លប់ និងមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត។
- ប្រជុំផ្សព្វផ្សាយស្តីពី ការផ្សព្វផ្សាយអំពីសុវត្ថិភាពចរាចរណ៍លើមធ្យោបាយដឹកជញ្ជូនដល់អ្នកបើកបរដឹកកម្មករ និងកម្មករនិយោជិត, វគ្គបណ្តុះបណ្តាល និងប្រឡងយកបណ្ណបើកបរ, វគ្គបណ្តុះបណ្តាលគ្រូបង្គោល។
- ផ្សព្វផ្សាយស្ព័តរូបភាពតាមស្ថានីយទូរទស្សន៍ និងស្ព័តសំលេងតាមវិទ្យុ។
- ប្រជុំពិគ្រោះយោបល់ត្រីភាគី ស្តីពីការផ្តល់តាវកាលិកផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិត។
- ធ្វើព្រឹត្តិប័ត្រ, ប្រតិទិន, ខិត្តប័ណ្ណ, សៀវភៅផ្សព្វផ្សាយ និងឯកសារចុះបញ្ជិកា សម្រាប់ផ្សព្វផ្សាយ។

ក្រៅពីការងារផ្សព្វផ្សាយខាងលើ ប.ស.ស ក៏មានគេហទំព័រ (www.nssf.gov.kh) ដែលផ្ទុកនូវរាល់ព័ត៌មាន និងឯកសារគតិយុត្តសំខាន់ៗ ទាក់ទងនឹងការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ព្រមទាំងមានបណ្តាញទំនាក់ទំនងសង្គម *(Page Facebook បេឡាជាតិរបបសន្តិសុខសង្គម www.facebook.com/nssfpage)*, ប្រព័ន្ធទូរស័ព្ទទំនាក់

ទំនងបន្ទាន់ Hot Line ១២៨៦ និង Call Center ដែលបានផ្សព្វផ្សាយនូវព័ត៌មានទាន់ហេតុការណ៍នានាទាក់ទងនឹងការអនុវត្តគោលនយោបាយរបបសន្តិសុខសង្គម និងអាចផ្តល់ព័ត៌មានផ្ទាល់ជាមួយនឹងសមាជិកភ្លាមៗ។ មួយវិញទៀត ប.ស.ស ក៏បានធ្វើការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀតជាច្រើនផងដែរ និងបានចាត់បញ្ជូនមន្ត្រីឱ្យចុះធ្វើការផ្សព្វផ្សាយ ពន្យល់ណែនាំដល់បណ្តាសហគ្រាស គ្រឹះស្ថានផ្ទាល់ ជាពិសេសការអនុវត្តគោលនយោបាយ ផ្នែកហានិភ័យការងារ ពីនីតិវិធី និងបែបបទនៃការចុះបញ្ជិកា, ការបង់ភាគទាន និងតាវកាលិក (អត្ថប្រយោជន៍) ដែលកម្មករនិយោជិតត្រូវទទួលបាន។

### ៦.១.១. ការពង្រឹងការផ្សព្វផ្សាយគោលនយោបាយថ្មីៗ

ការពង្រឹងការផ្សព្វផ្សាយគោលនយោបាយថ្មីៗ បានធ្វើការផ្សព្វផ្សាយស្តីពីគោលនយោបាយនៃការពង្រឹងសេវានៃការផ្តល់តាវកាលិកហានិភ័យការងារជូនកម្មករនិយោជិត ឆ្នាំ២០១៥ នេះ បានធ្វើការប្រជុំផ្សព្វផ្សាយជូនដល់តំណាងសហគ្រាស គ្រឹះស្ថាន ជនរងគ្រោះដែលជាសមាជិក ប.ស.ស តំណាងអង្គភាព មន្ទីរ អាជ្ញាធរមានសមត្ថកិច្ច មូលដ្ឋានផ្តល់សេវាសុខាភិបាល(ចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស) ព្រមទាំងជនរងគ្រោះទាំងអស់ដែលកំពុងទទួលបានតាវកាលិកហានិភ័យការងារពីប.ស.ស មកចូលរួមប្រជុំ។

តារាងទី៩. ផ្សព្វផ្សាយគោលនយោបាយថ្មីៗ

| បរិយាយ | ស្ថានភាពផ្សព្វផ្សាយ | | | អ្នកចូលរួមប្រជុំផ្សព្វផ្សាយ | |
|---|---|---|---|---|---|
| | លើក | សហគ្រាស/ជនរងគ្រោះ/អាជ្ញាធរ | រាជធានី-ខេត្ត | សរុប | ស្រី |
| ឆ្នាំ២០១៥ | 46 | 4,841 | 24 | 6,188 | 2,475 |
| ឆ្នាំ២០១៤ | 23 | 2,907 | 14 | 2,907 | 1,163 |
| ប្រៀបធៀប(%) | 100% | 67% | 71% | 113% | 113% |

ប្រភព៖ បេឡាជាតិរបបសន្តិសុខសង្គម ឆ្នាំ២០១៥

## ៦.២. ការងារប្រជុំផ្សព្វផ្សាយបង្ការហានិភ័យការងារ

### ៦.២.១. ក្រុមការងារ ទ.ស.ប.ក

ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ (ទ.ស.ប.ក) មានតួនាទីសិក្សាស្រាវជ្រាវរកមូលហេតុករណីសន្លប់របស់កម្មករនិយោជិតចាត់វិធានការសង្គ្រោះបន្ទាន់ និងសម្របសម្រួលជាមួយមន្ទីរពេទ្យ ជាមួយអាជ្ញាធរពាក់ព័ន្ធដើម្បីឱ្យជនរងគ្រោះទទួលបានការសង្គ្រោះបន្ទាន់ និងរៀបចំការផ្សព្វផ្សាយពីកម្មវិធីបង្ការគ្រោះថ្នាក់ការងារ។ ក្រុមការងារ ទ.ស.ប.ក បាននិងកំពុងរៀបចំកិច្ចប្រជុំផ្សព្វផ្សាយ អប់រំដូចភ្លៀងរលឹម ដើម្បីឱ្យនិយោជក តំណាងសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតទទួលបានការអប់រំស្តីពីលក្ខខណ្ឌការងារ, លក្ខខណ្ឌអនាម័យ, សុវត្ថិភាពការងារ, ការទប់ស្កាត់ករណីកម្មករនិយោជិតសន្លប់ និងបង្ការគ្រោះថ្នាក់ចរាចរណ៍ ដោយមធ្យោបាយធ្វើដំណើរកម្មករនិយោជិត ក្នុងន័យទប់ស្កាត់ និងបង្ការគ្រោះថ្នាក់ការងារ ពិសេសករណីកម្មករនិយោជិតសន្លប់ឱ្យស្ថិតនៅកម្រិតទាបបំផុត។ ជាការគួរឱ្យកត់សំគាល់សម្រាប់ឆ្នាំ២០១៥ ក្រុមការងារ បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអប់រំបានចំនួន ៩០ លើក មានរោងចក្រចំនួន ៩០ និងកម្មករនិយោជិតប្រមាណជា ១៣.៤៥០ នាក់ ។

*រូបភាពទី៦. ពិធីប្រជុំផ្សព្វផ្សាយអប់រំអំពី លក្ខខណ្ឌអនាម័យ, សុវត្ថិភាពការងារ, សុវត្ថិភាពចរាចរណ៍លើមធ្យោបាយដឹកជញ្ជូន និងអត្ថប្រយោជន៍របបសន្តិសុខសង្គម នៅក្រុមហ៊ុន 7NG GROUP Co., LTD (ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥)*



ក្នុងបាតុភាពករណីសន្លប់កម្មករនិយោជិតក្រុមការងារ ទ.ស.ប.ក ក៏បានចុះជួយសម្របសម្រួលចាត់វិធានការកែលំអ និងជួយសង្គ្រោះបន្ទាន់ នៅរោងចក្រចំនួន ៣២ និងមានកម្មករនិយោជិតចំនួន ១.៨០៦ នាក់ ដោយក្នុងនោះរួមមាន៖

- រាជធានីភ្នំពេញមាន ០៨ រោងចក្រ មានកម្មករសន្លប់សរុបចំនួន ៣៥៩ នាក់ ។
- ខេត្តកណ្តាលមាន ១៣ រោងចក្រ មានកម្មករសន្លប់សរុបចំនួន ៨០០ នាក់ ។
- ខេត្តកំពង់ស្ពឺមាន ០៥ រោងចក្រ មានកម្មករសន្លប់សរុបចំនួន ២៩៧ នាក់ ។
- ខេត្តកំពង់ឆ្នាំងមាន ០២ រោងចក្រ មានកម្មករសន្លប់សរុបចំនួន ៨៧ នាក់ ។
- ខេត្តស្វាយរៀងមាន ០១ រោងចក្រ មានកម្មករសន្លប់សរុបចំនួន ១០៤ នាក់ ។
- ខេត្តតាកែវមាន ០២ រោងចក្រ មានកម្មករសន្លប់សរុបចំនួន ១៤២ នាក់ ។
- ខេត្តព្រៃវែង ០១ រោងចក្រ មានកម្មករសន្លប់សរុបចំនួន ១៧ នាក់។

## ស្ថានភាពបាតុភាពករណីសន្លប់ និងការផ្សព្វផ្សាយអប់រំកម្មករនិយោជិតនៅឆ្នាំ២០១៤ និង ឆ្នាំ២០១៥

*-ស្ថានភាពបាតុភាពករណីសន្លប់*

*ក្រាហ្វិកទី៨. មូលហេតុនៃកម្មករនិយោជិតសន្លប់ទាំង ៣២ រោងចក្រកាត់ដេរ និង ផលិតស្បែកជើង*



*ក្រាហ្វិកទី៩. មូលហេតុនៃកម្មករនិយោជិតសន្លប់ទាំង ៣២ រោងចក្រ ធៀបនឹងរោងចក្រកាត់ដេរ និង ផលិតស្បែកជើង ដែលបានចុះបញ្ជិកានៅ ប.ស.ស ទាំង ១,០៨៨ រោងចក្រ*




*តារាងទី១០. ទិន្នន័យរោងចក្រ និងកម្មករនយោជិតសន្លប់ក្នុងឆ្នាំ២០១៤ និង ឆ្នាំ២០១៥*

| ល.រ | រាជធានី/ខេត្ត | ឆ្នាំ២០១៥ | | ឆ្នាំ២០១៤ | | គិតជា % | |
|---|---|---|---|---|---|---|---|
| | | រោងចក្រ | កម្មករ | រោងចក្រ | កម្មករ | រោងចក្រ | កម្មករ |
| | សរុបរួម | 32 | 1,806 | 34 | 1,806 | -5.9% | 0% |
| ១ | រាជធានីភ្នំពេញ | 8 | 359 | 21 | 1,030 | -62% | -65% |
| ២ | ខេត្តកណ្តាល | 13 | 800 | 2 | 357 | 550% | 124% |
| ៣ | ខេត្តកំពង់ស្ពឺ | 5 | 297 | 3 | 72 | 67% | 313% |
| ៤ | ខេត្តកោះកុង | - | - | 1 | 7 | - | - |
| ៥ | ខេត្តកំពង់ឆ្នាំង | 2 | 87 | 2 | 48 | 0% | 81% |
| ៦ | ខេត្តស្វាយរៀង | 1 | 104 | 3 | 253 | -67% | -59% |
| ៧ | ខេត្តព្រះសីហនុ | - | - | 1 | 36 | - | - |
| ៨ | ខេត្តតាកែវ | 2 | 142 | 1 | 3 | 100% | 4633% |
| ៩ | ខេត្តព្រៃវែង | 1 | 17 | - | - | - | - |

*តារាងទី១១. ការវិភាគប្រវត្តិទិន្នន័យជារួម ក្នុងឆ្នាំ២០១៤ និងឆ្នាំ២០១៥*

| ល.រ | បរិយាយ | ឆ្នាំ២០១៥ | ឆ្នាំ២០១៤ | គិតជា % |
|---|---|---|---|---|
| ១ | រោងចក្រជួបបញ្ហាសន្លប់ | 32 | 34 | -5.88% |
| ២ | កម្មករសន្លប់ | 1,806 | 1,806 | 0.00% |
| ៣ | កម្មករមិនបានសន្លប់ក្នុង រោងចក្រជួបបញ្ហាសន្លប់ | 45,259 | 52,883 | -14.42% |
| ៤ | រោងចក្រកាត់ដេរ/ស្បែកជើង បានចុះបញ្ជិកា ប.ស.ស | 1,088 | 1,075 | 1.21% |
| ៥ | កម្មករកាត់ដេរ/ស្បែកជើង បានចុះបញ្ជិកា ប.ស.ស | 71,564 | 699,158 | -89.76% |
| ៦ | ផលធៀបរវាងល.រ ១ និង ៤ | 2.94% | 3.16% | -7.01% |
| ៧ | ផលធៀបរវាងល.រ ២ និង ៥ | 2.52% | 0.26% | 876.97% |
| ៨ | ផលធៀបរវាងល.រ ២ និង ៣ | 3.99% | 3.42% | 16.85% |

*-ការផ្សព្វផ្សាយអប់រំ*

*តារាងទី១២. ការវិភាគប្រវត្តិទិន្នន័យផ្សព្វផ្សាយជារួម ក្នុងឆ្នាំ២០១៤ និងឆ្នាំ២០១៥*

| បរិយាយ | សហគ្រាសបានទទួលការផ្សព្វផ្សាយអប់រំ | | កម្មករនិយោជិតចូលរួមប្រជុំផ្សព្វផ្សាយ | |
|---|---|---|---|---|
| | រោងចក្រ | លើក | សរុប | ស្រី |
| ឆ្នាំ២០១៥ | 90 | 90 | 1,345 | 12,105 |
| ឆ្នាំ២០១៤ | 27 | 19 | 31 | 279 |
| ប្រៀបធៀប(%) | 233.33% | 373.68% | 4238.71% | 4238.71% |

**ប្រភព៖ ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ (ទ.ស.ប.ក) ឆ្នាំ២០១៥**

### ៦.២.២. ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត

បច្ចុប្បន្នគ្រោះថ្នាក់ចរាចរណ៍ ជាបន្ទុកដ៏ធំដល់រាជរដ្ឋាភិបាល ដោយសារជនរងគ្រោះបានបាត់បង់ជីវិត របួស ពិការ ខូចខាតទ្រព្យសម្បត្តិរដ្ឋ និងឯកជនយ៉ាងច្រើន ជាពិសេសកម្មករ កម្មការិនីដែលទទួលរងគ្រោះថ្នាក់ចរាចរណ៍ពេលកំពុងធ្វើដំណើរទៅ និងត្រឡប់មកពីបំពេញការងារ ដោយមធ្យោបាយនានា។ ដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយ ក៏ដូចជាទប់ស្កាត់ករណីគ្រោះថ្នាក់ចរាចរណ៍នេះ បេឡាជាតិរបបសន្តិសុខសង្គម តាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបង្កើតក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិតហៅកាត់ថា (ស.ផ.ក)ដោយសេចក្តីសម្រេចលេខ០០២/១៣ ក.ប/ស.ស.រ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ ដែលមានសមាសភាពមកពីក្រសួងពាក់ព័ន្ធ, តំណាងភាគីនិយោជក, កម្មករនិយោជិត និងអង្គការជនពិការអន្តរជាតិ(HI)។ ក្រុមការងារនេះមានភារកិច្ចកសាងផែនការសកម្មភាព,សិក្សាស្រាវជ្រាវប្រមូលទិន្នន័យវិភាគ,ស្រង់ស្ថិតិមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត, ផ្សព្វផ្សាយអប់រំណែនាំពីច្បាប់និងសុវត្ថិភាពចរាចរណ៍ និងសហការជាមួយអាជ្ញាធរដែនដី សមត្ថកិច្ចពាក់ព័ន្ធក្នុងការចាត់វិធានការបង្ការ និងទប់ស្កាត់ករណីគ្រោះថ្នាក់ចរាចរណ៍ ព្រមទាំងអនុវត្តភារកិច្ចផ្សេងទៀត តាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

*រូបភាពទី៧. ការផ្សព្វផ្សាយអំពីសុវត្ថិភាពចរាចរណ៍លើមធ្យោបាយដឹកជញ្ជូនដល់អ្នកបើកបរដឹកកម្មករ និងកម្មករនិយោជិត*




សម្រាប់ឆ្នាំ២០១៥ កន្លងមកនេះ ក្រុមការងារបានរៀបចំផែនការការងារ និងសម្ភារៈឧបទ្ទេសសម្រាប់ផ្សព្វផ្សាយអប់រំដល់អ្នកបើកបរដឹកកម្មករនិយោជិត កម្មករ/កម្មការិនី ស្តីពីច្បាប់ចរាចរណ៍ផ្លូវគោក, បច្ចេកទេសត្រួតពិនិត្យយានយន្ត, វិជ្ជាសង្គ្រោះបឋម, ពាក់មួកសុវត្ថិភាព និងវិធីការពារគ្រោះថ្នាក់ផ្សេងៗជាពិសេសចំណុចដែលបណ្តាលឱ្យមានគ្រោះថ្នាក់ចរាចរណ៍ជាញឹកញាប់ និងការងារមួយចំនួនទៀត បានគួរឱ្យកត់សំគាល់ ដូចបង្ហាញលទ្ធផលខាងក្រោម៖

*-ស្ថានភាពគ្រោះថ្នាក់ចរាចរណ៍*

**តារាងទី ១៣៖ ស្ថានភាពគ្រោះថ្នាក់ចរាចរណ៍របស់កម្មករនិយោជិត**

| គ្រោះថ្នាក់ចរាចរណ៍របស់កម្មករ | ករណី | ស្ថានភាពជនរងគ្រោះ(នាក់) | | | | យានយន្តទូទៅ(%) | | | យាន្តយន្តដឹកកម្មករ(%) | | តាមវិស័យ(%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ស្លាប់ | របួសធ្ងន់ | របួសស្រាល | សរុប | ម៉ូតូ | រថយន្ត | ផ្សេងៗ | យានយន្តដឹកកម្មករ | ផ្សេងៗ | រោងចក្រ | ធនាគា/មីក្រូហិរញ្ញវត្ថុ | ផ្សេងៗ |
| ឆ្នាំ២០១៥ | 6,491 | 130 | 1,068 | 6,159 | 7,357 | 73 | 14 | 13 | 47 | 53 | 67 | 5 | 28 |
| ឆ្នាំ២០១៤ | 3,800 | 73 | 789 | 3,875 | 4,737 | 70 | 9 | 21 | 81 | 19 | 83 | 3 | 14 |
| ប្រៀបធៀប(%) | 70.82% | 78.08% | 35.36% | 58.94% | 55.31% | 4.29% | 55.56% | -38.10% | -41.98% | 178.95% | -19.28% | 66.67% | 100.00% |

ប្រភព៖ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) ឆ្នាំ២០១៥

*-ការងារផ្សព្វផ្សាយដល់កម្មករនិយោជិត*

**តារាងទី១៤៖ ការងារផ្សព្វផ្សាយអប់រំកម្មករនិយោជិតរបស់ក្រុមការងារ (ស.ផ.ក)**

| បរិយាយ | ចំនួនសហគ្រាសបានទទួលការផ្សព្វផ្សាយអប់រំ | | ចំនួនកម្មករនិយោជិតចូលរួមប្រជុំផ្សព្វផ្សាយ | | | |
|---|---|---|---|---|---|---|
| | ចំនួនរោងចក្រ | ចំនួនលើក | កម្មករ | អ្នកបើកបរ | សរុបរួម | ស្រី |
| ឆ្នាំ២០១៥ | 307 | 103 | 17,776 | 3,591 | 21,367 | 12,820 |
| ឆ្នាំ២០១៤ | 123 | 22 | 2,675 | 1,600 | 4,275 | 2,565 |
| ប្រៀបធៀប(%) | 149.59% | 368.18% | 564.52% | 124.44% | 399.81% | 399.81% |

ប្រភព៖ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) ឆ្នាំ២០១៥

*-ការងារបណ្តុះបណ្តាល*

**តារាងទី១៥.វគ្គបណ្តុះបណ្តាលប្រឡង និងផ្តល់បណ្ណបើកបរ**

| បរិយាយ | បណ្តុះបណ្តាល ប្រឡង និងផ្តល់បណ្ណបើកបរ | | |
|---|---|---|---|
| | ចំនួនលើក | ចំនួនអ្នកចូលរួម | លទ្ធផលប្រឡងជាប់ |
| ឆ្នាំ២០១៥ | ២ | ១៥៣ | ១១៤ |
| ឆ្នាំ២០១៤ | គ្មានសកម្មភាព | គ្មានសកម្មភាព | គ្មានសកម្មភាព |
| ប្រៀបធៀប( %) | - | - | - |

ប្រភព៖ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) ឆ្នាំ២០១៥

**តារាងទី១៦.វគ្គបណ្តុះបណ្តាលគ្រូបង្គោលផ្នែកសុវត្ថិភាពចរាចរណ៍ដល់សហព័ន្ធសហជីព**

| បរិយាយ | វគ្គបណ្តុះបណ្តាលគ្រូបង្គោលផ្នែកសុវត្ថិភាពចរាចរណ៍ដល់សហព័ន្ធសហជីព | |
|---|---|---|
| | ចំនួនលើក | ចំនួនអ្នកចូលរួម |
| ឆ្នាំ២០១៥ | ៤ | ៣៨០ |
| ឆ្នាំ២០១៤ | គ្មានសកម្មភាព | គ្មានសកម្មភាព |
| ប្រៀបធៀប( %) | - | - |

ប្រភព៖ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) ឆ្នាំ២០១៥

### ៦.២.៣. គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស

គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ត្រូវបានបង្កើតឡើង ដើម្បីដោះស្រាយវិវាទ ឬ បណ្តឹងដែលទាក់ទងទៅនឹងការអនុវត្តបទប្បញ្ញត្តិ និង បទបញ្ជាខាងវិស័យសន្តិសុខសង្គម រវាងសមាជិក ប.ស.ស និយោជក និង ប.ស.ស ដែលគណៈកម្មការនេះមានការចូលរួមត្រីភាគីរួមមានតំណាង ប.ស.ស តំណាងនិយោជក និងកម្មករនិយោជិត។

សម្រាប់ឆ្នាំ២០១៥ គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស បានទទួលពាក្យបណ្តឹងចំនួន ០២ ករណី អំពីការសុំទាមទារសំណងគ្រោះថ្នាក់ការងារ។ ចំពោះករណីនេះ គណៈកម្មការបានធ្វើការវិនិច្ឆ័យបណ្តឹងតវ៉ា ដែលមានការចូលរួមពីគ្រប់ភាគីទាំងអស់ រួមមានភាគី ប.ស.ស តំណាងនិយោជក តំណាងកម្មករនិយោជិត និង ភាគីដើមបណ្តឹង ដោយប្រព្រឹត្តទៅបានល្អប្រសើរ ប្រកបដោយតម្លាភាព និងយុត្តិធម៌។ តាមរយៈគណៈកម្មការនេះ យើងបានកត់សម្គាល់ឃើញផងដែរថា ចាប់តាំងពីដំណើរការដំបូងរហូតមកដល់ពេលនេះ គណៈកម្មការបានទទួលពាក្យបណ្តឹងពីជនរងគ្រោះ ជាសមាជិក ប.ស.ស តែ ០៤ ករណី ប៉ុណ្ណោះ ដែលប្រការនេះកើតចេញមកពី ប.ស.ស បានរៀបចំយុទ្ធសាស្ត្រ និងនីតិវិធីអនុវត្តការងារបានត្រឹមត្រូវជាពិសេសប្រព័ន្ធការងារ ដែលមានផែនការច្បាស់លាស់ និងការត្រួតពិនិត្យតាមដានជាប្រចាំ ដែលបានជំរុញឱ្យមន្ត្រី និងបុគ្គលិកគ្រប់លំដាប់ថ្នាក់របស់ ប.ស.ស បំពេញការងារប្រកបដោយវិជ្ជាជីវៈ ការទទួលខុសត្រូវព្រមទាំងមានការចូលរួមរបស់និយោជក និងកម្មករនិយោជិតក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួនបានល្អប្រសើរ។ ក្នុងឆ្នាំ២០១៥នេះដែរ គណៈកម្មការបានប្រជុំផ្ទៃក្នុងចំនួន ០២ លើក ដើម្បីពិនិត្យ និងកែសម្រួលប្រការ៣ នៃប្រកាសលេខ១៧៧ កប/ប្រក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ ស្តីពីសមាសភាព និងការប្រព្រឹត្តទៅរបស់ គណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹងនៃ ប.ស.ស និងពិនិត្យលើសេចក្តីសម្រេចស្តីពីការកំណត់បែបបទ និងរបៀបរបបការងារ។

## III. ការរៀបចំដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព

បន្ទាប់ពីបានអនុវត្តដោយជោគជ័យនូវជំហានទី១ ផ្នែកហានិភ័យការងារ និងដោយយោងទៅលើស្ថានភាពរីកចំរើន នៃសេដ្ឋកិច្ចជាតិ ដែលក្នុងនោះមានការកើនឡើងជាច្រើននូវការវិនិយោគក្នុងប្រទេស និងកម្មករនិយោជិតដែលបម្រើការងារនៅតាមបណ្តាសហគ្រាស គ្រឹះស្ថាន ហើយដែលការរីកចំរើននេះទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់អំពីបញ្ហាលក្ខខណ្ឌការងារ ជាពិសេសបញ្ហាសុខភាពរបស់កម្មករនិយោជិត ជាក់ស្តែងនាប៉ុន្មានឆ្នាំចុងក្រោយនេះមានបាតុភាពករណីកម្មករនិយោជិតសន្លប់នៅក្នុងសហគ្រាស គ្រឹះស្ថាន តាមបណ្តារាជធានី-ខេត្តមួយចំនួន ដែលករណីនេះមួយចំនួនធំត្រូវបានរកឃើញថាមានការពាក់ព័ន្ធទៅនឹងបញ្ហាសុខភាពផ្ទាល់របស់កម្មករនិយោជិត។

បច្ចុប្បន្ន ប.ស.ស បានទទួលយកគម្រោងធានារ៉ាប់រងសុខភាព(HIP) របស់អង្គការ GRET មកអនុវត្តសាកល្បង ដែលគម្រោងនេះគ្របដណ្តប់លើសេវាព្យាបាលថែទាំវេជ្ជសាស្ត្រ និងសេវាបញ្ជូនជនរងគ្រោះ។ បច្ចុប្បន្នគម្រោងនេះ បានចុះបញ្ជិកាពេងចក្រចំនួន ១១ មានកម្មករនិយោជិតសរុបចំនួន ៧.៩៥៦ នាក់

(ស្រី ៧.១៦០ នាក់) ។ សម្រាប់ឆ្នាំ២០១៥ មានសមាជិកប្រើប្រាស់សេវាសរុបចំនួន ១១.៩៣៧ ដង ក្នុងនោះសម្រាកនៅពេទ្យ IPD ៤៣៥ ដង, ពិគ្រោះជំងឺក្រៅ OPD ១១.២៥៦ ដង,សម្រាលកូន Delivery ១៣៤ ដង និង រលូតកូន Abortion ១១២ ដង ស្មើនឹងចំនួនអ្នកប្រើប្រាស់សេវាសរុបចំនួន ៣.៤៥៧ នាក់ (ស្រី ៣.១៨៥ នាក់) មានការថយចុះចំនួន -៤៨១ នាក់ ស្មើនឹង -១២,២១ភាគរយ បើប្រៀបធៀបនឹងឆ្នាំចាស់។

**តារាងទី១៧៖ ចំនួនអ្នកប្រើប្រាស់សេវាធានារ៉ាប់រងសុខភាព(HIP)**

| ល.រ | ប្រភេទអ្នកប្រើប្រាស់សេវាធានារ៉ាប់រងសុខភាព(HIP) | អ្នកប្រើប្រាស់ (ដង) | | |
|---|---|---|---|---|
| | | ឆ្នាំ២០១៥ | ឆ្នាំ២០១៤ | ប្រៀបធៀប(%) |
| ១ | សម្រាកនៅពេទ្យ (IPD) | 417 | 367 | 13.62% |
| ២ | ពិគ្រោះជំងឺក្រៅ (OPD) | 10,822 | 10,211 | 5.98% |
| ៣ | សម្រាលកូន (Delivery) | 121 | 103 | 17.48% |
| ៤ | រលូតកូន (Abortion) | 106 | 103 | 2.91% |
| សរុប | | 11,466 | 10,784 | 6.32% |

**ប្រភព៖ បេឡាជាតិរបបសន្តិសុខសង្គម ឆ្នាំ២០១៥**

*សំគាល់៖ ចំនួនអ្នកប្រើប្រាស់សេវាសរុប ១១.៤៦៦ ដង ស្មើនឹងចំនួន ៣.៤៥៧ នាក់ (ស្រី ៣.១៨៥ នាក់)។

ដើម្បីឱ្យកម្មករទទួលបាននូវការព្យាបាល និងសេវាសង្គ្រោះបានទាន់ពេលវេលា ប.ស.ស បានដាក់ឱ្យដំណើរការប្រព័ន្ធទូរស័ព្ទទំនាក់ទំនងបន្ទាន់មួយខ្សែ ០១១ ៧៩៩ ៤៣០ ដើម្បីសម្របសម្រួលជាមួយសមាជិក និងដាក់ភ្នាក់ងារសម្របសម្រួលនៅតាមមន្ទីរពេទ្យ និងមណ្ឌលសុខភាពចំនួន ០៨ ក្នុងរាជធានីភ្នំពេញ។

សម្រាប់ការរៀបចំដាក់ឱ្យដំណើរការផ្នែកថែទាំសុខភាពនេះផងដែរ ប.ស.ស កន្លងមកក៏បានបង្កើតក្រុមការងាររៀបចំដាក់ឱ្យដំណើរការផ្នែកថែទាំសុខភាព និងគណៈកម្មការរៀបចំយន្តការនៃការទូទាត់សេវាសុខាភិបាល តាមរយៈក្រុមការងារ និងគណៈកម្មការនេះ ការត្រៀមរៀបចំអនុវត្តការងារ សម្រេចបានលទ្ធផលគួរឱ្យកត់សំគាល់លើការរៀបចំលិខិតបទដ្ឋានគតិយុត្ត បែបបទ និងនីតិវិធី ការងារបានមួយចំនួនរួមមាន៖

- សេចក្តីព្រាងអនុក្រឹត្យស្តីពីរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។
- សេចក្តីព្រាងប្រកាសស្តីពីសេវាធានារ៉ាប់រងសុខភាព។
- សេចក្តីព្រាងប្រកាសស្តីពីយន្តការទូទាត់ថ្លៃសេវាធានារ៉ាប់រងសុខភាព និងហានិភ័យការងារ។
- សេចក្តីព្រាងប្រកាសស្តីពីការកំណត់អត្រាភាគទាន និងបែបបទ នៃការបង់ភាគទានសម្រាប់ផ្នែកថែទាំសុខភាព។
- សេចក្តីព្រាងប្រកាសស្តីពីជម្ងឺរ៉ាំរ៉ៃ។
- ចុះកំណត់អត្តសញ្ញាណកម្មករនិយោជិត ។

## IV. **បញ្ហាប្រឈម**

នៅក្នុងការអនុវត្តជំហានទី១ ផ្នែកហានិភ័យការងារ ប.ស.ស បានជួបប្រទះនូវការលំបាកមួយចំនួន ទាក់ទងទៅនឹងការចូលរួមអនុវត្តច្បាប់របស់និយោជក កម្មករនិយោជិត ការផ្តល់សេវាព្យាបាលថែទាំវេជ្ជសាស្ត្ររបស់មន្ទីរពេទ្យ និងបញ្ហាខាងក្នុងរបស់ ប.ស.ស មួយចំនួនផងដែរ។

*និយោជក ឬ ម្ចាស់សហគ្រាសមួយចំនួនតូច*

- ការអនុវត្តកាតព្វកិច្ចរបស់និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថានមួយចំនួនមិនទាន់បានល្អប្រសើរ។
- មិនទាន់មានទិន្នន័យកម្មករនិយោជិត គ្រប់គ្រាន់ជាហេតុធ្វើឱ្យពិបាកក្នុងការផ្តល់លេខអត្តសញ្ញាណកម្មករនិយោជិត។
- សហការមិនបានល្អក្នុងការផ្តល់ព័ត៌មានទាក់ទងនឹងចំនួនកម្មករនិយោជិត ប្រាក់ឈ្នួល និង សាខារបស់ក្រុមហ៊ុន។
- រាយការណ៍ពីចំនួនកម្មករនិយោជិត និងបង់ភាគទានតាមខែនីមួយៗមានភាពយឺតយ៉ាវ។
- ផ្តល់របាយការណ៍ហានិភ័យការងារមិនច្បាស់លាស់ និង យឺតយ៉ាវ ដែលនាំឱ្យមានការលំបាកក្នុងការអង្កេតរកមូលហេតុគ្រោះថ្នាក់ការងារ និង នាំឱ្យការផ្តល់តាវកាលិកជូនជនរងគ្រោះយឺត។
- មានការលំបាកក្នុងការជួបម្ចាស់សហគ្រាស គ្រឹះស្ថានមួយចំនួនជាពិសេសវិស័យភោជនីយដ្ឋាន ក្លឹបកំសាន្ត ខារ៉ាអូខេជាដើម ដោយពួកគាត់ពុំទាន់បានស្គាល់ច្បាស់ពី ប.ស.ស នៅឡើយ។
- សហគ្រាស គ្រឹះស្ថានមួយចំនួនចេះតែសុំលើកពេល និងមួយចំនួនទៀតមិនព្រមចុះហត្ថលេខាទទួលឯកសារពីក្រុមអធិការ និងមិនបានផ្តល់ឯកសារពាក់ព័ន្ធមកក្រុមអធិការ។
- តំណាងសហគ្រាស ពុំបានរាយការណ៍អំពីការចុះបញ្ជិកាមក ប.ស.ស ទៅឱ្យម្ចាស់សហគ្រាសបានដឹងទាន់ពេលវេលា។
- ម្ចាស់សហគ្រាសគ្រឹះស្ថានមួយចំនួននៅមិនទាន់បានស្គាល់ ប.ស.ស ច្បាស់លាស់ទាក់ទងនឹងនីតិវិធីចុះបញ្ជិកា ក៏ដូចជាបង់ភាគទាន និងអត្ថប្រយោជន៍ដែលទទួលបាន។
- សហគ្រាស គ្រឹះស្ថានមួយចំនួន បិទទ្វារ ផ្អាកសកម្មភាព ប្តូរអាស័យដ្ឋាន ប្តូររដ្ឋបាលថ្មី ប្តូរថៅកែថ្មី ឬប្តូរយីហោថ្មី ដោយមិនបានធ្វើលិខិតជម្រាបជូនដំណឹងមក ប.ស.ស ជាមុន។
- រក្សាទុកឯកសារទាមទារតាវកាលិករយៈពេលយូរ ដោយទុកសរុបរួមបានច្រើនករណី ឬ ដាច់ខែទើបបញ្ជូនមក ប.ស.ស និងពេលបានតាវកាលិកមានភាពយឺតយ៉ាវក្នុងការផ្តល់ឱ្យជនរងគ្រោះវិញ។

*កម្មករនិយោជិតមួយចំនួនតូច*

- មិនទាន់យល់ច្បាស់ពីការអនុវត្តរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ។
- មិនមានឯកសារបញ្ជាក់ពីអត្តសញ្ញាណរបស់ខ្លួន ខ្ចីឯកសារអ្នកដទៃមកប្រើ(ដូចជាអត្តសញ្ញាណប័ណ្ណ ប័ណ្ណស្នាក់នៅ និងសៀវភៅគ្រួសារ ឬ ប្រើប្រាស់ឯកសារមិនប្រក្រតីដែលនាំឱ្យមានការលំបាកក្នុងការចុះបញ្ជិកាកម្មករនិយោជិត និងផ្ទៀងផ្ទាត់ឯកសារនៅពេលផ្តល់តាវកាលិក។

- រៀបអាពាហ៍ពិពាហ៍ហើយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ ដែលជាហេតុមិនអាចទទួលបានតាវកាលិកឧត្តរជីវី សម្រាប់អ្នករស់នៅក្នុងបន្ទុក។
- ទៅទទួលការព្យាបាលនៅមន្ទីរពេទ្យ ដែលមិនបានចុះកិច្ចសន្យាជាមួយ ប.ស.ស និងប្រើប្រាស់សេវាមិនចំគោលដៅ។
- ពិបាកក្នុងការទាមទារសំណងព្យាបាលវេជ្ជសាស្ត្រដែលមិនមែនជាគ្រោះថ្នាក់ការងារ។
- ទាមទារតាវកាលិកចំពោះគ្រោះថ្នាក់មិនមែនការងារ។

*មូលដ្ឋានសុខាភិបាលមួយចំនួនតូច*

- គុណភាពនៃការផ្តល់សេវាព្យាបាលថែទាំវេជ្ជសាស្ត្រនៅមានកម្រិត។
- ផ្តល់សេវាមិនគោរពទៅតាមគោលការណ៍របស់ក្រសួងសុខាភិបាល, តាមបច្ចេកទេសវេជ្ជសាស្ត្រ, មិនចំគោលដៅ, បន្លើសតម្លៃសេវា ឬការបង្កើតសេវាបន្ថែម និង ពិបាកក្នុងការទាមទារឯកសារវេជ្ជសាស្ត្រ។
- ប្រើរថយន្តសង្គ្រោះបន្ទាន់ដឹកជនរងគ្រោះទាមទារតម្លៃសេវាខ្ពស់។

ក្រៅពីកត្តាខាងក្រៅ ក៏នៅមានកត្តាខាងក្នុងរបស់ ប.ស.ស ផ្ទាល់ផងដែរទាក់ទងទៅនឹងសមត្ថភាពរបស់ស្ថាប័ន រួមមានទីកន្លែងធ្វើការនៅមានភាពតូចចង្អៀត, សមត្ថភាពមន្ត្រីមួយចំនួនតូចនៅមានកម្រិត, ប្រព័ន្ធគ្រប់គ្រងទិន្នន័យមិនទាន់មានភាពរលូន និងការផ្តល់តាវកាលិកមួយចំនួនមានការយឺតយូរផងដែរ។

## V. វិធានការដោះស្រាយ

ភាពច្បាស់លាស់, ការពង្រឹងការអនុវត្តច្បាប់, ការផ្សព្វផ្សាយ, ការសម្របសម្រួល និងដោះស្រាយបានឆាប់រហ័សទាន់ពេលវេលា, ការបណ្តុះបណ្តាលធនធានមនុស្ស, ការអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យា, ការរៀបចំបែបបទ និងនីតិវិធីឱ្យបានកាន់តែល្អប្រសើរ គឺជាវិធានការដោះស្រាយដ៏សក្តិសិទ្ធ ដើម្បីធានាដល់ការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារឱ្យមានប្រសិទ្ធភាព និងប្រកបដោយគុណភាព។ ក្នុងគោលបំណងដោះស្រាយបញ្ហាប្រឈមទាំងនេះ ប.ស.ស បាននឹងកំពុងអនុវត្តនូវសកម្មភាពជាអាទិភាពមួយចំនួនមានជាអាទិ៍៖

- ផ្សព្វផ្សាយ ពន្យល់ណែនាំដល់ម្ចាស់សហគ្រាស គ្រឹះស្ថាន សហជីពមូលដ្ឋាន និងកម្មករនិយោជិតឱ្យយល់ពីការអនុវត្តគោលនយោបាយរបបសន្តិសុខសង្គម ជាពិសេសផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពដែលនឹងដាក់ឱ្យដំណើរការនាឆ្នាំ២០១៦ នេះ។
- ជ្រើសរើស និងដាក់ភ្នាក់ងារ ប.ស.ស និងសម្របសម្រួលជាមួយមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងឱ្យផ្តល់សេវាព្យាបាលថែទាំវេជ្ជសាស្ត្របានកាន់តែល្អប្រសើរ។
- ចាត់វិធានការរដ្ឋបាលចំពោះសហគ្រាស គ្រឹះស្ថាន ដែលមិនអនុវត្តតាមច្បាប់។
- បណ្តុះបណ្តាលធនធានមនុស្ស, អភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យា, រៀបចំបែបបទ និងនីតិវិធីការងារឱ្យបានកាន់តែល្អប្រសើរ និងរៀបចំប្រព័ន្ធនៃការទទួលគំនិតរិះគន់ស្ថាបនា (Complaint System) ទាំងនៅផ្នែក Hard Ware និង Soft Ware។
- កែសម្រួលឡើងវិញនូវប្រព័ន្ធគ្រប់គ្រង Hot Line និង Call Center។

- បង្កើតប្រព័ន្ធជូនដំណឹងពីពេលវេលាត្រូវបង់ភាគទាន និងយន្តការបង់ភាគទានតាមប្រព័ន្ធទូរស័ព្ទដៃ (Acleda Unity)។
- រៀបចំយន្តការទាររបាយការណ៍ព័ត៌មានគ្រោះថ្នាក់ការងារជាមួយសហគ្រាស គ្រឹះស្ថាន និងមូលដ្ឋានសុខាភិបាល។
- ផ្តល់ព័ត៌មានពីលទ្ធផលអង្កេតគ្រោះថ្នាក់ការងារ ដល់សហគ្រាស និងកម្មករនិយោជិត និងឱ្យមកដាក់ពាក្យស្នើសុំតាវកាលិកឱ្យបានឆាប់រហ័ស។
- ចុះបញ្ជិកាកម្មករនិយោជិតឡើងវិញ។
- សម្របសម្រួលជាមួយមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀង ផ្តល់សេវាបានកាន់តែល្អប្រសើរ និងប្រជុំដោះស្រាយបញ្ហាប្រឈមនានា។

## VI. ទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០១៦

ដើម្បីធានាដល់ការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារឱ្យមានប្រសិទ្ធភាព និង ទាន់ពេលវេលា ប.ស.ស បានដាក់ចេញនូវទិសដៅសំខាន់ៗមួយចំនួន លើការអនុវត្តជំហានទី១ គឺផ្នែកហានិភ័យការងារដែលបាននិងកំពុងអនុវត្ត និងជំហានទី២ ផ្នែកថែទាំសុខភាព ដែលគ្រោងនឹងអនុវត្តនៅឆ្នាំ២០១៦ នេះ ដើម្បីផ្តល់សេវាជូនកម្មករនិយោជិតដែលទទួលរងនូវយថាភាពផ្សេងៗ ឱ្យទទួលបាននូវការព្យាបាល ការថែទាំសុខភាព ធានាបាននូវសន្តិសុខប្រាក់ចំណូល និងដើម្បីរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ស្ថិរភាពសង្គម។

- ពង្រឹង ពង្រីក និងអភិវឌ្ឍផ្នែកហានិភ័យការងារ ឱ្យបានកាន់តែល្អប្រសើរបន្ថែមទៀត។
- បន្តរៀបចំបែបបទ នីតិវិធី និង លិខិតបទដ្ឋានគតិយុត្ត ដើម្បីដាក់ឱ្យដំណើរការ ផ្នែកថែទាំសុខភាពនៅឆ្នាំ២០១៦ នេះ។
- រៀបចំបែបបទ នីតិវិធី និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីដាក់ឱ្យដំណើរការផ្នែកប្រាក់សោធន។
- បន្តដាក់ភ្នាក់ងារ ប.ស.ស និងសម្របសម្រួលជាមួយមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងឱ្យផ្តល់សេវាកាន់តែមានប្រសិទ្ធភាព និងល្អប្រសើរជាងមុន។
- បន្តធ្វើការផ្សព្វផ្សាយ សម្របសម្រួល និង ពន្យល់ណែនាំពីការអនុវត្តគោលនយោបាយផ្នែកហានិភ័យការងារដល់ម្ចាស់សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត។
- បន្តចុះផ្សព្វផ្សាយអប់រំជូនតំណាងនិយោជក, សហជីព, ប្រតិភូបុគ្គលិក, អ្នកបើកបរ និងកម្មករនៅតាមបណ្តាសហគ្រាស គ្រឹះស្ថាន។
- បន្តធ្វើការចុះអង្កេតគ្រោះថ្នាក់ការងារចំពោះជនរងគ្រោះដែលជាសមាជិក ប.ស.ស។
- បន្តចុះស្រាវជ្រាវសហគ្រាស គ្រឹះស្ថានដែលបង្កើតថ្មីឱ្យមកចុះបញ្ជិកានៅ ប.ស.ស។
- បន្តចុះបញ្ជិកាកម្មករឡើងវិញ។
- បណ្តុះបណ្តាលធនធានមនុស្ស និងអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យា។

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមរបាយការណ៍ខាងលើ បានឆ្លុះបញ្ចាំងឱ្យឃើញថា ប.ស.ស បានបោះជំហានទៅមុខមួយកម្រិតទៀត ដោយការអនុវត្តនូវជំហានទី១ ផ្នែកហានិភ័យការងាររហូតមកដល់ដំណាច់ឆ្នាំ២០១៥ នេះ បានពង្រីកវិសាលភាពគ្របដណ្តប់នៅទូទាំងប្រទេស, ចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន បានចំនួន ៧.៧៩៦ មានកម្មករនិយោជិតចំនួន *១.០៧៧.០៧៩* នាក់, ចុះកិច្ចព្រមព្រៀងប្រើប្រាស់សេវាព្យាបាលថែទាំវេជ្ជសាស្ត្រជាមួយមូលដ្ឋានសុខាភិបាលចំនួន ៩៣, ផ្តល់តាវកាលិកហានិភ័យការងារសម្រាប់ឆ្នាំ២០១៥ បានចំនួន *១៥.៥៥១* នាក់ និងបានចុះធ្វើអធិការកិច្ចតាមបណ្តាសហគ្រាស គ្រឹះស្ថាន ពង្រឹងការអនុវត្តច្បាប់បានជាច្រើនករណី។ ក្រៅពីការងារចុះបញ្ជិកា, ទទួលភាគទាន, ការផ្តល់តាវកាលិក និងការចុះធ្វើអធិការកិច្ច ប.ស.ស បាននឹងកំពុងចុះកំណត់អត្តសញ្ញាណរបស់កម្មករជាថ្មី, រៀបចំវិធានការបង្ការគ្រោះថ្នាក់ការងារ, រៀបចំពង្រឹង ពង្រីក និងអភិវឌ្ឍការអនុវត្តគោលនយោបាយផ្នែកហានិភ័យការងារ បានជាច្រើនទៀត ដើម្បីធានាបាននូវការផ្តល់សេវាសន្តិសុខសង្គមប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា។ មួយវិញទៀត ប.ស.ស ក៏បានរៀបចំលិខិតបទដ្ឋានគតិយុត្ត នីតិវិធី និងបែបបទការងារសម្រាប់អនុវត្តជំហានទី២ ផ្នែកថែទាំសុខភាព ដែលនឹងដាក់ឱ្យដំណើរការជាផ្លូវការនៅឆ្នាំ២០១៦ នេះ ដើម្បីឱ្យកម្មករនិយោជិតទទួលបាននូវការថែទាំ និងព្យាបាលសុខភាព ការពារប្រឆាំងនឹងការប្រថុយប្រថាននៃការចំណាយលើមហន្តរាយផ្នែកសុខភាព និងការខាតបង់ប្រាក់ចំណូលនៅពេលមានជំងឺ មាតុភាព និងយថាភាពផ្សេងៗទៀត។

ការសម្រេចបាននូវលទ្ធផលការងារខាងលើនេះ ដោយសារថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក ប.ស.ស ទាំងអស់ បានយកចិត្តទុកដាក់បំពេញការងារប្រកបដោយមនសិការវិជ្ជាជីវៈ និងឆន្ទៈទទួលខុសត្រូវខ្ពស់ រួមទាំងមានការគាំទ្រសហការពីក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍន៍នានា និងការចូលរួមអនុវត្តច្បាប់បានល្អប្រសើរពីសំណាក់ម្ចាស់សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត។

ទន្ទឹមនឹងលទ្ធផលការងារខាងលើ ប.ស.ស បានសង្កេតឃើញនៅមានបញ្ហាប្រឈមមួយចំនួនទៀត ទាក់ទងនឹងការអនុវត្តកាតព្វកិច្ចមិនទាន់បានល្អប្រសើរពីសំណាក់និយោជកនិងកម្មករនិយោជិតមួយចំនួនតូច គុណភាពនៃការផ្តល់សេវាព្យាបាលថែទាំវេជ្ជសាស្ត្រនៅមានកម្រិត និងបញ្ហារបស់ ប.ស.ស មួយចំនួនផងដែរ។ មួយវិញទៀត ទាក់ទងនឹងបញ្ហាប្រឈមនេះ ប.ស.ស ក៏បានកត់សំគាល់ឃើញថា ចំនួនគ្រោះថ្នាក់ការងារនៅតែមានការកើនឡើង ស្របនឹងការកើនឡើងនៃចំនួនសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតដែលបានចុះបញ្ជិកានៅ ប.ស.ស ជាពិសេសករណីរបួសធ្ងន់ ទោះបីជាករណីគ្រោះថ្នាក់នៅពេលធ្វើដំណើរមានការកើនឡើងបន្តិចក៏ដោយ ក៏ករណីនេះនៅតែមានចំនួនគួរឱ្យព្រួយបារម្ភផងដែរ។ ដូចនេះ ដើម្បីចូលរួមដោះស្រាយបញ្ហាប្រឈមខាងលើ វាទាមទារឱ្យមានការបន្តជួយជ្រោមជ្រែង គាំទ្រសហការបន្ថែមទៀតពីសំណាក់ក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា នៅក្នុងការអភិវឌ្ឍន៍វិស័យសន្តិសុខសង្គមនៅកម្ពុជាឱ្យមានការរីកចម្រើន និងសូមឱ្យមានការចូលរួមយ៉ាងសកម្មក្នុងការចាត់វិធានការអប់រំផ្សព្វផ្សាយ ដើម្បីបង្ការ និងទប់ស្កាត់ក្នុងការកម្រិតគ្រោះថ្នាក់ការងារឱ្យនៅទាបបំផុត ដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើកកំពស់ស្ថិរភាពសង្គម។ ម្យ៉ាងវិញទៀតកម្មករនិយោជិត

ខ្លួនឯងផ្ទាល់ត្រូវមានការយល់ដឹងចំពោះបញ្ហាសុខភាព និងប្រុងប្រយ័ត្នខ្ពស់នៅក្នុងការបំពេញការងារ ជាពិសេសការធ្វើដំណើរទៅមក ដើម្បីជៀសវាងកុំឱ្យមានគ្រោះថ្នាក់ ព្រោះវានាំឱ្យខាតបង់ការងារ ពេលវេលាថវិកា និងជាយថាហេតុបណ្តាលឱ្យបាត់បង់ដល់អាយុជីវិតទៀតផង។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៦

**នាយកបេឡាជាតិរបបសន្តិសុខសង្គម**

## លទ្ធផលសម្រេចបានធៀបនឹងផែនការសកម្មភាពអនុវត្តយុទ្ធសាស្ត្រគាំពារសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារឆ្នាំ២០១៤-២០១៨

### អនុកម្មវិធីទី១៖ ពង្រឹង និងពង្រីកការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ

| ល.រ | សកម្មភាព | សូចនាករ | ឯកតា | ឆ្នាំអនុវត្ត | | | | | | | | | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៤ | | | ២០១៥ | | | ២០១៦ | ២០១៧ | ២០១៨ | |
| | | | | ផែនការ | លទ្ធផល | | ផែនការ | លទ្ធផល | | | | | |
| | | | | | ចំនួនឯកតា | ផលធៀប (%) | | ចំនួនឯកតា | ផលធៀប (%) | | | | |
| **ចង្កោមសកម្មភាពទី១. ពង្រីកដែនអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ** | | | | | | | | | | | | | |
| ១.១ | បន្តផ្សព្វផ្សាយការអនុវត្តគោលនយោបាយរបបធានារ៉ាប់រងហានិភ័យការងារ | កិច្ចប្រជុំផ្សព្វផ្សាយតាមបណ្តារាជធានី.ខេត្ត | លើក | ១៥ | ២៣ | ១៥៣ | ១២ | ៤៦ | ៣៨៣ | ១២ | ១២ | ១២ | ប.ស.ស |
| ១.២ | បង្កើតការិយាល័យសាខា ប.ស.ស តាមបណ្តារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | ចំនួនការិយាល័យសាខា ប.ស.ស តាមបណ្តារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | ការិយាល័យ | ០២ | ០២ | ១០០ | ០៦ | ០ | ០ | ១០ | ១០ | ១០ | ប.ស.ស |
| ១.៣ | ចុះកិច្ចសន្យាជាមួយមូលដ្ឋានសុខាភិបាលនៅតាមបណ្តា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | ចំនួនមូលដ្ឋានសុខាភិបាលនៅតាមបណ្តារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | មូលដ្ឋានសុខាភិបាល | ២៥ | ២០ | ៨០ | ១៥០ | ០៨ | ៥ | ៥០ | ៣០ | ២០ | ប.ស.ស |
| ១.៤ | ចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត | ចំនួនសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត | សហគ្រាស | ១.០០០ | ៩៣៤ | ៩៣ | ១.០០០ | ៧៥៥ | ៧៥ | ១.០០០ | ១.០០០ | ៥.០០០ | ប.ស.ស |
| | | | កម្មករ (នាក់) | ១០០.០០០ | ១៧៤.៤១៣ | ១៧៤ | ៥០.០០០ | ៥៥.៤៩១ | ១១១ | ៥០.០០០ | ៥០.០០០ | ៤០០.០០០ | |
| ១.៥ | កែសម្រួលប្រកាសស្តីពីការកំណត់ដំណាក់កាល និងវិសាលភាពនៃការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ និងប្រកាសស្តីពីបញ្ជិកាសហគ្រាសគ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម | ដំណើរការនៃការកែសម្រួលប្រកាស | % | ០ | ០ | ០ | ០ | ០ | ០ | | ១០០ | | ប.ស.ស |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១.៦ | អនុវត្តការចុះបញ្ជិកាចំពោះនិយោជកដែលមានប្រើកម្មករចាប់ពី០១ នាក់ | ដំណើរការអនុវត្ត | % | ០ | ០ | ០ | ០ | ០ | ០ | | | ២០ | ប.ស.ស |
| ១.៧ | ពង្រីកការតភ្ជាប់ប្រព័ន្ធគ្រប់គ្រង និងភ្ជាប់បណ្ដាញព័ត៌មានវិទ្យា នៅតាមការិយាល័យសាខា ប.ស.ស រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | ដំណើរការតភ្ជាប់បណ្ដាញ | % | ១០០ | ១០០ | ១០០ | ០ | ០ | ០ | | | | ប.ស.ស |
| **ចង្កោមសកម្មភាពទី២. ពង្រឹង និងអភិវឌ្ឍរបបធានារ៉ាប់រងហានិភ័យការងារ** | | | | | | | | | | | | | |
| ២.១ | ធ្វើអធិការកិច្ចតាមបណ្ដាសហគ្រាស គ្រឹះស្ថាន | ចំនួនការធ្វើអធិការកិច្ច | លើក | ៥.៧៦០ | ៥.០៦៣ | ៨៨ | ៦.៣៣៦ | ៦.១០៩ | ៩៦ | ៦.៧៧៩ | ៧.១១៧ | ១០.៦៧៥ | ប.ស.ស |
| ២.២ | អង្កេតគ្រោះថ្នាក់ការងារ | កម្មករនិយោជិតរងគ្រោះថ្នាក់ការងារទទួលបានតាវកាលិកតាមច្បាប់ | នាក់ | ១៧.៦៧៥ | ១៨.៦៩៩ | ១០៦ | ១៧.៥៤៣ | ៣០.២៨១ | ១៧៣ | ១៧.៣១១ | ១៦.៩៧៩ | ២១.៤៤៧ | ប.ស.ស |
| ២.៣ | ចាត់វិធានការរដ្ឋបាលចំពោះសហគ្រាសគ្រឹះស្ថានដែលមិនព្រមអនុវត្តតាមច្បាប់ | អត្រាសហគ្រាស គ្រឹះស្ថានអនុវត្តតាមច្បាប់ | % | ៨៩ | ៨៧ | ៩៨ | ៩០ | ៩៦ | ១០៦ | ៩១ | ៩២ | ៩៣ | ប.ស.ស |
| ២.៤ | រៀបចំគោលការណ៍ស្ដីពីការគ្រប់គ្រងការិយភារីចំពោះរបបធានារ៉ាប់រងហានិភ័យការងារ | ដំណើរការនៃការរៀបចំប្រកាសស្ដីពីការគ្រប់គ្រងការិយភារី | % | ៥០ | មិនទាន់បានអនុវត្ត | ០ | ១០០ | ០ | ០ | | | | ប.ស.ស |
| ២.៥ | កំណត់គោលការណ៍ស្ដីពីសិស្សសាលាវិជ្ជាជីវៈ និងកូនជាង | ដំណើរការនៃការរៀបចំប្រកាសស្ដីពីការធានារ៉ាប់រងហានិភ័យការងារចំពោះសិស្សសាលាវិជ្ជាជីវៈនិងកូនជាង | % | ៥០ | មិនទាន់បានអនុវត្ត | ០ | ១០០ | ០ | ០ | | | | ប.ស.ស |
| ២.៦ | រៀបចំគោលការណ៍ស្ដីពីវិជ្ជាជីវៈសេរី ការងារម្ដងម្កាល ឬតាមរដូវ | ដំណើរការនៃការរៀបចំប្រកាសស្ដីពីការធានារ៉ាប់រងហានិភ័យការងារចំពោះអ្នកប្រកបវិជ្ជាជីវៈសេរី ការងារម្ដងម្កាល ឬតាមរដូវ | % | ៥០ | មិនទាន់បានអនុវត្ត | ០ | ១០០ | ០ | ០ | | | | ប.ស.ស |
| ២.៧ | សិក្សាចងក្រងប្រភេទជំងឺវិជ្ជាជីវៈ | ដំណើរការនៃការរៀបចំប្រកាសអន្តរក្រសួងស្ដីពីការកំណត់ប្រភេទជំងឺវិជ្ជាជីវៈ | % | ៥០ | មិនទាន់បានអនុវត្ត | ០ | ១០០ | ០ | ០ | | | | ប.ស.ស |
| ២.៨ | ធ្វើឲ្យកាន់តែប្រសើរប្រព័ន្ធគ្រប់គ្រង | ដំណើរការនៃការរៀបចំ | % | ១០០ | ១០០ | ១០០ | ០ | ៥០ | ០ | | | | ប.ស.ស |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | បញ្ជិកា និងភាគទានកម្មករនិយោជិត និងសហគ្រាស គ្រឹះស្ថាន | ប្រព័ន្ធគ្រប់គ្រងបញ្ជិកា និង ភាគទាន | | | | | | | | | | | |
| ២.៩ | ធ្វើឲ្យកាន់តែប្រសើរប្រព័ន្ធគ្រប់គ្រងតាវកាលិក | ប្រសិទ្ធភាព នៃការផ្តល់តាវកាលិក ជូនជនរងគ្រោះ | % | ៩៥ | ៨០ | ៨៤ | ៩៦ | ៩០ | ៩៤ | ៩៧ | ៩៨ | ៩៩ | ប.ស.ស |
| ២.១០ | ដំឡើងប្រព័ន្ធ SMS សម្រាប់កម្មករនិយោជិត | ដំណើរការដំឡើង ប្រព័ន្ធ SMS | % | ១០០ | ១០០ | ១០០ | ០ | ៧០ | ០ | | | | ប.ស.ស |
| **ទិសដៅចង្កោមសកម្មភាពទី៣. ចាត់វិធានការបង្ការគ្រោះថ្នាក់ការងារ** | | | | | | | | | | | | | |
| ៣.១ | សិក្សាចងក្រងស្ថិតិគ្រោះថ្នាក់ការងារ | ដំណើរការនៃការសិក្សាចងក្រងស្ថិតិគ្រោះថ្នាក់ការងារ | % | ៧០ | ២០ | ២៩ | ១០០ | ៤០ | ៤០ | | | | ប.ស.ស |
| ៣.២ | ប្រជុំពិគ្រោះយោបល់ជាមួយដៃគូពាក់ព័ន្ធ រៀបចំវិធានការបង្ការទប់ស្កាត់ និង សង្គ្រោះបន្ទាន់ករណី គ្រោះថ្នាក់ការងារ | ចំនួនប្រជុំពិគ្រោះយោបល់ជាមួយដៃគូពាក់ព័ន្ធ | លើក | ២០ | ១១ | ៥៥ | ២០ | ១៤ | ៧០ | ២០ | ២០ | ២០ | ប.ស.ស, គណៈកម្មការ ស.ទ. ប.ក និង ក្រុមការងារ ស.ផ.ក |
| ៣.៣ | ផ្សព្វផ្សាយ និងពន្យល់ណែនាំពីវិធានការបង្ការ ទប់ស្កាត់ និងសង្គ្រោះបន្ទាន់ករណីគ្រោះថ្នាក់ការងារ ទៅដល់និយោជក កម្មករនិយោជិត និងដៃគូពាក់ព័ន្ធនានា | ចំនួនប្រជុំផ្សព្វផ្សាយ និង ពន្យល់ណែនាំ | លើក | ៤៤ | ៤១ | ៩៣ | ៤០ | ១៩៩ | ៤៩៧ | ៣០ | ៣០ | ៣០ | ប.ស.ស, គណៈកម្មការ ស.ទ. ប.ក និង ក្រុមការងារ ស.ផ.ក |
| ៣.៤ | សហការជាមួយដៃគូពាក់ព័ន្ធ ចាត់វិធានការផ្នែកសន្តិសុខការងារ អនាម័យ និង សង្គ្រោះបន្ទាន់ករណីគ្រោះថ្នាក់ការងារ | អត្រាកាត់បន្ថយបាននូវករណីគ្រោះថ្នាក់ការងារ | % | ១,៨០ | ១,៨៣ | ១០២ | ១,៧០ | ២.៨១ | ១៦៥ | ១,៦០ | ១,៥០ | ១,៤០ | ប.ស.ស, គណៈកម្មការ ស.ទ. ប.ក និង ក្រុមការងារ ស.ផ.ក |
| ៣.៥ | ចុះពិនិត្យផ្ទាល់ និងជួយសម្របសម្រួលករណីគ្រោះថ្នាក់ការងារឲ្យជនរងគ្រោះទទួលបានការសង្គ្រោះបន្ទាន់ | ប្រសិទ្ធភាពនៃការទទួលបានការសង្គ្រោះបន្ទាន់ | % | ៨៥ | ៩០ | ១០៦ | ៩០ | ៩០ | ១០០ | ៩៣ | ៩៥ | ៩៧ | ប.ស.ស, គណៈកម្មការ ស.ទ. ប.ក និង ក្រុមការងារ ស.ផ.ក |
| **ចង្កោមសកម្មភាពទី៤. ផ្តល់សេវាបុននីតិសម្បទា** | | | | | | | | | | | | | |
| ៤.១ | បង្កើតយន្តការរៀបចំការផ្តល់សេវាបុននីតិសម្បទា | ដំណើរការរៀបចំយន្តការសេវាបុននីតិសម្បទា | % | ៥០ | ២០ | ៤០ | ១០០ | ៧០ | ៧០ | | | | ប.ស.ស |
| ៤.២ | បណ្តុះបណ្តាលធនធានមនុស្សផ្នែកបុននីតិសម្បទា | ចំនួនមន្ត្រីទទួលបានការបណ្តុះបណ្តាលផ្នែកបុន | នាក់ | ៧ | ៣ | ៤៣ | ១០ | | | ១៥ | ២០ | ២៥ | ប.ស.ស |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | នីតិសម្បទា | | | | | | | | | | | |
| ៤.៣ | សិក្សាស្រាវជ្រាវ និង សហការជាមួយដៃគូពាក់ព័ន្ធ | ដំណើរការនៃការសិក្សាស្រាវជ្រាវ | % | ៥០ | ២០ | ៤០ | ១០០ | ៧០ | ៧០ | | | | ប.ស.ស |
| ៤.៤ | រៀបចំលិខិតបទដ្ឋានគតិយុត្ត | ដំណើរការរៀបចំ លិខិតបទដ្ឋានគតិយុត្ត | % | ៥០ | ២០ | ៤០ | ១០០ | ៧០ | ៧០ | | | | ប.ស.ស |
| ៤.៥ | កំណត់ និងវាយតម្លៃអំពីស្ថានភាពបាត់បង់សមត្ថភាពការងាររបស់ជនរងគ្រោះ ដើម្បីផ្តល់សេវា | ប្រសិទ្ធភាព នៃការផ្តល់សេវាបុននីតិសម្បទាជូនជនរងគ្រោះ | % | ៥០ | មិនទាន់បានអនុវត្ត | ០ | ៦៥ | ០ | ០ | ៧៥ | ៨៥ | ៩៥ | ប.ស.ស |
| ៤.៦ | បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យ ការផ្តល់សេវាបុននីតិសម្បទា | ដំណើរការ នៃការរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យ | % | ៥០ | មិនទាន់បានអនុវត្ត | ០ | ១០០ | ៣០ | ៣០ | | | | ប.ស.ស |
| ៤.៧ | ចុះកិច្ចសន្យាជាមួយអង្គភាពផ្តល់សេវា | ចំនួនអង្គភាពផ្តល់សេវាបុននីតិសម្បទា | អង្គភាព | | មិនទាន់បានអនុវត្ត | ០ | ០ | ០ | ០ | ៥ | ៥ | ៥ | ប.ស.ស |

## អនុកម្មវិធីទី២៖ ដាក់ឲ្យដំណើរការរបបធានារ៉ាប់រងសុខភាព

| ល.រ | សកម្មភាព | សូចនាករ | ឯកតា | ឆ្នាំអនុវត្ត | | | | | | | | | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៤ | | | ២០១៥ | | | ២០១៦ | ២០១៧ | ២០១៨ | |
| | | | | ផែនការ | លទ្ធផល | | ផែនការ | លទ្ធផល | | | | | |
| | | | | | ចំនួនឯកតា | ធៀប (%) | | ចំនួនឯកតា | ធៀប (%) | | | | |
| **ចង្កោមសកម្មភាពទី១. រៀបចំបែបបទ និងនីតិវិធីអនុវត្តរបបធានារ៉ាប់រងសុខភាព** | | | | | | | | | | | | | |
| ១.១ | រៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការអនុវត្តរបបធានារ៉ាប់រងសុខភាព | ដំណើរការរៀបចំលិខិតបទដ្ឋានគតិយុត្ត | % | ១០០ | ១០០ | ១០០ | ០ | ០ | ០ | | | | ប.ស.ស |
| ១.២ | រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ ជាមួយដៃគូពាក់ព័ន្ធ ដើម្បីប្រមូលនូវគំនិតយោបល់ និងបទពិសោធន៍ | ចំនួនកិច្ចប្រជុំពិគ្រោះយោបល់ | លើក | ១០ | ៥ | ៥០ | ០ | ៤ | ០ | | | | ប.ស.ស |
| ១.៣ | សិក្សាស្រាវជ្រាវ និងវិភាគពីលទ្ធភាពគ្របដណ្តប់សេវាដែលមិនទាន់រាប់បញ្ចូល | ដំណើរការសិក្សាស្រាវជ្រាវ និងវិភាគប្រភេទសេវាដែលត្រូវដាក់បញ្ចូលនៅក្នុងរបប | % | ០ | ០ | ០ | ០ | ០ | ០ | ៥០ | ៧០ | ១០០ | ប.ស.ស |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ធានារ៉ាប់រងសុខភាព | | | | | | | | | | | |
| ១.៤ | រៀបចំបែបបទ និងបង្កើតឧបករណ៍វាយតម្លៃសេវារបស់មូលដ្ឋានសុខាភិបាល | ចំនួនមូលដ្ឋានសុខាភិបាលដែលបានទទួលស្គាល់គុណភាព | មូលដ្ឋានសុខាភិបាល | ៦០ | មិនទាន់បានអនុវត្ត | ០ | ១០០ | ០ | ០ | ២០០ | ៣០០ | ៥០០ | ប.ស.ស |
| **ចង្កោមសកម្មភាពទី២. រៀបចំប្រព័ន្ធព័ត៌មានវិទ្យា សម្រាប់ការអនុវត្តរបបធានារ៉ាប់រងសុខភាព** | | | | | | | | | | | | | |
| ២.១ | បង្កើតប្រព័ន្ធនៃការចុះបញ្ជិកា និងបង់ភាគទាន | ដំណើរការ នៃការរៀបចំប្រព័ន្ធគ្រប់គ្រងការចុះបញ្ជិកា និងបង់ភាគទាន | % | ១០០ | ១០០ | ១០០ | ០ | ០ | ០ | | | | ប.ស.ស |
| ២.២ | រៀបចំប្រព័ន្ធគ្រប់គ្រងការផ្តល់តាវកាលិក | ដំណើរការ នៃការរៀបចំប្រព័ន្ធគ្រប់គ្រងតាវកាលិក | % | ១០០ | ១០០ | ១០០ | ០ | ០ | ០ | | | | ប.ស.ស |
| ២.៣ | សហការជាមួយក្រសួងមហាផ្ទៃ ដើម្បីកំណត់គោលដៅអត្តសញ្ញាណកម្មករនិយោជិត | ភាគរយកម្មករនិយោជិតមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ID Smart Card) | % | ៣០ | ១៥ | ៥០ | ៧០ | ០ | ០ | ១០០ | | | ប.ស.ស |
| ២.៤ | បង្កើត និងបំពាក់ប្រព័ន្ធនៃការ ទទួលបណ្តឹងតវ៉ាពីសមាជិក (Complaint System) | ដំណើរការនៃការបង្កើត និងបំពាក់ប្រព័ន្ធ | % | ១០០ | ៧០ | ៧០ | ០ | ១០០ | ០ | | | | ប.ស.ស |
| ២.៥ | សិក្សាលទ្ធភាពផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងមូលដ្ឋាន ទិន្នន័យ (Database Oracle) | ដំណើរការនៃការសិក្សាលទ្ធភាពផ្លាស់ប្តូរប្រព័ន្ធ គ្រប់គ្រងមូលដ្ឋានទិន្នន័យ | % | ៥០ | ១០០ | ២០០ | ១០០ | ១០០ | ១០០ | | | | ប.ស.ស |
| ២.៦ | សិក្សាអំពីលទ្ធភាពផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងរួមរវាងរបបធានារ៉ាប់រងហានិភ័យ ការងារ និងរបបធានារ៉ាប់រងសុខភាព | ដំណើរការនៃការសិក្សា លទ្ធភាព និងផ្លាស់ប្តូរប្រព័ន្ធ | % | ៥០ | ១០០ | ២០០ | ១០០ | ០ | ០ | | | | ប.ស.ស |
| ២.៧ | រៀបចំតភ្ជាប់រវាងប្រព័ន្ធគ្រប់គ្រង របបធានារ៉ាប់រងសុខភាព ជាមួយនឹង ប្រព័ន្ធគ្រប់គ្រងគណនេយ្យ(Sage) | ដំណើរការតភ្ជាប់ប្រព័ន្ធ | % | ១០០ | ១០០ | ១០០ | ០ | ៧០ | ០ | | | | ប.ស.ស |
| ២.៨ | បង្កើនល្បឿនការបញ្ជូនទិន្នន័យរវាងស្នាក់ការកណ្តាល និង ការិយាល័យសាខា | ប្រសិទ្ធភាពនៃការបញ្ជូនទិន្នន័យបានទាន់ពេលវេលា | % | ៩០ | ៩០ | ១០០ | ៩៥ | ៩៥ | ១០០ | ៩៦ | ៩៨ | ១០០ | ប.ស.ស |
| ២.៩ | រៀបចំនីតិវិធី និងបំពាក់ឧបករណ៍ត្រួតពិនិត្យប្រព័ន្ធ | ដំណើរនៃការរៀបចំនីតិវិធី និងបំពាក់ឧបករណ៍ត្រួតពិនិត្យប្រព័ន្ធ | % | ១០០ | ៥០ | ៥០ | ០ | ១០០ | ០ | | | | ប.ស.ស |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ចង្កោមសកម្មភាពទី៣. រៀបចំវិធីសាស្ត្រទូទាត់ថ្លៃសេវាសុខាភិបាល** | | | | | | | | | | | | | |
| ៣.១ | រៀបចំយន្តការទូទាត់ថ្លៃសេវាសុខាភិបាល | ដំណើរការរៀបចំយន្តការ | % | ១០០ | ១០០ | ១០០ | ០ | ០ | ០ | | | | ប.ស.ស |
| ៣.២ | រៀបចំប្រព័ន្ធ នៃការទូទាត់ថ្លៃសេវាសុខាភិបាល តាមប្រព័ន្ធព័ត៌មានវិទ្យា | ដំណើរការនៃការរៀបចំប្រព័ន្ធ នៃការទូទាត់ថ្លៃសេវាសុខាភិបាល | % | ១០០ | ១០០ | ១០០ | ០ | ០ | ០ | | | | ប.ស.ស |
| ៣.៣ | រៀបចំប្រកាសអន្តរក្រសួងសម្រាប់ ការប្រើប្រាស់សេវាសុខាភិបាល ចំពោះរបបធានារ៉ាប់រងសុខភាព | ដំណើរការនៃការរៀបចំប្រកាសអន្តរក្រសួង | % | ១០០ | ៩០ | ៩០ | ០ | ០ | ០ | | | | ប.ស.ស |
| ៣.៤ | បង្កើត និងបំពាក់ប្រព័ន្ធត្រួតពិនិត្យសុពលភាព នៃសមាជិកនៅតាម មូលដ្ឋានសុខាភិបាល | ចំនួនមូលដ្ឋានសុខាភិបាលដែលត្រូវបំពាក់ប្រព័ន្ធ | មូលដ្ឋានសុខាភិបាល | ៦០ | មិនទាន់បានអនុវត្ត | ០ | ១០០ | ០ | ០ | ២០០ | ៣០០ | ៥០០ | ប.ស.ស |
| ៣.៥ | ដាក់ភ្នាក់ងារ ប.ស.ស ប្រចាំការ នៅតាមមូលដ្ឋានសុខាភិបាល | ចំនួនភ្នាក់ងារ ប.ស.ស ប្រចាំការនៅតាមមូលដ្ឋានសុខាភិបាល | នាក់ | ២៨ | ៥ | ១៨ | ១០០ | ៣០ | ៣០ | ៥០ | ៥០ | ៥០ | ប.ស.ស |
| **ចង្កោមសកម្មភាពទី៤. ផ្សព្វផ្សាយសាធារណៈ និងកំណត់ជំហានអនុវត្ត** | | | | | | | | | | | | | |
| ៤.១ | ប្រជុំផ្សព្វផ្សាយ ស្តីពីការអនុវត្តរបប ធានារ៉ាប់រងសុខភាពតាមបណ្តា រាជធានី-ខេត្ត | ចំនួនកិច្ចប្រជុំផ្សព្វផ្សាយ | លើក | ១ | មិនទាន់បានអនុវត្ត | ០ | ៧ | ០ | ០ | ៥ | ៥ | ៧ | ប.ស.ស |
| ៤.២ | ផលិតស្ប៉ត និងខិត្តប័ណ្ណផ្សព្វផ្សាយ | ចំនួនស្ប៉ត និង ខិត្តប័ណ្ណផ្សព្វផ្សាយ | ស្ប៉ត | ១ | មិនទាន់បានអនុវត្ត | ០ | ០ | ០ | ០ | ១ | | ១ | ប.ស.ស |
| | | | ខិត្តប័ណ្ណផ្សព្វផ្សាយ | ១ | មិនទាន់បានអនុវត្ត | ០ | ០ | ០ | ០ | ១ | | ១ | |
| ៤.៣ | ដាក់ឲ្យអនុវត្តរបបធានារ៉ាប់រង សុខភាពតាមបណ្តារាជធានី-ខេត្ត | ចំនួនរាជធានី-ខេត្ត | រាជធានី-ខេត្ត | ១ | មិនទាន់បានអនុវត្ត | ០ | ៧ | ០ | ០ | ៥ | ៥ | ៧ | ប.ស.ស |
| ៤.៤ | ចុះបញ្ជិកា និងប្រមូលភាគទាន សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត | ចំនួនសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតចុះបញ្ជីក្នុងប្រព័ន្ធ | សហគ្រាស | ៦០០ | មិនទាន់បានអនុវត្ត | ០ | ៤.៥០០ | ០ | ០ | ២.០០០ | ២.០០០ | ៥.៩០០ | ប.ស.ស |
| | | | នាក់ | ៣៦០.០០០ | មិនទាន់បានអនុវត្ត | ០ | ៥៥០.០០០ | ០ | ០ | ៨០.០០០ | ៨០.០០០ | ៤៣០.០០០ | |
| ៤.៥ | ផ្តល់តាវកាលិករបបធានារ៉ាប់រងសុខភាពដល់កម្មករនិយោជិត | អត្រាសមាជិកប្រើប្រាស់សេវាធានារ៉ាប់រងសុខភាព | % | ៦០ | មិនទាន់បានអនុវត្ត | ០ | ៥០ | ០ | ០ | ៤៥ | ៤៥ | ៤៥ | ប.ស.ស |
| ៤.៦ | តាមដានពីផលប៉ះពាល់សុខភាពរបស់សមាជិកក្រោយទទួលបាន | អត្រាសមាជិកត្រូវបានការអង្កេត | % | ៥ | មិនទាន់បានអនុវត្ត | ០ | ៥ | ០ | ០ | ៥ | ៥ | ៥ | ប.ស.ស |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សេវាវេជ្ជសាស្ត្រ | | | | | | | | | | | | |
| ៤.៧ | អនុវត្តកម្មវិធីអប់រំផ្សព្វផ្សាយលើកកម្ពស់សុខភាព កម្មវិធីបង្ការ និងសង្គ្រោះបឋមកម្មករនិយោជិត | ចំនួនកម្មវិធីបង្ការ ត្រូវបានអប់រំផ្សព្វផ្សាយ | លើក | ១០ | មិនទាន់បានអនុវត្ត | ០ | ១៥ | ០ | ០ | ២០ | ២៥ | ៣០ | ប.ស.ស |

## អនុកម្មវិធីទី៣៖ ដាក់ឲ្យដំណើរការរបបប្រាក់សោធន

| ល.រ | សកម្មភាព | សូចនាករ | ឯកតា | ឆ្នាំអនុវត្ត | | | | | | | | | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៤ | | | ២០១៥ | | | ២០១៦ | ២០១៧ | ២០១៨ | |
| | | | | ផែនការ | លទ្ធផល | | ផែនការ | លទ្ធផល | | | | | |
| | | | | | ចំនួនឯកតា | ផលធៀប (%) | | ចំនួនឯកតា | ផលធៀប (%) | | | | |
| **ចង្កោមសកម្មភាពទី១. សិក្សាសមិទ្ធិលទ្ធភាពដាក់ឲ្យដំណើរការរបបប្រាក់សោធន** | | | | | | | | | | | | | |
| ១.១ | រៀបចំយន្តការរបបប្រាក់សោធន | ដំណើរការរៀបចំយន្ត ការរបបប្រាក់សោធន | % | ៥០ | ២០ | ៤០ | ១០០ | ០ | ០ | | | | ប.ស.ស |
| ១.២ | សិក្សាពីស្ថានភាពប្រជាសាស្ត្រ និងកម្មករនិយោជិត លើទម្រង់អាយុ សម្រាប់ការអនុវត្តរបបប្រាក់សោធន | ដំណើរការសិក្សា | % | ១០០ | មិនទាន់បានអនុវត្ត | ០ | ០ | ០ | ០ | | | | ប.ស.ស |
| ១.៣ | សិក្សាពីស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ច | ដំណើរការសិក្សា | % | ១០០ | មិនទាន់បានអនុវត្ត | ០ | ០ | ០ | ០ | | | | ប.ស.ស |
| ១.៤ | រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ ជាមួយដៃគូពាក់ព័ន្ធ | ចំនួនកិច្ចប្រជុំពិគ្រោះយោបល់ | លើក | ៨ | មិនទាន់បានអនុវត្ត | ០ | ៣ | ១ | ៣៣ | | | | ប.ស.ស |
| ១.៥ | សហការជាមួយជំនាញការគណិតវិទ្យាសន្តិសុខសង្គមដើម្បីកំណត់អត្រា ភាគទាន និងកញ្ចប់តាវកាលិក | ដំណើរការកំណត់អត្រាភាគទាន និងតាវកាលិក | % | ៥០ | មិនទាន់បានអនុវត្ត | ០ | ១០០ | ០ | ០ | | | | ប.ស.ស |
| **ចង្កោមសកម្មភាពទី២. រៀបចំលិខិតបទដ្ឋានគតិយុត្ត និងបណ្តុះបណ្តាលធនធានមនុស្ស** | | | | | | | | | | | | | |
| ២.១ | រៀបចំលិខិតបទដ្ឋានគតិយុត្ត | ដំណើរការរៀបចំ | % | ៥០ | ៥០ | ១០០ | ១០០ | ១០០ | ១០០ | | | | ប.ស.ស |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | លិខិតបទដ្ឋាន | | | | | | | | | | | |
| ២.២ | ប្រជុំពិគ្រោះយោបល់ជាមួយដៃគូពាក់ព័ន្ធ ប្រមូលផ្តុំនូវ មតិយោបល់ ដើម្បីដាក់ បញ្ចូលទៅក្នុងលិខិត បទដ្ឋានគតិយុត្ត | ចំនួនកិច្ចប្រជុំពិគ្រោះ យោបល់ | លើក | ៨ | មិនទាន់បាន អនុវត្ត | ០ | ៥ | ៣ | ៦០ | | | | ប.ស.ស |
| ២.៣ | ចាត់តាំង និងជ្រើសរើសមន្ត្រី និង បុគ្គលិកដែលមានចំណេះដឹងផ្នែក សោធនឲ្យបំពេញការងារ | ចំនួនមន្ត្រី និងបុគ្គលិក ធ្វើការផ្នែកប្រាក់សោធន | នាក់ | ១០ | ៦ | ៦០ | ៥ | ៥ | ១០០ | ៥ | ៥ | ៥ | ប.ស.ស |
| ២.៤ | សហការជាមួយដៃគូអភិវឌ្ឍន៍ធ្វើទស្សន កិច្ចសិក្សាដកស្រង់បទពិសោធន៍ ទាំង ក្នុង និងក្រៅប្រទេស | ចំនួនទស្សនកិច្ចសិក្សា | លើក | ២ | ៥ | ២៥០ | ២ | ៦ | ៣០០ | ២ | ២ | ២ | ប.ស.ស |
| ២.៥ | បណ្តុះបណ្តាលសមត្ថភាពមន្ត្រី និង បុគ្គលិកផ្នែកប្រាក់សោធន | ចំនួនមន្ត្រី និងបុគ្គលិកមាន សមត្ថភាព | នាក់ | ១០ | ៦ | ៦០ | ៥ | ៥ | ១០០ | ៥ | ៥ | ៥ | ប.ស.ស |
| **ចង្កោមសកម្មភាពទី៣. រៀបចំប្រព័ន្ធព័ត៌មានវិទ្យា សម្រាប់ការអនុវត្តរបបប្រាក់សោធន** | | | | | | | | | | | | | |
| ៣.១ | កសាងមូលដ្ឋានទិន្នន័យរបបប្រាក់ សោធន ដោយសហការជាមួយអ្នក ជំនាញការជាតិ និងអន្តរជាតិ | ដំណើរការកសាងមូលដ្ឋាន ទិន្នន័យ និងប្រព័ន្ធគ្រប់គ្រង | % | ៥០ | មិនទាន់បាន អនុវត្ត | ០ | ១០០ | ០ | ០ | | | | ប.ស.ស |
| ៣.២ | រៀបចំប្រព័ន្ធគ្រប់គ្រងគណនេយ្យ និង ហិរញ្ញវត្ថុ | ដំណើរការរៀបចំប្រព័ន្ធ គ្រប់គ្រង | % | ៥០ | មិនទាន់បាន អនុវត្ត | ០ | ១០០ | ០ | ០ | | | | ប.ស.ស |
| ៣.៣ | បង្កើតប្រព័ន្ធនៃការចុះបញ្ជិកា និង បង់ភាគទាន | ដំណើរការរៀបចំប្រព័ន្ធ ចុះ បញ្ជិកា និងបង់ភាគទាន | % | ៥០ | មិនទាន់បាន អនុវត្ត | ០ | ១០០ | ៥០ | ៥០ | | | | ប.ស.ស |
| ៣.៤ | បង្កើតប្រព័ន្ធនៃការផ្តល់តាវកាលិក | ដំណើរការរៀបចំប្រព័ន្ធ នៃការផ្តល់តាវកាលិក | % | ៥០ | មិនទាន់បាន អនុវត្ត | ០ | ១០០ | ៥០ | ៥០ | | | | ប.ស.ស |
| ៣.៥ | រៀបចំបញ្ជូនទិន្នន័យទៅគណនីរបស់ និវត្តន៍ជននៅធនាគារដៃគូ | ដំណើរការរៀបចំបញ្ជូន ទិន្នន័យ | % | ៥០ | មិនទាន់បាន អនុវត្ត | ០ | ១០០ | ៣០ | ៣០ | | | | ប.ស.ស |
| **ចង្កោមសកម្មភាពទី៤. ផ្សព្វផ្សាយសាធារណៈ និងកំណត់ជំហានអនុវត្ត** | | | | | | | | | | | | | |
| ៤.១ | ប្រជុំផ្សព្វផ្សាយស្តីពីការដាក់ឲ្យអនុវត្ត | កិច្ចប្រជុំផ្សព្វផ្សាយ តាម | លើក | ០ | ០ | ០ | ៣ | ០ | ០ | ៨ | ១៤ | | ប.ស.ស |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | របបប្រាក់សោធនតាមបណ្តារាជធានី-ខេត្ត | បណ្តារាជធានី-ខេត្ត | | | | | | | | | | | |
| ៤.២ | ផលិតស្ប៉ត និងខិត្តប័ណ្ណផ្សព្វផ្សាយ | ចំនួនស្ប៉ត និងខិត្តប័ណ្ណផ្សព្វផ្សាយ | ស្ប៉ត | ០ | ០ | ០ | ១ | ០ | ០ | ១ | ១ | ១ | ប.ស.ស |
| | | | ខិត្តប័ណ្ណ | ០ | ០ | ០ | ១ | ០ | ០ | ១ | ១ | ១ | |
| ៤.៣ | ដាក់ឲ្យអនុវត្តរបបប្រាក់សោធនតាមបណ្តារាជធានី-ខេត្ត | ចំនួនរាជធានី-ខេត្ត | រាជធានី-ខេត្ត | ០ | ០ | ០ | ៣ | ០ | ០ | ៨ | ១៤ | | ប.ស.ស |
| ៤.៤ | ចុះបញ្ជិកា និងប្រមូលភាគទានសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត | ចំនួនសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតបានចុះបញ្ជិកា និងបង់ភាគទាន | សហគ្រាស | ០ | ០ | ០ | ៥.៥០០ | ០ | ០ | ២.០០០ | ១.៥០០ | ៦.០០០ | ប.ស.ស |
| | | | នាក់ | ០ | ០ | ០ | ៧៩០.០០០ | ០ | ០ | ១៦០.០០០ | ១០០.០០០ | ៤៥០.០០០ | |
| ៤.៥ | ផ្តល់វិភាជន៍ជរាភាពដល់កម្មករនិយោជិត | ចំនួនកម្មករនិយោជិតទទួលបានតាវកាលិកវិភាជន៍ជរាភាព | នាក់ | ០ | ០ | ០ | ១.០៥៣ | ០ | ០ | ១.៥៦៨ | ២.៥៧៣ | ៤.១៥០ | ប.ស.ស |

## អនុកម្មវិធីទី៤៖ សេវាគាំទ្រ

| ល.រ | សកម្មភាព | សូចនាករ | ឯកតា | ឆ្នាំអនុវត្ត | | | | | | | | | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៤ | | | ២០១៥ | | | ២០១៦ | ២០១៧ | ២០១៨ | |
| | | | | ផែនការ | លទ្ធផល | | ផែនការ | លទ្ធផល | | | | | |
| | | | | | ចំនួនឯកតា | ផលធៀប (%) | | ចំនួនឯកតា | ផលធៀប (%) | | | | |
| **ចង្កោមសកម្មភាពទី១. បង្កើនប្រសិទ្ធភាព និងគុណភាពសេវារដ្ឋបាលសាធារណៈ** | | | | | | | | | | | | | |
| ១.១ | កសាងសមត្ថភាព និងបណ្តុះបណ្តាលធនធានមនុស្ស | អត្រាមន្ត្រី និងបុគ្គលិកទទួលបានការបណ្តុះបណ្តាល | % | ៥០ | ២៥ | ៥០ | ៥០ | ៧៧ | ១៥៤ | ៥០ | ៥០ | ៥០ | ប.ស.ស |
| ១.២ | ពង្រឹងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង និងគោលនយោបាយធនធានមនុស្ស | ប្រសិទ្ធភាពក្នុងការគ្រប់គ្រងផ្ទៃក្នុង | % | ៩០ | ៩០ | ១០០ | ៩៧ | ៩៧ | ១០០ | ៩៩ | ៩៩ | ៩៩ | ប.ស.ស |
| ១.៣ | ពង្រីកការផ្សព្វផ្សាយសាធារណៈពីការផ្តល់សេវាធានារ៉ាប់រងសន្តិសុខសង្គម | ភាពគ្រប់ដណ្តប់នៃការផ្តល់ព័ត៌មានជាសាធារណៈ | % | ៧០ | ៧០ | ១០០ | ៧០ | ៧០ | ១០០ | ៧០ | ៧០ | ៧០ | ប.ស.ស |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១.៤ | បង្កើតយន្តការទទួលព័ត៌មាន និងដោះស្រាយបញ្ហា | ប្រសិទ្ធភាពក្នុងការទទួលព័ត៌មាន និងដោះស្រាយបញ្ហា | % | ៨០ | ៨០ | ១០០ | ៩០ | ៩០ | ១០០ | ៩៥ | ៩៧ | ៩៧ | ប.ស.ស |
| ១.៥ | បង្កើតបណ្ណាល័យឯកសារពីការផ្តល់សេវាធានារ៉ាប់រងសន្តិសុខសង្គម | ដំណើរការរៀបចំ និងដាក់ឲ្យប្រើប្រាស់ | % | ០ | ០ | ០ | ៥០ | ០ | ០ | ១០០ | | | ប.ស.ស |
| ១.៦ | កែសម្រួលសមាសភាព តួនាទីភារកិច្ចគណៈកម្មការវេជ្ជសាស្ត្រ | ដំណើរការកែសម្រួលប្រកាស គណៈកម្មការវេជ្ជសាស្ត្រ នៃបេឡាជាតិរបបសន្តិសុខសង្គម | % | ១០០ | មិនទាន់បានអនុវត្ត | ០ | ០ | ០ | ០ | | | | ប.ស.ស |
| ១.៧ | រៀបចំប្រព័ន្ធគ្រប់គ្រងការប្រើប្រាស់សេវាសុខាភិបាល | ប្រសិទ្ធភាពនៃការទូទាត់ និងការប្រើប្រាស់សេវាសុខាភិបាល | % | ៩៥ | ៩០ | ៩៥ | ៩៦ | ៩០ | ៩៤ | ៩៧ | ៩៨ | ៩៩ | ប.ស.ស |
| ១.៨ | រៀបចំ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យា | ប្រសិទ្ធភាព នៃការបញ្ជូនទិន្នន័យ | % | ៩០ | ១០០ | ១១១ | ៩៥ | ១០០ | ១០៥ | ១០០ | | | ប.ស.ស |
| ១.៩ | សិក្សាអំពីលទ្ធភាពភ្ជាប់បណ្តាញព័ត៌មានវិទ្យាជាមួយនឹងធនាគារដៃគូ | ដំណើរការនៃការភ្ជាប់បណ្តាញព័ត៌មានវិទ្យាជាមួយនឹងធនាគារដៃគូ | % | ៥០ | ៥០ | ១០០ | ១០០ | ៥០ | ៥០ | | | | ប.ស.ស |
| ១.១០ | រៀបចំនីតិវិធី និងគោលនយោបាយអនុវត្តសម្រាប់ការប្រើប្រាស់ឧបករណ៍ និងប្រព័ន្ធព័ត៌មានវិទ្យា | ដំណើរការនៃការរៀបចំ | % | ១០០ | ៨០ | ៨០ | ០ | ០ | ០ | | | | ប.ស.ស |
| **ចង្កោមសកម្មភាពទី២. ពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ** | | | | | | | | | | | | | |
| ២.១ | កំណត់នីតិវិធី និងបែបបទនៃការគ្រប់គ្រងហិរញ្ញវត្ថុ | ដំណើរការនៃការកំណត់នីតិវិធី និងបែបបទនៃការគ្រប់គ្រងហិរញ្ញវត្ថុ | % | ១០០ | ៧០ | ៧០ | ០ | ០ | ០ | | | | ប.ស.ស |
| ២.២ | វិភាគហិរញ្ញវត្ថុរបបសន្តិសុខសង្គម | ចំនួនការវិភាគហិរញ្ញវត្ថុរបបសន្តិសុខសង្គម | ដង | ១ | ១ | ១០០ | ០ | ០ | ០ | | ១ | | ប.ស.ស |
| ២.៣ | បង្កើតគណៈកម្មការវិនិយោគ | ដំណើរការ នៃការរៀបចំបង្កើតគណៈកម្មការវិនិយោគ | % | ១០០ | ១០០ | ១០០ | ០ | ០ | ០ | | | | ប.ស.ស |
| ២.៤ | រៀបចំផែនការលទ្ធកម្ម និងផ្គត់ផ្គង់ឲ្យស្របតាមច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងគោលការណ៍ហិរញ្ញវត្ថុ | ប្រសិទ្ធភាពក្នុងការគ្រប់គ្រងកិច្ចការលទ្ធកម្ម និងផ្គត់ផ្គង់ | % | ៩០ | ៩០ | ១០០ | ៩៧ | ១០០ | ១០៣ | ៩៩ | ៩៩ | ៩៩ | ប.ស.ស |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ២.៥ | រៀបចំឲ្យមានយន្តការថែរក្សា និងប្រើប្រាស់ទ្រព្យសម្បត្តិរួម | ប្រសិទ្ធភាពក្នុងការប្រើប្រាស់ទ្រព្យសម្បត្តិ | % | ៩០ | ៩០ | ១០០ | ៩៧ | ១០០ | ១០៣ | ៩៩ | ៩៩ | ៩៩ | ប.ស.ស |
| **ចង្កោមសកម្មភាពទី៣. ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ និងអន្តរជាតិ** | | | | | | | | | | | | | |
| ៣.១ | ពង្រឹង និងពង្រីកកិច្ចសហការជាមួយនឹងស្ថាប័នជាតិ និងអន្តរជាតិដែលធ្វើការលើផ្នែកសន្តិសុខសង្គម | ប្រសិទ្ធភាពក្នុងការផ្លាស់ប្តូរព័ត៌មាន និងទិន្នន័យលើផ្នែកសន្តិសុខសង្គម | % | ៧០ | ៥០ | ៧១ | ៧៥ | ៦០ | ៨០ | ៨០ | ៨៥ | ៩០ | ប.ស.ស |
| ៣.២ | ពង្រឹងការអនុវត្តកាតព្វកិច្ច ចំពោះបទដ្ឋានជាតិ និងអន្តរជាតិលើផ្នែកសន្តិសុខសង្គម | ការអនុវត្តបានតាមបទដ្ឋានជាតិ និងអន្តរជាតិ | % | ៧០ | ៧០ | ១០០ | ៧៥ | ៧៥ | ១០០ | ៨០ | ៨៥ | ៩០ | ប.ស.ស |
| ៣.៣ | បន្តការតាមដាន និងអនុវត្តនូវកិច្ចព្រមព្រៀង និងអនុស្សរណៈនៃការយោគយល់គ្នា | ការរក្សាបាននូវចំណងកិច្ចសហប្រតិបត្តិការ | % | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ប.ស.ស |
| ៣.៤ | ចូលរួមប្រជុំប្រចាំឆ្នាំជាមួយ ASSA និង AWCF ព្រមទាំងចូលរួមកិច្ចប្រជុំ និងសិក្ខាសាលាផ្សេងៗទៀត | ចំនួនកិច្ចប្រជុំ និងសិក្ខាសាលា | លើក | ១០ | ១២ | ១២០ | ១០ | ២០ | ២០០ | ១០ | ១០ | ១០ | ប.ស.ស |
| ៣.៥ | រៀបចំទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ទាំងក្នុង និងក្រៅប្រទេស | ចំនួនទស្សនកិច្ចសិក្សា | លើក | ៥ | ២ | ៤០ | ៥ | ២ | ៤០ | ៥ | ៥ | ៥ | ប.ស.ស |
| **ចង្កោមសកម្មភាពទី៤. ពង្រឹងយន្តការរៀបចំផែនការ ស្ថិតិ និងនីតិកម្ម** | | | | | | | | | | | | | |
| ៤.១ | កសាងផែនការយុទ្ធសាស្ត្ររយៈពេលវែង និងផែនការប្រចាំឆ្នាំ | មានផែនទីបង្ហាញផ្លូវសម្រាប់តម្រង់ទិសការអនុវត្តបានចំគោលដៅ | % | ១០០ | ៩០ | ៩០ | ១០០ | ១០ | ១០០ | ១០០ | ១០០ | ១០០ | ប.ស.ស |
| ៤.២ | ធ្វើរបាយការណ៍លទ្ធផលការងារប្រចាំឆ្នាំ និងលើកទិសដៅអនុវត្ត | មានយន្តការប្រៀបធៀប និងវាយតម្លៃការអនុវត្ត | របាយការណ៍ | ១ | ១ | ១០០ | ១ | ១ | ១០០ | ១ | ១ | ១ | ប.ស.ស |
| ៤.៣ | ចងក្រង និងកែសម្រួលលិខិតបទដ្ឋានគតិយុត្ត ដើម្បីធានាផ្តល់សេវាសន្តិសុខសង្គម ឲ្យបានកាន់តែមានប្រសិទ្ធភាព និងស្របតាមស្ថានភាពអភិវឌ្ឍទាំងនៅកម្រិតថ្នាក់ជាតិ តំបន់ និងអន្តរជាតិ | ប្រសិទ្ធភាព និងវឌ្ឍនភាពនៃសេវាសន្តិសុខសង្គម | % | ៨០ | ៨០ | ១០០ | ៨៥ | ៨៥ | ១០០ | ៩០ | ៩៥ | ៩៧ | ប.ស.ស |
| ៤.៤ | បន្តសហការជាមួយក្រសួងអាណាព្យាបាល និងស្ថាប័នពាក់ព័ន្ធក្នុងការកសាងផែនការ ស្ថិតិ និងការងារនីតិកម្មតាម | ការអនុវត្តបានតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល | % | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ប.ស.ស |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | គោលនយោបាយរបស់រាជរដ្ឋាភិបាល | | | | | | | | | | | | |
| ៤.៥ | ពង្រឹងការចាត់វិធានការរដ្ឋបាលចំពោះការមិនអនុវត្តតាមច្បាប់ និងគោលការណ៍សន្តិសុខសង្គម | ចំនួនការចាត់វិធានការ នៃករណីមិនអនុវត្តតាមច្បាប់ និងគោលការណ៍ | % | ៨០ | ៨០ | ១០០ | ៩០ | ៩៦ | ១០៦ | ១០០ | ១០០ | ១០០ | ប.ស.ស |
| **ចង្កោមសកម្មភាពទី៥. ពង្រឹងការងារសវនកម្មផ្ទៃក្នុង** | | | | | | | | | | | | | |
| ៥.១ | កសាងផែនការ និងធ្វើរបាយការណ៍សវនកម្មប្រចាំឆ្នាំ | ប្រសិទ្ធភាពក្នុងការអនុវត្តការងារសវនកម្មផ្ទៃក្នុងបានចំទិសដៅ | % | ៨៥ | ៥០ | ៥៩ | ៩០ | ៧០ | ៧៨ | ៩៥ | ៩៧ | ៩៧ | ប.ស.ស |
| ៥.២ | សហការជាមួយអាជ្ញាធរសវនកម្មជាតិ និងស្ថាប័នជំនាញ រៀបចំវគ្គបណ្តុះបណ្តាលពីចំណេះដឹងផ្នែកសវនកម្ម, ការងារហិរញ្ញវត្ថុ, យន្តការគ្រប់គ្រងផ្ទៃក្នុង និងចំណេះដឹងផ្សេងៗទៀត | ចំនួនវគ្គបណ្តុះបណ្តាល | លើក | ១ | មិនទាន់បានអនុវត្ត | ០ | ១ | ០ | ០ | ១ | ១ | ១ | ប.ស.ស |
| ៥.៣ | សហការជាមួយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអនុវត្តការងារសវនកម្មផ្ទៃក្នុង | ការធ្វើសវនកម្មប្រចាំឆ្នាំ | លើក | ១ | ១ | ១០០ | ១ | ១ | ១០០ | ១ | ១ | ១ | ប.ស.ស |
| ៥.៤ | ត្រួតពិនិត្យ តាមដាន វាយតម្លៃ និងផ្តល់អនុសាសន៍លើការអនុវត្តគោលនយោបាយសន្តិសុខសង្គម | ប្រសិទ្ធភាពក្នុងការគ្រប់គ្រងគោលនយោបាយសន្តិសុខសង្គម | % | ៨០ | ៨០ | ១០០ | ៨៥ | ៨០ | ៩៤ | ៩០ | ៩៥ | ៩៩ | ប.ស.ស |
| ៥.៥ | ធ្វើសវនកម្ម និងស៊ើបអង្កេតលើផ្នែកហិរញ្ញវត្ថុ, ភាគទាន, ការផ្តល់តាវកាលិក, ព្រមទាំងសកម្មភាពផ្សេងៗទៀត ទាំងនៅការិយាល័យថ្នាក់កណ្តាល និងការិយាល័យសាខា | ការកែសម្រួល និងអភិវឌ្ឍបានប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ, ភាគទាន និងការផ្តល់តាវកាលិករបបសន្តិសុខសង្គម | % | ៧០ | មិនទាន់បានអនុវត្ត | ០ | ៧៥ | ៦០ | ៨០ | ៨០ | ៨៥ | ៩០ | ប.ស.ស |
| **ចង្កោមសកម្មភាពទី៦. លើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យសន្តិសុខសង្គម** | | | | | | | | | | | | | |
| ៦.១ | ជំរុញ និងលើកទឹកចិត្តស្ត្រីឲ្យចូលបម្រើការនៅក្នុងការងារសន្តិសុខសង្គមព្រមទាំងផ្តល់អាទិភាពឲ្យមានតួនាទីសំខាន់ៗ | អគ្រាមន្ត្រី និងបុគ្គលិកជាស្ត្រីដែលបម្រើការងារនៅ ប.ស.ស | % | ៥០ | ៣៤ | ៦៨ | ៥០ | ៣៦ | ៧២ | ៥០ | ៥០ | ៥០ | ប.ស.ស |
| ៦.២ | ផ្តល់ការធានារ៉ាប់រងគ្រោះថ្នាក់ការងារ, | កម្មការិនី និងនិយោជិតជា | % | ៧១ | ៧១ | ១០០ | ៧១ | ៧១ | ១០០ | ៧១ | ៧១ | ៧១ | ប.ស.ស |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ធានារ៉ាប់រងសុខភាព និងរបបប្រាក់សោធន | ស្ត្រីទទួលបានការធានារ៉ាប់រង ធៀបនឹងកម្មករនិយោជិតសរុបដែលបានចុះបញ្ជិកា | | | | | | | | | | | |
| ៦.៣ | ចូលរួមកសាងផែនការ និងរបាយការណ៍លើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យសន្តិសុខសង្គមជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធនានា | ការបញ្ជ្រាប និងចែករំលែកព័ត៌មានយេនឌ័រក្នុងវិស័យសន្តិសុខសង្គមជាមួយស្ថាប័នពាក់ព័ន្ធ | % | ៧០ | ៧០ | ១០០ | ៧០ | ៧០ | ១០០ | ៧០ | ៧០ | ៧០ | ប.ស.ស |

# អាសយដ្ឋាន និងលេខទូរស័ព្ទសម្រាប់ទំនាក់ទំនងជាមួយ ប.ស.ស តាមបណ្ដាខេត្ត

| ល.រ | ខេត្ត | អាសយដ្ឋាន | លេខទូរស័ព្ទដៃ | លេខទូរស័ព្ទលើតុ | E-mail |
|---|---|---|---|---|---|
| ១ | ខេត្តកណ្ដាល | ផ្ទះលេខ០១ ផ្លូវលេខ២០២, ភូមិដើមមៀន, សង្កាត់ដើមមៀន, ក្រុងតាខ្មៅ, ខេត្តកណ្ដាល | ០៨៥ ៥៦៧ ៧៦៦<br>៩៧៧ ៩៦៣ ០៧៨ | ០២៤ ៦៤០ ១៦៧៦ | samphearak@nssf.gov.kh |
| | | ភូមិក្នុង, ឃុំព្រែកតាមាក់, ស្រុកខ្សាច់កណ្ដាល, ខេត្តកណ្ដាល | ០៩៦ ៦១៥ ៦១៦៨<br>០១២ ៥៤៨ ៨០៥<br>០៩៨ ៥៤៨ ៨០៥ | ០២៣ ៥១៩ ៨៩៩៩ | nssf_reythearith@nssf.gov.kh |
| ២ | ខេត្តកំពង់ស្ពឺ | ផ្ទះលេខ៣៦A ភូមិស្វាយជ្រុំ, ឃុំបែកចាន, ស្រុកអង្គស្នួល, ខេត្តកណ្ដាល | ០១២ ២៨៦ ៨៧៩<br>០១៥ ២១០ ២១០<br>០៦០ ២១២ ២១២ | ០២៤ ៥០៨ ០៧៧៧ | movratha@yahoo.com |
| ៣ | ខេត្តស្វាយរៀង | ផ្លូវជាតិលេខ០១, ភូមិបាវិតលើ, សង្កាត់បាវិត, ក្រុងបាវិត, ខេត្តស្វាយរៀង | ០៧៧ ៦៦៣ ២១៤ | ០៤៤ ៧១៥ ៨៣១ | pek.samol@nssf.gov.kh |
| ៤ | ខេត្តព្រះសីហនុ | សង្កាត់លេខ០៤, ក្រុងព្រះសីហនុ, ខេត្តព្រះសីហនុ | ០១៧ ៩៣៣ ៣៩៦<br>០៧៧ ៦៦៣ ២១៥ | ០៣៤ ៩៣៤ ៦០៦ | tong_samnieng@nssf.gov.kh |
| ៥ | ខេត្តកំពង់ឆ្នាំង | ផ្ទះលេខC៤៩៥, ក្រុមទី១៨, ភូមិម៉ុងបារាំង, សង្កាត់ប្អេរ, ក្រុងកំពង់ឆ្នាំង, ខេត្តកំពង់ឆ្នាំង | ០៧៧ ៦៦៣ ២១៦<br>០១៦ ៨៨៤ ៣៤៨ | ០២៦ ៩៨៨ ៨៩១<br>០២៦ ៧៧៥ ៥៦៦ | nssf_kcn@nssf.gov.kh |
| ៦ | ខេត្តសៀមរាប | ផ្ទះលេខP១០, ភូមិត្រពាំងសេះ, ឃុំគោកចក, ក្រុងសៀមរាប, ខេត្តសៀមរាប | ០១២ ៥៣៤ ៣៤៥<br>០៧៧ ៦៦៣ ២១៧ | ០៦៣ ៩៦៥ ៩៣៤ | pang_sokchea@yahoo.com<br>sokchea@nssf.gov.kh |
| ៧ | ខេត្តបន្ទាយមានជ័យ | ភូមិគីឡូម៉ែតលេខ០៤, សង្កាត់ផ្សារកណ្ដាល, ក្រុងប៉ោយប៉ែត, ខេត្តបន្ទាយមានជ័យ | ០៧៧ ៦៦៣ ២១៨<br>០៨៩ ៩៨៧ ៨៨៧ | ០៥៤ ៧១១ ៤៤១ | nssf_bmc@nssf.gov.kh |
| ៨ | ខេត្តកំពង់ចាម | ភូមិទី១៤, សង្កាត់វាលវង់, ក្រុងកំពង់ចាម, ខេត្តកំពង់ចាម | ០១២ ៥២០ ៧៦៧<br>០៧៧ ៩៩០ ០៤៨ | ០៤២ ៦៥២ ១៩៩៩<br>០៤២ ៩៤៣ ៣៨៨ | say.sothon@nssf.gov.kh |

| ល.រ | ខេត្ត | អាសយដ្ឋាន | លេខទូរស័ព្ទដៃ | លេខទូរស័ព្ទលើតុ | E-mail |
|---|---|---|---|---|---|
| ៩ | ខេត្តក្រចេះ | ផ្លូវជាតិលេខ៧៣, ភូមិរកាកណ្តាលទី០១, សង្កាត់រកាកណ្តាល, ក្រុងក្រចេះ, ខេត្តក្រចេះ | ០៩២ ៨៧៣ ០៥១<br>០៩៧ ២៦២ ៧៥៤៧ | ០៧២ ២១០ ៤២៣ | kratie@nssf.gov.kh<br>soksay.he@nssf.gov.kh |
| ១០ | ខេត្តព្រៃវែង | ផ្ទះលេខ១០៧, ភូមិលេខ០៣, សង្កាត់កំពង់លាវ, ក្រុងព្រៃវែង, ខេត្តព្រៃវែង | ០១២ ៥៤៨ ៨០៥<br>០៩២ ៧០៨ ៨០៣ | | reythearith@yahoo.com<br>rey.thearith@nssf.gov.kh |
| ១១ | ខេត្តតាកែវ | ផ្លូវលេខ១០, ភូមិ០២, សង្កាត់រកាក្នុង, ក្រុងដូនកែវ, ខេត្តតាកែវ | ០១២ ៦៣៦ ៤៣៩ | ០៣២ ២១០ ៦៦៦ | vannak-rk@nssf.gov.kh<br>vannaknssf@gmail.com |
| ១២ | ខេត្តកំពត | ភូមិ០១ឧសភា, ឃុំកំពង់កណ្តាល, ស្រុកកំពុងបាយ, ក្រុងកំពត, ខេត្តកំពត | ០១២ ៦២៣ ៣៣២<br>០៧២ ៦៨៨ ៨៨៦ | ០៣៣ ៩៣២ ១៣៣ | phokchetra@gmail.com<br>sin.kosal@nssf.gov.kh |
| ១៣ | ខេត្តកោះកុង | ផ្ទះលេខ២៦, ក្រុម០២, ភូមិ០៣, សង្កាត់ដងទង់, ក្រុងខេមរភូមិន្ទ, ខេត្តកោះកុង | ០៩៧ ៩៧៣ ៩០០៦<br>០១២ ៦២៥ ៨៥៥ | ០៣៥ ៩៣៦ ៤៣៦ | kongkea.nssf.kk@gmail.com |
| ១៤ | ខេត្តបាត់ដំបង | ផ្ទះលេខB០៩, បុរីពាណិជ្ជកម្មបាត់ដំបង, សង្កាត់ស្វាយប៉ោ, ក្រុងបាត់ដំបង, ខេត្តបាត់ដំបង | ០៩៧ ៩៩៧ ២៨២៩ | ០៥៣ ៩៥៣ ៣៣៦ | battambang@nssf.gov.kh |
| ១៥ | ខេត្តប៉ៃលិន | ភូមិវត្ត, សង្កាត់ប៉ៃលិន, ក្រុងប៉ៃលិន, ខេត្តប៉ៃលិន | ០៨៦ ៨៩៣ ៧៧៧ | ០៥៥ ៩៥៦ ៦៦៧ | somit.ream@nssf.gov.kh |
| ១៦ | ខេត្តពោធិ៍សាត់ | ផ្ទះលេខ០០៧, ភូមិរាំ, សង្កាត់ផ្ទះព្រៃ, ក្រុងពោធិ៍សាត់, ខេត្តពោធិ៍សាត់ | ០៩២ ៧០៧ ៣៨៥ | ០៥២ ៩៥១ ១២៣ | nssf_ps@nssf.gov.kh |
| ១៧ | ខេត្តកំពង់ធំ | ភូមិទី០៧,សង្កាត់កំពង់ធំ, ក្រុងស្ទឹងសែន, ខេត្តកំពង់ធំ | ០៩២ ៧៤៧ ០៩៩ | ០៦២ ២១០ ៤៦៣ | ly_sokha2007@yahoo.com |
| ១៨ | ខេត្តស្ទឹងត្រែង | ភូមិថ្មលាត, សង្កាត់ស្រះឫស្សី, ក្រុងស្ទឹងត្រែង, ខេត្តស្ទឹងត្រែង | ០១២ ៤០៥ ៤៥១ | | nganrachana@gmail.com |
| ២៩ | ខេត្តរតនគិរី | ភូមិទេសអន្លង់, សង្កាត់បឹងកន្សែង, ក្រុងបាលុង, ខេត្ត រតនគិរី | ០១១ ៤៥១ ៧៧៧<br>០៩៧ ៩៦៦ ៧៦៦៦ | ០៧៥ ៩៧៤ ១៨៤ | sam_ath@nssf.gov.kh |

| ល.រ | ខេត្ត | អាស័យដ្ឋាន | លេខទូរស័ព្ទដៃ | លេខទូរស័ព្ទលើតុ | E-mail |
|---|---|---|---|---|---|
| ២០ | ខេត្តមណ្ឌលគិរី | ភូមិចំបក់, សង្កាត់ស្ពានមានជ័យ, ក្រុងសែនមនោរម្យ, ខេត្តមណ្ឌលគិរី | ០១២ ២០៥ ៧៥៦<br>០៨៨ ៨២០ ៥៧៥៦ | | kosol_vicheth@yahoo.com |
| ២១ | ខេត្តឧត្តរមានជ័យ | ភូមិឈ្មូក, សង្កាត់សំរោង, ក្រុងសំរោង, ខេត្តឧត្តមានជ័យ | ០៩៧ ៥២៣ ៤៦៦៦<br>០៨៥ ៣១១ ៣០០ | | simmao2013@gmail.com |
| ២២ | ខេត្តព្រះវិហារ | ភូមិកណ្តាល, សង្កាត់កំពង់ប្រណាក, ក្រុងព្រះវិហារ, ខេត្តព្រះវិហារ | ០៩៧ ៣៦៦ ៦០៦០<br>០១២ ២៥៩ ២៥៨ | | nssf_pvh@nssf.gov.kh<br>savuthnou22@gmail.com |
| ២៣ | សាខាខណ្ឌដង្កោ | ផ្ទះលេខ១២A, ផ្លូវវេងស្រេង, សង្កាត់ចោមចៅ, ខ័ណ្ឌពោធិ៍សែនជ័យ, រាជធានីភ្នំពេញ, (ទល់មុខផែរស្ទួតសូរង្ងន) | ០១២ ៦៩៥ ៥៥០<br>០៨៦ ២៧១ ៣៧១ | ០២៣ ៩៩៥ ៤៨៤ | lpl@nssf.gov.kh |
| ២៤ | សាខាខណ្ឌឫស្សីកែវ | ផ្ទះលេខ៥០$E_0E_1$, ផ្លូវលេខ០៣, ភូមិបឹងឈូក, សង្កាត់គីឡូម៉ែត០៦, ខណ្ឌឫស្សីកែវ, រាជធានីភ្នំពេញ | ០៩២ ៤៨៦ ២៥៦<br>០៨៨ ៦៩១ ១៩១១ | ០២៣ ៦៦៣ ៣០៣០ | vannaknssf@nssf.gov.kh |

# មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស

| ល.រ | ឈ្មោះមន្ទីរពេទ្យ | ឡានសាម៉ុយ | ទូរស័ព្ទទំនាក់ទំនង | ភ្នាក់ងារ ប.ស.ស | អាស័យដ្ឋានមន្ទីរពេទ្យ |
|---|---|---|---|---|---|
| I. | **រាជធានីភ្នំពេញ** | | | | |
| ០១ | មន្ទីរពេទ្យកាល់ម៉ែត | ១១៩ | ០២៣ ៤២៦ ៩៤៨<br>០២៣ ៧២៤ ៨៩១ | ០៩៧ ៦៨៧ ២៤ ២៦<br>០៩២ ១៥១ ៨៤៥ | ឡូត៍លេខ៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| ០២ | មន្ទីរពេទ្យព្រះកុសុមៈ | ១១៩ | ០១២ ៦៥៧ ៦៥៣<br>០១៦ ៩០៩ ៧៧៤ | ០១៧ ៣៧៨ ៤៥៦<br>០៧៨ ៣២១ ៨១៨ | អាគារលេខ១៨៨ ផ្លូវ ២៧១ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ |
